វិចារណកថា
EDITORIAL

# ជោគជ័យឆ្នាំទី ១ របស់រាជរដ្ឋាភិបាលនីតិកាលទី ៥ នៃរដ្ឋសភា

## The First-Year Gains of the Fifth Legislative Term Royal Government

នៅថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ សម័យប្រជុំដំបូងនៃរដ្ឋសភានីតិកាលទី ៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** បានអនុម័តផ្តល់សេចក្តីទុកចិត្តលើសមាសភាពរាជរដ្ឋាភិបាលនីតិកាលទី ៥ នៃរដ្ឋសភា ដែលមានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី ។ នៅថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០១៣ រាជរដ្ឋាភិបាលកម្ពុជាបានបើកសម័យប្រជុំរបស់ខ្លួនជាលើកដំបូងហើយបានប្រកាសជូនជនរួមជាតិនូវកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ សម្រាប់រយៈពេល ៥ ឆ្នាំបន្តទៀត ។ មកដល់ពេលនេះ រាជរដ្ឋាភិបាលកម្ពុជាមានអាយុគ្រប់ ១ ឆ្នាំ ហើយ ។

កម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាល បានបង្ហាញច្បាស់នូវគោលបំណង ឧត្តមគតិ និងការប្តេជ្ញាដ៏មោះមុតរបស់រាជរដ្ឋាភិបាល ក្នុងការការពាររាល់សមិទ្ធផលនៃសង្គមជាតិ និងបន្តកសាង និងការពារមាតុភូមិឆ្ពោះទៅរកអនាគតដ៏រុងរឿង ស្របតាមឆន្ទៈ និងបំណងប្រាថ្នារបស់ប្រជាជនកម្ពុជា ។ រាជរដ្ឋាភិបាលក៏បានបញ្ជាក់នូវជំហរប្តូរផ្តាច់ក្នុងការបន្តអនុវត្តកំណែទម្រង់ដ៏ទូលំទូលាយ និងស៊ីជម្រៅក្នុងវិស័យទាំងឡាយ សំដៅបំបាត់រាល់ឧបសគ្គដែលរារាំងដល់ការអភិវឌ្ឍ ការផ្តល់សេវាប្រកបដោយគុណភាព ការពង្រឹងយុត្តិធម៌ សមធម៌សង្គម និងការលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាជនទូទៅ ។

គួរបញ្ជាក់ថា ក្រោយការបោះឆ្នោតជាតិនីតិកាលទី ៥ នាថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៣ គណបក្សប្រឆាំង និងមជ្ឈដ្ឋានអគតិនានា បានរិះរកវិធីសព្វបែបយ៉ាង ដើម្បីបង្កឱ្យមានអស្ថិរភាពនយោបាយ និងសង្គម ក្នុងគោលបំណងផ្តួលរំលំរាជរដ្ឋាភិបាលថ្មីដែលកើតចេញពីការបោះឆ្នោត ។ ជាក់ស្តែង ពួកគេបានបដិសេធលទ្ធផលនៃការបោះឆ្នោតធ្វើពហិការមិនចូលរួមប្រជុំដំបូងនៃរដ្ឋសភាចលនាបណ្តាប្រទេសនិងស្ថាប័នអន្តរជាតិនានាឱ្យផ្អាកទំនាក់ទំនងជាមួយរដ្ឋាភិបាលកម្ពុជា និងជំរុញការធ្វើបាតុកម្មតាមដងផ្លូវយ៉ាងអនាធិបតេយ្យ ទាមទារឱ្យមានការផ្លាស់ប្តូរការដឹកនាំ តាមរយៈរបស់ដែលហៅថា "អំណាចប្រជាជន" រហូតបង្កជាកុប្បកម្មដ៏ហិង្សា ដែលធ្វើឱ្យបាត់បង់ជីវិតមនុស្ស ទ្រព្យសម្បត្តិសាធារណៈ និងឯកជន និងប៉ះពាល់យ៉ាងខ្លាំងដល់សន្តិសុខសណ្តាប់ធ្នាប់សង្គម ។ ទង្វើប្រទូសរ៉ាយនេះ បានរំលោភយ៉ាងធ្ងន់ធ្ងរលើរដ្ឋធម្មនុញ្ញ ឆន្ទៈរបស់ប្រជាជនជាម្ចាស់ឆ្នោត និងគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ ព្រមទាំងប្រមាថដល់ស្ថាប័នព្រះមហាក្សត្រ ។ បំណងប្រាថ្នារបស់ពួកគេគឺធ្វើឱ្យសង្គមកម្ពុជាត្រូវច្របូកច្របល់

On 24 September 2013, the first session of the fifth legislative term of the National Assembly, convened under the presidency of Samdech Punhea Chakrey Heng Samrin, adopted a resolution to endorse the Royal Government's Cabinet for the fifth legislative term of the National Assembly and Samdech Akka Moha Sena Padei Techo Hun Sen as the Prime Minister. On 25 September 2013, the Royal Government of Cambodia convened its first session and declared to the public its political platform and Rectangular Strategy Phase III for the coming five years. As of now, the Royal Government of Cambodia is one year old.

The political platform and Rectangular Strategy Phase III of the Royal Government clearly shows its aim, ideal and unfaltering determination in defending national achievements and continuing to build and defend the prosperous future of the motherland in conformity with the will and aspiration of the Cambodian people. The Royal Government of Cambodia ascertains resolutely its position in continuing to implement wide ranging and profound reforms in every field aimed at eradicating obstacles that are preventing the course of development, providing quality service in strengthening justice and social equity, and raising high living condition of the people in general.

It is worth affirming that after the national election of the fifth legislative term on 28 July 2013, the opposition party and ill-will circles sought out all means to instigate socio-political instability aimed at bringing down the new government born out of the elections. It was factual that they denied results of the elections, boycotted the first session of the National Assembly, mobilized countries and international institutions to suspend relations with the Royal Government of Cambodia. In the mean time, they also bolstered anarchic street demonstrations demanding leadership change by the so-called means of "people's power" leading to violent clashes causing deaths, damages of public and private properties, while deteriorating social security and order.

The threats seriously violated the Constitution, voters' will and principle of democracy, while inflicting insult to HM the King. Their aims were to destabilize the Cambodian society in such a way that it would be stuck and derailing from the path of democracy, while forcing the Cambodian People's Party to accept conditions they so raised. Despites all, the Cambodian situation was irreversible. Cambodia continues to march energetically on the path of peace, democracy, rule of law and development.

The fifth legislative term Royal Government under the leadership of Samdech Techo Hun Sen has promoted fruitful and responsible implementation of its political platform basing on legal and democratic principle and rule of law. The Royal Government takes effective measures to guarantee sustainability of all institutions at every level while maintaining political stability, security, social order and regularity in people's livelihood.

ក្រឡាប់ចាក់ជាប់គាំងទៅមុខមិនរួច ធ្លាក់ចេញពីមាគ៌ាប្រជាធិបតេយ្យ ហើយចាប់បង្ខំឱ្យគណបក្សប្រជាជនកម្ពុជាត្រូវទទួល យកនូវលក្ខខណ្ឌរបស់ពួកគេ ។ ប៉ុន្ដែសភាពការណ៍កម្ពុជាមិនអាចត្រូវពួកគេធ្វើឱ្យផ្លាស់ប្ដូរបានឡើយ កម្ពុជានៅតែបន្ដដំណើរទៅមុខយ៉ាងស្វាហាប់លើមាគ៌ាសន្ដិភាព ប្រជាធិបតេយ្យ នីតិរដ្ឋ និងអភិវឌ្ឍន៍ ។

រាជរដ្ឋាភិបាលនីតិកាលទី ៥ ក្រោមការដឹកនាំរបស់សម្ដេចតេជោ **ហ៊ុន សែន** បានជំរុញការអនុវត្តកម្មវិធីនយោបាយរបស់ខ្លួនប្រកបដោយផ្លែផ្កា និងការទទួលខុសត្រូវ ដោយឈរលើមូលដ្ឋានច្បាប់ គោលការណ៍ប្រជាធិបតេយ្យ និងនីតិរដ្ឋ ។ រាជរដ្ឋាភិបាលបានចាត់វិធានការនានាប្រកបដោយប្រសិទ្ធភាព ធានាបាននិរន្ដរភាពនៃគ្រប់ស្ថាប័នរដ្ឋនៅគ្រប់ថ្នាក់ រក្សាបានស្ថិរភាពនយោបាយ សន្ដិសុខសណ្ដាប់ធ្នាប់សង្គម និងប្រក្រតីភាពនៃជីវភាពរបស់ប្រជាជន ។ វិស័យការបរទេសក៏មានដំណើរការទៅមុខយ៉ាងល្អប្រសើរ ទោះបីជាគណបក្សប្រឆាំងខិតខំរកគ្រប់វិធីដើម្បីរាំងស្កាត់យ៉ាងណាក្ដី ។ កម្ពុជាបានបន្ដដំណើរការសមាហរណកម្មទាំងក្នុងក្របខណ្ឌតំបន់ និងពិភពលោក បានចូលរួមនៅរាល់កិច្ចប្រជុំជាអន្ដរជាតិនានា បានពង្រីកនូវចំណងមិត្ដភាព និងសហប្រតិបត្តិការជាមួយបណ្ដាប្រទេស និងបណ្ដាស្ថាប័នអន្ដរជាតិប្រកបដោយផ្លែផ្កា ។ វិស័យសេដ្ឋកិច្ចបាន និងកំពុងបន្ដរីកចម្រើនប្រកបដោយមោទនភាព ដោយធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ស្ថិរភាពប្រាក់រៀល ឯអតិផរណាក៏ស្ថិតក្នុងកម្រិតទាប ។ ឆ្នាំ២០១៣ សេដ្ឋកិច្ចកម្ពុជាសម្រេចបានកំណើន ៧,៤% ហើយនៅឆ្នាំ ២០១៤ នេះ នឹងសម្រេចបានកំណើនមិនតិចជាង ៧% ឡើយ ឯអត្រានៃភាពក្រីក្រ ក៏ត្រូវបានកាត់បន្ថយមកនៅក្រោម ១៨% ។ ចំណូលពន្ធដារ និងពន្ធគយបានកើនឡើងច្រើន ដែលបង្កលក្ខណសម្បត្តិល្អដល់រាជរដ្ឋាភិបាលឱ្យដំឡើងបានប្រាក់បៀវត្សជូនមន្ដ្រី រាជការ កងកម្លាំងប្រដាប់អាវុធ និងបង្កើនការវិនិយោគសាធារណៈ ។ វិស័យកសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម ហេដ្ឋារចនាសម្ព័ន្ធ ធនធានទឹក បរិស្ថាន ទេសចរណ៍ អប់រំ សុខាភិបាល សង្គមកិច្ច វប្បធម៌ ... សុទ្ធតែមានការរីកចម្រើនទាំងអស់ ។ ដោយឡែក វិស័យអប់រំសម្រេចបានលទ្ធផលលេចធ្លោក្នុងជំហានថ្មីនៃការកែទម្រង់របស់ខ្លួន ដែលចាប់ផ្ដើមពីការប្រឡងមធ្យមសិក្សាបត្រទុតិយភូមិ ។ វិស័យការងារបានលើកកម្ពស់លក្ខខណ្ឌការងាររបស់កម្មករនិយោជិត ហើយបានជំរុញការដំឡើងប្រាក់ឈ្នួលអប្បបរមាក្នុងវិស័យកាត់ដេរ និងវាយនភណ្ឌឱ្យកើនឡើងជាបន្ដ បន្ទាប់សម្រាប់ឆ្នាំនីមួយៗ ។ រាជរដ្ឋាភិបាលបានបង្កើតឱ្យមានវេទិកាសាធារណៈថ្នាក់ជាតិនៅគ្រប់រាជធានី ខេត្ត ដែលផ្ដល់ឱកាសកាន់តែច្រើនឱ្យប្រជាជននៅមូលដ្ឋានបានសម្ដែងមតិរបស់ខ្លួនអំពីកង្វល់ ការលំបាក និងសំណូមពរផ្សេងៗ ឆ្លុះបញ្ចាំងជូនរដ្ឋាភិបាល រាល់ក្រសួង ស្ថាប័ន អាជ្ញាធរ និងសមត្ថកិច្ច

On the front of foreign affairs, the Royal Government has scored good achievements. Cambodia continues to move along with regional and world integration. Cambodia participates in various international meetings while expanding fruitful bonds of friendship and cooperation with other countries and international institutions. On the economic front, Cambodia has gone on making proud achievements in guaranteeing macroeconomic stability and stabilizing the Riel currency. Cambodia has kept a low rate of inflation. In 2013, Cambodia realized a 7.4% growth, and in 2014, it has anticipated a growth no less than 7%, while bringing down the poverty rate to below 18%. Incomes from taxation and excise have increased. It creates a favorable condition for the Royal Government to increase salary for government officials, armed forces and increases public investment.

Cambodia has also achieved remarkable progresses in other fields – agriculture, industry, trade, infrastructure, water resources, environment, education, health, social affairs, culture, etc. In area of education, Cambodia hammered out particularly outstanding result in a new step of reform starting from the senior secondary school exam. In area of labor, Cambodia has seen the improvement of working condition of our workers and employees, while working with concerned agencies to increase gradually basic minimum salary in the field of garment and textile in each coming year.

The Royal Government has set up a mechanism of public forum at national level in all cities and provinces, which gives our people in every corner more chance to make their opinions and concerns, hardships as well as requests heard to and for solutions from the Royal Government, concerned ministries, institutions and competent authorities at all levels. Thanks to the public forum, the Royal Government sees a clearer truth in its implementation of the political platform – both in strong and weak points, that helps in taking further strengthening or improving measures.

Having seen the Royal Government's strong standing, the opposition party has brought itself to understand that they could not bring down the Royal Government. It is on this development that on 8 August 2014, the members of the National Assembly from the opposition party joined the sessions of the National Assembly leading to the end of the nearly one-year old political crisis. It has become now a chance for every Cambodian people to stand united in defending national achievements and further developing the country.

Despites these facts, the Royal Government still has more challenges ahead to resolve. Take for instance we still have to respond to greater demand for reform that requires double efforts at every level from top to bottom. The opposition party and ill-will circles continue to nurture their idea and action to increase political temperature aimed at splashing negative influence on the procedure of the National Assembly and the Royal Government.

The one-year achievements clearly show capacity of the fifth legislative term Royal Government under the leadership of Samdech Akka Moha Sena Padei Techo Hun Sen, who enjoys love, belief and support of the overwhelming majority of the Cambodian people. Samdech Techo Hun Sen said on 3 August 2014 that the Royal Government of Cambodia sees clearly its tasks

គ្រប់លំដាប់ថ្នាក់ធ្វើការដោះស្រាយ ។ឆ្លងតាមវេទិកាសាធារណៈ រាជរដ្ឋាភិបាលកាន់តែឃើញជាក់ស្តែងអំពីស្ថានភាពពិតនៃការអនុវត្តគោលនយោបាយទាំងចំណុចខ្លាំង និងចំណុចខ្សោយ ហើយបន្តដាក់ចេញនូវវិធានការពង្រឹង ឬកែលម្អបន្ថែមទៀត ។លើមូលដ្ឋានភាពខ្លាំងរបស់រាជរដ្ឋាភិបាលដូច្នេះ ធ្វើឱ្យគណបក្សប្រឆាំងយល់ថា ខ្លួនមិនអាចផ្តួលរំលំរាជរដ្ឋាភិបាលបានទេ អាស្រ័យហេតុនេះ នៅថ្ងៃទី ៨ ខែសីហា ឆ្នាំ ២០១៤ អ្នកតំណាងរាស្ត្រនៃគណបក្សប្រឆាំងបានយល់ព្រមចូលរួមក្នុងសម័យប្រជុំវិសាមញ្ញរបស់រដ្ឋសភា ធ្វើឱ្យវិបត្តិនយោបាយរយៈពេលជិតមួយឆ្នាំដែលពួកគេបានបង្កឡើងត្រូវបានបញ្ចប់ ។ នេះជាឱកាសសម្រាប់ប្រជាជនកម្ពុជាយើងគ្រប់ៗរូបរួបរួមគ្នាដើម្បីការពារសមិទ្ធផលសង្គមជាតិ និងជំរុញការអភិវឌ្ឍប្រទេសតទៅមុខទៀត ។

ទោះជាយ៉ាងនេះក្តី ក៏នៅមានបញ្ហាប្រឈមជាច្រើនទៀតដែលរាជរដ្ឋាភិបាលត្រូវដោះស្រាយ ។ ជាពិសេស ដំណើរការកែទម្រង់លើគ្រប់វិស័យនៅតែមានសំណូមពរធំធេងនៅឡើយ ដែលទាមទារឱ្យមានការខិតខំទ្វេឡើងថែមទៀតនៅគ្រប់លំដាប់ថ្នាក់ តាំងពីលើរហូតដល់ក្រោម ។ទន្ទឹមនេះ គណបក្សប្រឆាំង និងមជ្ឈដ្ឋានអគតិនានា ក៏នៅតែចិញ្ចឹមគំនិត និងសកម្មភាពប៉ុនប៉ងដុតកម្តៅនយោបាយក្នុងសង្គមឱ្យនៅតែក្តៅគំ ដើម្បីជះឥទ្ធិពលអវិជ្ជមានទៅលើដំណើរការរបស់រដ្ឋសភា និងរាជរដ្ឋាភិបាល ។

លទ្ធផលការងាររយៈពេលមួយឆ្នាំនេះ បានឆ្លុះបញ្ចាំងឱ្យឃើញច្បាស់នូវសមត្ថភាពរបស់រាជរដ្ឋាភិបាលនីតិកាលទី ៥ ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ដែលទទួលបាននូវសេចក្តីស្រឡាញ់ ជំនឿ និងការគាំទ្រពីប្រជាជនកម្ពុជាភាគច្រើនលើសលប់ ។សម្តេចតេជោ **ហ៊ុន សែន** បានថ្លែងកាលពីថ្ងៃទី ៣ ខែសីហា ឆ្នាំ ២០១៤ ថា រាជរដ្ឋាភិបាលកម្ពុជាឃើញច្បាស់ណាស់នូវភារកិច្ចចាំបាច់ក្នុងការថែរក្សាសន្តិភាព ស្ថិរភាព ការអភិវឌ្ឍ និងវិបុលភាពសង្គម សេដ្ឋកិច្ច ដែលប្រជាពលរដ្ឋត្រូវការមិនអាចខ្វះបានឡើយ ។ បន្ថែមពីលើនេះ ក្នុងពេលបច្ចុប្បន្នប្រជាពលរដ្ឋជាទីស្រឡាញ់របស់យើងនៅចង់បានលើសពីនេះទៀត ដូចជាចង់ឃើញរាជរដ្ឋាភិបាលខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លាបន្ថែមទៀត ដើម្បីបន្តបង្កើនឱកាសការងារ ចង់ទទួលបានការសិក្សាអប់រំប្រសើរជាងមុន ចង់បានអត្រានៃភាពក្រីក្រ និងវិសមភាពសង្គមកាន់តែរួមតូចទៅៗ ។ រាជរដ្ឋាភិបាលនឹងបន្តធ្វើអ្វីៗគ្រប់យ៉ាងដើម្បីប្រជាជន ។ នេះជាទស្សនវិស័យដ៏ថ្លៃថ្លារបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ដែលយើងទាំងអស់គ្នាគប្បីចូលរួមអនុវត្តយ៉ាងសកម្ម ឱ្យសម្រេចបានសមិទ្ធផលធំៗថ្មីទៀតនៅក្នុងឆ្នាំទី ២ នៃនីតិកាលទី ៥ នេះ ។/

ទស្សនាវដ្តីប្រជាជន

in maintaining peace, stability, development and socio-economic prosperity indispensably required by our people. Our beloved people would like to see the Royal Government makes stronger efforts to continue increasing job opportunity and better education, ensure lower rate of poverty and smaller gap of social inequality. The Royal Government will do what it can for the people. This is a brilliant point of view of the head of the Royal Government of Cambodia. We all should take part actively in fulfilling and realizing further achievements in the second year of the fifth legislative term./.

*THE PRACHEACHUN MAGAZINE*




សូមគោរពឯកឧត្តម លោកជំទាវ និងប្រិយមិត្តអ្នកអានជាទីគោរព
សូមចូលមក Facebook Page : Pracheachun Magazine-ទស្សនាវដ្ដីប្រជាជន
ហើយចុច Like និង Share ដើម្បីទទួលបានព័ត៌មានសំខាន់ៗប្រចាំថ្ងៃ ព្រមទាំងផ្តល់ទស្សនៈ ឬ មតិផ្សេងៗ

# សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រារព្ធពិធីបុណ្យកាន់បិណ្ឌវេនទី១ និងប្រគេនទេយ្យទានព្រះសង្ឃចំនួន ៨៤ វត្ត





*សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រារព្ធពិធីបុណ្យកាន់បិណ្ឌវេនទី ១ និងប្រគេនទេយ្យទាន ព្រមទាំងរាប់បាត្រប្រគេនព្រះសង្ឃចំនួន ៨៤ អង្គ*

ព្រឹកថ្ងៃ ១ រោច ខែភទ្របទ ត្រូវនឹងថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ២០១៤ នៅភូមិគ្រឹះចំការមន សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា បានប្រារព្ធពិធីបុណ្យកាន់បិណ្ឌវេនទី ១ និងប្រគេនទេយ្យទានព្រះសង្ឃនៅវត្តចំនួន ៨៤ និងរាប់បាត្រព្រះ សង្ឃចំនួន ៨៤ អង្គ ដើម្បីចូលរួមចម្រើននូវជោគជ័យសិរីមង្គល ព្រមទាំងឧទ្ទិសកុសល និងរំលឹកដល់វិញ្ញាណក្ខន្ធលោកជំទាវ **ឡែម ស៊ឿន** ដែលបានធ្វើមរណកាលទៅកាន់លោកខាងមុខផងដែរ ។

សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងលោកជំទាវ ឯកឧត្តម **សាយ ឈុំ** អនុប្រធានទី ១ ព្រឹទ្ធសភា ឯកឧត្តម **ខួន ញ៉ិល** អនុប្រធានទី ២ រដ្ឋសភា លោកជំទាវឧប-នាយករដ្ឋមន្ត្រី **ម៉ែន សំអន** ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **យឹម ឆៃលី** ព្រមទាំងសមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា ថ្នាក់ដឹកនាំមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងញាតិមិត្ត ឧបាសក ឧបាសិកា ជិតឆ្ងាយជាច្រើននាក់ក៏បានអញ្ជើញចូលរួមពិធីកាន់បិណ្ឌនេះផងដែរ ។

ក្នុងពិធីនោះ សម្តេចប្រធានព្រឹទ្ធសភាបានប្រគេនដល់ព្រះសង្ឃនៅក្នុងវត្តទាំង ៨៤ នោះ ក្នុងវត្តនីមួយៗទទួលបាននូវបច្ច័យ ២ លានរៀល អង្ករ ៥០ គីឡូក្រាម ផ្លែឈើ ១ កន្ត្រក មី ទឹកដោះគោ ត្រីខស្ករស ទឹក ក្រូច ទឹកសុទ្ធ និងសម្ភារៈផ្សេងៗមួយចំនួនបន្ថែមទៀត ព្រមទាំងផ្តល់អំណោយដល់យាយជី តាជី ចំនួន ៦០០ នាក់ ផងដែរ ។

តាមប្រវត្តិរបស់ពិធីបុណ្យនេះបានឱ្យដឹងថា ដោយហេតុពុទ្ធសាសនិកមានការមមាញឹកចំពោះកិច្ចការប្រចាំថ្ងៃ និងដើម្បីធានាថា



ព្រះសង្ឃត្រូវបានផ្គត់ផ្គង់ចង្ហាន់ជាទៀងទាត់នោះ ទើបពុទ្ធបរិស័ទប្រជាពលរដ្ឋដែលកាន់ព្រះពុទ្ធសាសនាចែកគ្នាជាក្រុមៗដាក់វេនគ្នាយកទេយ្យទានទៅប្រគេនព្រះសង្ឃរយៈពេល ១៤ ថ្ងៃ ចាប់ពី ថ្ងៃ ១ រោច ដល់ថ្ងៃ ១៤ រោច ខែភទ្របទ ហើយត្រូវបានគេឱ្យឈ្មោះថាជាវេនទី ១ ដល់វេនទី ១៤ ។

ចំណែកថ្ងៃ ១៥ រោច ដែលជាថ្ងៃចុងក្រោយនោះ ពុទ្ធសាសនិកបានប្រមូលគ្នាមកពីគ្រប់វេនទាំងអស់ ហើយមកជួបជុំគ្នាធ្វើទានចំពោះសង្ឃជាមួយគ្នា ដើម្បីបញ្ចប់បុណ្យកាន់បិណ្ឌដែលជាថ្ងៃចុងក្រោយ សម្រាប់ពុទ្ធសាសនិកហៅថា បុណ្យភ្ជុំបិណ្ឌ ឬថ្ងៃភ្ជុំបិណ្ឌ ។ ពុទ្ធបរិស័ទ និងប្រជាពុទ្ធសាសនិកទាំងអស់ដែលមានសទ្ធាជ្រះថ្លាក្នុងការរួមចំណែកប្រគេននូវទេយ្យទានដល់ព្រះសង្ឃក្នុងពិធីបុណ្យកាន់បិណ្ឌ ឬបុណ្យភ្ជុំបិណ្ឌ នឹងទទួលបានអានិសង្សយ៉ាងច្រើន ។/

# សម្ដេចតេជោ ហ៊ុន សែន អញ្ជើញចូលរួមពិធីតាំងពិព័រណ៍អាស៊ាន-ចិន នៅទីក្រុងណាននីង




*សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ទស្សនាការតាំងពិព័រណ៍អាស៊ាន-ចិនលើកទី ១១ នៅទីក្រុងណាននីងខេត្តក្វាងស៊ី សាធារណរដ្ឋប្រជាមានិតចិន*

ថ្ងៃទី ១៥-១៦ ខែកញ្ញា ឆ្នាំ២០១៤ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានអញ្ជើញទៅចូលរួមពិធីតាំងពិព័រណ៍អាស៊ាន-ចិនលើកទី ១១ នៅទីក្រុងណាននីងខេត្តក្វាងស៊ី សាធារណរដ្ឋប្រជាមានិតចិន ។

ក្នុងឱកាសស្នាក់នៅទីនោះ សម្ដេចតេជោ **ហ៊ុន សែន** បានជួបសំណេះសំណាលជាមួយឯកឧត្ដម **ចាង កាវលី** Zhang Gaoli ឧបនាយក-រដ្ឋមន្ត្រីទី ១ នៃរដ្ឋាភិបាលចិន ។ សម្ដេចតេជោ **ហ៊ុន សែន** បានលើកឡើងពីគម្រោងរបស់កម្ពុជាក្នុងការប្រើប្រាស់ជំនួយឥតសំណងចំនួន ៧00 លានយ័ន និងកម្ចីឥតការប្រាក់ចំនួន ២00 លានយ័ន ដែលសម្ដេច និងឯកឧត្ដម **ស៊ី ជីនពីង** ប្រធានាធិបតីចិនបានពិភាក្សាគ្នាក្នុងដំណើរទស្សនកិច្ចរបស់សម្ដេចទៅកាន់ទីក្រុងសៀងហៃ កាលពីខែឧសភាកន្លងទៅ ។ កម្ពុជានឹងប្រើប្រាស់ជំនួយទាំងនោះក្នុងការកសាងអគារពហុកីឡាដ្ឋានជាតិអូឡាំ-ពិកថ្មី កសាងអគាររដ្ឋបាលសាលាខេត្តត្បូងឃ្មុំ កសាងមជ្ឈមណ្ឌលការពារជំងឺឆ្លង និងបញ្ហាជាក់ស្ដែងដទៃទៀតដែលកម្ពុជាកំពុងត្រូវការជាបន្ទាន់ ។ សម្ដេចតេជោ **ហ៊ុន សែន** បានស្នើដល់ភាគីចិនបន្តរក្សានូវអត្រាការប្រាក់ ១,២៥% ក្នុងមួយឆ្នាំសម្រាប់រាល់កម្ចីរបស់កម្ពុជា ។ សម្ដេចតេជោបានស្នើដល់ភាគីចិននូវឥណទានដល់កម្ពុជាក្នុងការពង្រឹងវិស័យគមនា-គមន៍ និងសន្តិសុខជាតិសម្រាប់កម្ពុជា និងបានស្នើដល់ភាគីចិនជួយសាងសង់ឃ្លាំងរក្សាស្ដុកស្រូវ អង្ករដល់កម្ពុជាសំដៅធ្វើយ៉ាងណាឱ្យកម្ពុជាឈានទៅសម្រេចបាននូវការ នាំចេញអង្ករឱ្យបាន ១ លានតោន នៅឆ្នាំ ២០១៥ ខាងមុខ ។ សម្ដេចតេជោក៏បានស្នើដល់ភាគីចិនជួយទិញកសិផលមួយចំនួនដូចជា ពោត សណ្ដែកសៀង កៅស៊ូ អង្ករ ចេក ស្វាយ ពិសេសជួយជំរុញការនាំចូលមកកាន់ប្រទេសចិនដោយគ្មានកូតាកំណត់ចំនួន និងដោយគ្មានការបង់ពន្ធលើការនាំចូល ។

ឯកឧត្ដម **ចាង កាវលី** Zhang Gaoli បានគាំទ្រនិងស្វាគមន៍ចំពោះការនាំចូល និងទិញនូវកសិផលបន្ថែមពីប្រទេសកម្ពុជាដោយស្នើឱ្យក្រសួងពាណិជ្ជកម្ម និងគយរបស់ប្រទេសចិនធ្វើការពិភាក្សា ដើម្បីឈានទៅរកការទិញកសិផលពីកម្ពុជា ។ ឯកឧត្ដមក៏បានបង្ហាញនូវការគាំទ្រចំពោះគម្រោងនៃការប្រើប្រាស់ជំនួយឥតសំណង និងកម្ចីគ្មានការប្រាក់នៅប្រទេសកម្ពុជាក្នុងការកសាងអគារពហុកីឡាដ្ឋានជាតិអូឡាំពិកថ្មី អគាររដ្ឋបាលសាលាខេត្តត្បូងឃ្មុំ និងមជ្ឈមណ្ឌលការពារជំងឺឆ្លងដែលជាបញ្ហាជាក់ស្ដែងរបស់កម្ពុជា ។ ឯកឧត្ដម Zhang Gaoli បានបញ្ជាក់យ៉ាងច្បាស់ថា កម្ពុជា-ចិន គឺជាមិត្តចាស់ ក្នុងនោះ សម្ដេចតេជោគឺជាមិត្តដ៏ល្អរបស់ប្រទេសចិន និងប្រជាជនចិន ។

សម្ដេចតេជោ **ហ៊ុន សែន** ក៏បានជួបពិភាក្សាជាមួយឯកឧត្ដម Chen Wu អភិបាលតំបន់ស្វយ័តក្វាងស៊ី ។ សម្ដេចបានសម្ដែងការគាំទ្រចំពោះការតាំងពិព័រណ៍អាស៊ាន-ចិន ដែលបានបង្ហាញថា នយោបាយចិនគាំទ្រអាស៊ាន និងធ្វើយ៉ាងណាឱ្យអាស៊ានមានការអភិវឌ្ឍទៅមុខទៀត ។ ការតាំងពិព័រណ៍អាស៊ាន-ចិននេះ បានចាប់កំណើតឡើងក្នុងពេលកម្ពុជាគឺជាប្រទេសសម្របសម្រួលអាស៊ាន-ចិនក្នុងឆ្នាំ ២០០៣ និងម្យ៉ាងទៀត ដោយសារទីក្រុងណាននីងដែលជាកន្លែងតាំងពិព័រណ៍ប្រចាំឆ្នាំ គឺជាទីកដីទី ១ នៅប្រទេសចិនដែលសម្ដេចបានធ្វើទស្សនកិច្ចមុនគេក្នុងទសវត្សឆ្នាំ ៨0 ដើម្បីរៀបចំSNC ។សម្ដេចតេជោបានស្នើធ្វើយ៉ាងណាឱ្យទំហំពាណិជ្ជកម្មរវាងប្រទេសកម្ពុជា និងខេត្តក្វាងស៊ី កើនឡើងដល់ ២00 លានដុល្លារអាមេរិកនៅឆ្នាំ ២០១៧ ។ ឯកឧត្ដម Chen Wu បានថ្លែងថា ចំពោះកិច្ចសហការពាណិជ្ជកម្មរវាងខេត្តក្វាងស៊ី និងកម្ពុជា គឺមានការកើនឡើងដែលពីមុនមានត្រឹមតែ ២0 លានដុល្លារអាមេរិក ក្នុង ១ ឆ្នាំ ឥឡូវកើនឡើងជាង ៦0% ។ ឯកឧត្ដមតែងតែជំរុញអ្នកវិនិយោគចិនឱ្យមកបណ្ដាក់ទុនរកស៊ី

នៅកម្ពុជា ពិសេសលើវិស័យកសិកម្ម។ កន្លងមក ខេត្តក្វាងស៊ីក៏បានផ្ដល់អាហារូបករណ៍ដល់និស្សិតកម្ពុជា ហើយក្នុងឆ្នាំនេះខេត្តក្វាងស៊ីក៏បានបញ្ជូននិស្សិតអាហារូបករណ៍ចិនជាង ១០០ នាក់ មកកម្ពុជាផងដែរ។ ក្នុងជំនួបនេះ អភិបាលខេត្តក្វាងស៊ីបានផ្ដល់គ្រឿងចក្រកសិកម្មមួយចំនួនដល់សម្ដេចតេជោ **ហ៊ុន សែន** ដែលសម្ដេចតែងតែគាំទ្រដល់ការតាំងពិព័រណ៍អាស៊ាន-ចិន។

ក្នុងឱកាសស្នាក់នៅទីក្រុងណាននីងនេះដែរ សម្ដេចតេជោ **ហ៊ុន សែន** បានអនុញ្ញាតឱ្យឯកឧត្ដម Pham Binh Minh ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេសនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចូលជួបសម្ដែងការគួរសម និងពិភាក្សាការងារ។ សម្ដេចតេជោ និងឯក-ឧត្ដម Pham Binh Minh បានវាយតម្លៃខ្ពស់ និងកោតសរសើរចំពោះលទ្ធផលនៃកិច្ចសហប្រតិបត្តិការរវាងប្រទេសយើងទាំងពីរ កម្ពុជា-វៀតណាម ដែលទទួលបានការរីកចម្រើនយ៉ាងឆាប់រហ័សពីមួយថ្ងៃទៅមួយថ្ងៃ ព្រមទាំងបានសន្យារួមគ្នាថានឹងខិតខំជំរុញទំនាក់ទំនង និងកិច្ចសហប្រតិ-បត្តិការនៃប្រទេសទាំងពីរឱ្យកាន់តែរីកចម្រើនទ្វេឡើងថែមទៀតពិសេសការជំរុញកិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច ការវិនិយោគ ទេសចរណ៍ សំដៅធ្វើយ៉ាងណាឱ្យទំហំពាណិជ្ជកម្មនៃប្រទេសទាំងពីរកើនដល់ ៥០០០ លានដុល្លារនៅឆ្នាំ២០១៥ខាងមុខ។ ព្រមជាមួយនេះក៏ប្ដេជ្ញារួមគ្នាក្នុងការបោះបង្គោលព្រំដែននៃប្រទេសទាំងពីរឱ្យបានចប់សព្វគ្រប់តាមអ្វីដែលភាគីទាំងពីរបានព្រមព្រៀងគ្នារួចមកហើយនោះ។

នៅថ្ងៃទី ១៦ ខែកញ្ញា ពិព័រណ៍អាស៊ាន-ចិនលើកទី ១១ បានចាប់ផ្ដើមដោយខ្លឹមសារនៃពិព័រណ៍នេះផ្ដោតសំខាន់លើបញ្ហាចំនួន ៦ គឺ ទី១-ការខិតខំប្រឹងប្រែងធ្វើការងាររួមជាមួយគ្នា ដើម្បីធ្វើយ៉ាងណាកសាងជំនឿទុកចិត្តផ្នែកនយោបាយ ទី២-ធ្វើឱ្យប្រសើរជាបន្តទៀតក្នុងការជំរុញពាណិជ្ជកម្ម និងវិនិយោគរវាងអាស៊ាន-ចិន ទី៣-ពង្រឹងការតភ្ជាប់រវាងអាស៊ាន-ចិន ទី៤-ជំរុញកិច្ចសហការលើវិស័យសមុទ្រ ទី៥-ជំរុញកិច្ចសហការតំបន់ទន្លេមេគង្គ និងទី៦-លើកតម្កើងទំនាក់ទំនងរវាងប្រជាជន និងប្រជាជន។ ក្នុងឆ្នាំនេះចិនបានផ្ដល់អាហារូបករណ៍ចំនួន ១៥ ០០០ នាក់ដល់បណ្ដាប្រទេសអាស៊ាន ហើយឆ្នាំនេះក៏ត្រូវបានចាត់ទុកថាជាឆ្នាំនៃការផ្លាស់ប្ដូរវប្បធម៌ អាស៊ាន-ចិនផងដែរ។ ថ្លែងនៅក្នុងពិធីតាំងពិព័រណ៍នោះ សម្ដេចតេជោ **ហ៊ុន សែន** បានបញ្ជាក់ថាពិព័រណ៍ អាស៊ាន-ចិនកាន់តែមានលក្ខណៈទូលំទូលាយពីមួយឆ្នាំទៅមួយឆ្នាំ ហើយកំពុងក្លាយជាកាតាលិករដ៏សំខាន់សម្រាប់គាំទ្រដល់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន ព្រមទាំងផ្ដល់នូវកាលានុវត្តភាពលើការបង្កើនកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍសម្រាប់ភាគីទាំង ២ ក្នុងបរិការណ៍នៃនិម្មាបនកម្មបែបថ្មីរបស់ពិភព-លោក។ ជោគជ័យនៃពិព័រណ៍ អាស៊ាន-ចិន និងកិច្ចប្រជុំកំពូលធុរកិច្ច និងវិនិយោគអាស៊ាន-ចិននាពេលកន្លងមកនេះពិតជាបានឆ្លុះបញ្ចាំងអំពីឆន្ទៈដ៏មោះមុតរបស់ភាគីទាំង ២ ក្នុងការបន្តពង្រឹងកិច្ចសហប្រតិបត្តិការលើ



*សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** អនុញ្ញាតឱ្យ ឯកឧត្ដម Pham Binh Minh ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេសនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចូលជួប សម្ដែងការគួរសម និងពិភាក្សាការងារ*

គ្រប់វិស័យ ពិសេសវិស័យធុរកិច្ច ការពន្លឿនកិច្ចការសមាហរណកម្មក្នុងតំបន់ និងការចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍ និងពង្រឹងភាពជាដៃគូយុទ្ធសាស្ត្រអាស៊ាន-ចិន។ សម្ដេចតេជោបានថ្លែងទៀតថា ពិព័រណ៍អា-ស៊ាន-ចិន ដែលត្រូវបានរៀបចំឡើងជារៀងរាល់ឆ្នាំនេះ មិនត្រឹមតែផ្ដល់ឱកាសដល់ប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល ថ្នាក់ដឹកនាំសហគ្រាសរបស់ចិននិងប្រទេសជាសមាជិកទាំងអស់របស់អាស៊ានអាចពិភាក្សា និងផ្លាស់ប្ដូរគំនិតគ្នាដើម្បីពង្រឹង និងពង្រីកវិស័យពាណិជ្ជកម្ម និងវិនិយោគប៉ុណ្ណោះទេ ប៉ុន្តែក៏ជាវេទិកាបង្កើននូវកិច្ចសហប្រតិបត្តិការទ្វេភាគីលើគ្រប់វិស័យផងដែរ។ ក្នុងអំឡុងពេលនីមួយៗនៃពិធីតាំងពិព័រណ៍អាស៊ាន-ចិន និងកិច្ចប្រជុំកំពូលដទៃផ្សេងទៀត ដូចជាកិច្ចប្រជុំកំពូលធុរកិច្ច និងវិនិយោគអាស៊ាន-ចិន កិច្ចប្រជុំទ្វេភាគីវេទិកាជំរុញពាណិជ្ជកម្ម និងវិនិយោគ ព្រមទាំងជំនួបរវាងធុរជនដែលត្រូវបានរៀបចំឡើងដោយទៀងទាត់នោះ គឺបានប្រព្រឹត្តទៅនៅក្នុងគោលដៅបង្កើនកាលានុវត្តភាពទំនាក់ទំនងគ្នារវាងគណៈប្រតិភូធុរកិច្ចគ្រប់ប្រទេសទាំងអស់ ។ សម្ដេចតេជោបានសង្កត់ធ្ងន់ទៅលើចំណុចសំខាន់មួយចំនួនដែលត្រូវបានចាត់ទុកថា កិច្ចសហប្រតិបត្តិការអាស៊ាន-ចិន មានកំណើនឡើងយ៉ាងឆាប់រហ័ស ជាពិសេសក្រោយការបង្កើតតំបន់ទីផ្សារសេរី អាស៊ាន-ចិន ក្នុងឆ្នាំ ២០១០។

គួរបញ្ជាក់ថា ក្នុងការតាំងពិព័រណ៍អាស៊ាន-ចិនលើកទី ១១ នេះ មានក្រុមហ៊ុនចូលរួមប្រមាណជាង ២ ម៉ឺន។ ប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល ថ្នាក់ដឹកនាំនៃប្រទេសអាស៊ានបានគាំទ្រចំពោះការយកចិត្តទុកដាក់របស់ប្រទេសចិន ដែលបានផ្ដោតការយកចិត្តទុកដាក់ធ្វើយ៉ាងណាឱ្យតំបន់ឧស្សាហកម្មអាស៊ាន-ចិនមានការរីកចម្រើនជាងមុន ការបង្កើតធនាគារអាស៊ីសម្រាប់ហេដ្ឋារចនាសម្ព័ន្ធការវិនិយោគនិងការកសាងវិថីសូត្រសមុទ្រសម្រាប់ផ្ដល់ផលប្រយោជន៍ដល់បណ្ដាប្រទេសដែលបានចូលរួមផងដែរ។/

# សម្តេចតេជោ និងការគាំពារ និងអភិវឌ្ឍន៍កុមារតូច ការជំរុញកំណែទម្រង់វិស័យអប់រំ ការប្រយុទ្ធប្រឆាំងអំពើពុករលួយ និងការអនុវត្តប្រព័ន្ធបៀវត្សថ្មីនៅឆ្នាំ ២០១៥



*សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** អញ្ជើញជាអធិបតីក្នុងពិធីប្រកាសផ្សព្វផ្សាយគោលនយោបាយជាតិ និងផែនការសកម្មភាពជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច ឆ្នាំ ២០១៤-២០១៨*

ក្នុងខែកញ្ញាកន្លងទៅនេះសម្តេចអគ្គមហាសេនាបតីតេជោ**ហ៊ុន សែន** បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីមួយចំនួនដែលទាក់ទងទៅនឹងទិសដៅ ផែនការអភិវឌ្ឍកម្ពុជា ។ ក្នុងពិធីទាំងនេះ សម្តេចបានលើកឡើងអំពីការកត់សម្គាល់សំខាន់ៗ និងផ្តល់នូវអនុសាសន៍មួយចំនួនដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងកំណែទម្រង់របស់រដ្ឋាភិបាល ។

◆ ថ្ងៃទី ១ ខែកញ្ញា ឆ្នាំ ២០១៤ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានចូលរួមក្នុងពិធីប្រកាសផ្សព្វផ្សាយគោលនយោបាយជាតិ និងផែនការសកម្មភាពជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច ឆ្នាំ២០១៤-២០១៨ នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ ។

នាពេលនោះ សម្តេចតេជោបានលើកឡើងអំពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជាចំពោះកុមារតូច ។សម្តេចបញ្ជាក់ថាកិច្ចការនេះមិនមែនជាកិច្ចការថ្មីនោះទេ គឺរាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមធ្វើតាំងពីឆ្នាំ១៩៧៩ មកដោយបានធ្វើឱ្យកុមារកម្ពុជាទទួលបានការគាំទ្រ ទទួលបានការការពារ បីបាច់ថែរក្សា ហើយសិទ្ធិកុមារត្រូវបានលើកតម្កើងជាបន្តបន្ទាប់ ។ ការដាក់ឱ្យអនុវត្តគោលនយោបាយជាតិ និងផែនការសកម្មភាពជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូចឆ្នាំ ២០១៤-២០១៨ គឺជាការបង្ហាញពីការគិតគូរ និងយកចិត្តទុកដាក់ខ្ពស់ជាប់ជាប្រចាំចំពោះវិស័យកុមារនៅកម្ពុជា ។

ក្នុងពិធីនេះដែរ សម្តេចបានជំរុញឱ្យគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍន៍កុមារតូច និងក្រសួងស្ថាប័នពាក់ព័ន្ធ ផ្តោតអាទិភាពលើកិច្ចការមួយចំនួន ដូចជា ទី១. ត្រូវយកចិត្តទុកដាក់ជាប់ជាប្រចាំដល់កុមារតូចទាំងអស់ ជាពិសេសកុមារតូចរងគ្រោះ កុមារតូចងាយរងគ្រោះ កុមារតូចជនជាតិភាគតិច និងពិសេសបំផុតនោះគឺកុមារតូច មានពិការភាព តាមរយៈការពង្រឹង និងពង្រីកយន្តការដែលមានស្រាប់ក្នុងការចិញ្ចឹមបីបាច់ថែរក្សា ការផ្តល់អាហារូបត្ថម្ភ ការថែទាំសុខភាព និងការអប់រំ ព្រមទាំងធ្វើឱ្យសកម្មលើការទប់ស្កាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ធ្វើឱ្យកុមារបានរស់ដោយសុវត្ថិភាព មិនមានការប្រឈមទៅនឹងអំពើជួញដូរ ឬការរំលោភបំពាននានា ។ ទី២. ការលើកកម្ពស់សេវាគាំពារ និងអភិវឌ្ឍន៍កុមារតូចគ្រប់រូបភាព ត្រូវគិតគូរឱ្យបានច្រើនពីគុណភាពនិងចីរភាពនៃសកម្មភាព ។ ទី៣. ត្រូវបង្កើនកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍន៍កុមារតូច ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានានៅក្នុងស្មារតីគាំទ្របំពេញឱ្យគ្នាទៅវិញទៅមកដែលសកម្មភាពនេះជារូបមន្តដ៏ស័ក្តិសិទ្ធិក្នុងការឈានទៅសម្រេចបាននូវជោគជ័យសម្រាប់ទាំងអស់គ្នា និងទី៤.ត្រូវរៀបចំបង្កើតកម្មវិធីតាមដានត្រួត ពិនិត្យវាយតម្លៃនិងយន្តការផ្តល់របាយការណ៍មួយសមស្របដើម្បីធានាប្រសិទ្ធ-ភាពក្នុងការអនុវត្តគោលនយោបាយជាតិ និងផែនការសកម្មភាព ជាតិនេះ និងបន្តកែលម្អគោលនយោបាយ កម្មវិធីនានាក្នុងគោលបំណងអនុវត្តសកម្មភាព និងអន្តរាគមន៍នៅក្នុងវិស័យនេះឱ្យរឹតតែមានប្រសិទ្ធភាពខ្ពស់ថែមទៀត ។

សម្តេចតេជោក៏បានបញ្ជាក់ជាថ្មីម្តងទៀតទាក់ទងទៅនឹងការជំរុញ និងគាំទ្រកំណែទម្រង់វិស័យអប់រំ ។ សម្តេចបញ្ជាក់ថា កំណែទម្រង់របស់ក្រសួងអប់រំយុវជន និងកីឡាត្រូវបន្តធ្វើបន្ថែមទៀត ដោយមិនត្រឹមតែមធ្យមសិក្សាទុតិយភូមិទេ តែត្រូវធ្វើតាំងពីបឋមសិក្សាមក ដើម្បីផលិតចេញនូវធនធានមនុស្សមួយប្រកបដោយគុណភាពដែលចេញពីសាលាមកអាចធ្វើការងារបាន និងមានការទទួលស្គាល់ ។

សម្តេចបានមានប្រសាសន៍ថា "មានទស្សនៈខ្លះបានលើកឡើងថា បើតឹងម្លឹងៗធ្វើម៉េចទៅ? បើតឹងម្លឹងៗ មានតែប្រឹងទេដើម្បីជាប់" ។ គ្មានវិធីដោះស្រាយដោយការសូកប៉ាន់ ឬការធ្វើកំណែដោយការបន្ធូរបន្ថយនោះទេ គឺត្រូវតែមានការរឹតបន្តឹងបន្ថែមទៀត បើមិនដូច្នោះទេយើងមិនអាចរកបាននូវធនធានមនុស្សមានគុណភាពដែលចេញមកអាចធ្វើការងារបាននោះទេ ។

នៅក្នុងឱកាសនោះដែរ សម្តេចនាយករដ្ឋមន្ត្រីក៏បានថ្លែងសរសើរដល់ការខិតខំរបស់ក្រសួងអប់រំយុវជន និងកីឡា ដែលបានយកចិត្តទុកដាក់ក្នុងការធ្វើកំណែទម្រង់ក្នុងប្រព័ន្ធអប់រំ ដែលជាកំណែទម្រង់ដ៏ស៊ីជម្រៅមួយ ហើយតាមរយៈការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំនេះសិស្សជាប់បានតែជាង ២៥%ប៉ុណ្ណោះ ខុសពីឆ្នាំមុនៗដែលមានសិស្សជាប់ដល់ទៅជាង ៨០%នោះ ។ ក្នុងបញ្ហានេះសម្តេចថ្លែងថា កំណែទម្រង់បានចាប់ផ្តើមហើយ ។ កំណែទម្រង់នេះមិនត្រឹមធ្វើតែនៅមធ្យមសិក្សាទុតិយភូមិទេ ប៉ុន្តែក៏នឹងធ្វើនៅមធ្យមសិក្សា បឋមភូមិផងដែរ ។ គឺចាប់ផ្តើមពីបឋមសិក្សា ។ គឺត្រូវធ្វើឱ្យសិស្សខិតខំរៀនតាំងពីតូចមកមិនត្រូវមកប្រឹងនៅថ្នាក់ទី ១២ នោះទេ ។

សម្តេចតេជោក៏បានអំពាវនាវដល់មាតាបិតាអាណាព្យាបាល និងសិស្សានុសិស្សទាំងអស់ឱ្យយល់ និងចូលរួមខិតខំទាំងអស់គ្នាក្នុងកំណែ

ទម្រង់នេះ ជាពិសេស មាតាបិតា អាណាព្យាបាលគប្បីជំរុញកូនចៅឱ្យខិតខំរៀនសូត្រចាប់តាំងពីថ្នាក់បឋមសិក្សាឡើងទៅពីព្រោះមិនមានការដោះស្រាយបញ្ហាដោយការសូកប៉ាន់ ឬការបន្ធូរបន្ថយរបស់គ្រូបង្រៀនទៀតទេ។

សម្ដេចបានហៅកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការប្រឡងឆ្នាំ ២០១៤ ជាការចម្រាញ់ទឹក ១០ យកទឹក ១។

◆ ថ្ងៃទី ៣ ខែកញ្ញា សម្ដេចតេជោបានអញ្ជើញចូលរួមបើកសន្និសីទប្រចាំតំបន់លើកទី ៨ ស្ដីពីការប្រឆាំងអំពើពុករលួយនៃគំនិតផ្ដួចផ្ដើមប្រឆាំងអំពើពុករលួយសម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិកដែលបានប្រារព្ធធ្វើនៅសណ្ឋាគារអាំងទែរកុងទីណង់តាល់រាជធានីភ្នំពេញ។

ខណៈនោះ សម្ដេចនាយករដ្ឋមន្ត្រីបានរិះគន់ចំពោះការផ្ដល់ចំណាត់ថ្នាក់របស់បណ្ដាស្ថាប័នអន្តរជាតិមួយចំនួនថាការផ្ដល់ចំណាត់ថ្នាក់នេះប្រទេសខ្លះប៉ះពាល់មិនបានទេ។ប្រទេសនោះ បើគេទម្លាក់ពីអេ(A) មកប៊ី (B) ឬពីអេមួយ(A1) មកអេពីរ(A2) គឺអត់បានទេប្រតិកម្មភ្លាម។ក៏ប៉ុន្តែប្រទេសទាំងនោះគាត់ដើរទៅដាក់ពិន្ទុឱ្យប្រទេសគេវិញ។ គាត់ដាក់ស្រេចតែចិត្ត។ សម្ដេចបានបន្តដោយលើកជាសំណួរថា ប្រសិនបើគ្រាន់តែរឿងដាក់ពិន្ទុចំណាត់ថ្នាក់ប្រទេសពាក់ព័ន្ធទៅបញ្ហានយោបាយដែរនោះ តើគេប្រយុទ្ធប្រឆាំងអំពើពុករលួយបែបណាទៅ?។សម្ដេចបញ្ជាក់ថា ទាំងអស់គឺត្រូវចាប់ផ្ដើមពីការពិតមួយទើបរកឃើញបញ្ហា។

សម្ដេចនាយករដ្ឋមន្ត្រីកម្ពុជាក៏បានស្នើទៅកាន់លោកស្រី Clare Wee ប្រធានការិយាល័យប្រឆាំងអំពើ ពុករលួយ និងសុចរិតភាពនៃធនាគារអភិវឌ្ឍន៍អាស៊ី(ADB)ដែលមានវត្តមានក្នុងកិច្ចប្រជុំនេះដែរឱ្យពិនិត្យមើលកិច្ចសហការគ្នាជាមួយធនាគារពិភពលោក (WB) និងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) រកវិធីបែបណាក្នុងការដាក់ពិន្ទុចំណាត់ថ្នាក់ប្រទេសឱ្យមានស្តង់ដារជាអន្តរជាតិ ព្រោះការដាក់ចំណាត់ថ្នាក់ប្រទេសកន្លងទៅមានពាក់ព័ន្ធបញ្ហានយោបាយទៅជាមួយ។ បើស្អប់រដ្ឋាភិបាលប្រទេសហ្នឹងគឺដាក់ពិន្ទុ ឬចំណាត់ថ្នាក់ឱ្យធ្ងន់តែម្ដង។ សម្លាប់គេដោយនយោបាយតែម្ដង។ មានពេលខ្លះវាហួសព្រំដែនរបស់ខ្លួនធ្វើជាអង្គការអន្តរជាតិមួយ។

ទាក់ទងទៅនឹងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយដដែលនេះដែរ សម្ដេចតេជោបានបញ្ជាក់ថា "វិស័យឯកជន និងវិស័យសាធារណៈត្រូវតែសហការគ្នា។ អ្នកណាជាអ្នកសូកប៉ាន់ពិតប្រាកដ គឺវិស័យឯកជនជាអ្នកសូក។ បើវិស័យឯកជនមិនសូកប៉ាន់ទេ មន្ត្រីរាជការនោះបានលុយពីណា? គឺវាមានការពាក់ព័ន្ធបែបនេះ ទើបទាមទារឱ្យមានការចូលរួមពីវិស័យឯកជនចូលរួមធ្វើសហប្រតិបត្តិការ ក្នុងនោះគឺយកគោលការណ៍មិនសូកប៉ាន់ការសុំធ្វើការវិនិយោគដោយត្រឹមត្រូវ" ។ ក្នុងវិស័យឯកជនខ្លួនឯងក៏ត្រូវមានភាពច្បាស់លាស់ចំពោះបញ្ហានេះ ។ វិស័យឯកជនខ្លួនឯងត្រូវមានសុចរិតភាពផង និងតម្លាភាពផង ព្រោះមានពេលខ្លះមន្ត្រីរាជរដ្ឋាភិបាលគ្រាន់តែជាអ្នកដែលត្រូវទទួលការស្ដីបន្ទោស ប៉ុន្តែពួកគេមិនបានទទួលនូវសំណូកទេ។ ផ្ទុយទៅវិញបុគ្គលិកក្រុមហ៊ុនតែងបានប្រាប់ទៅថៅកែរបស់ខ្លួនវិញថា គេត្រូវការលុយប៉ុណ្ណេះសូកនៅកន្លែងនេះ ឬកន្លែងនោះ។ មន្ត្រីរាជរដ្ឋាភិបាល បានត្រឹមខូចឈ្មោះ ចំណែកអ្នកដែលយកលុយមកសូកនោះជាអ្នកដែលបានយកលុយពីក្រុមហ៊ុនដាក់ក្នុងហោប៉ៅរបស់ខ្លួន។ សម្ដេចបានស្នើសុំឱ្យក្រុមហ៊ុននិមួយៗសម្អាតផ្ទៃក្នុងរបស់ខ្លួន។

សម្ដេចបានបន្តថា តួអង្គមួយចំនួនទៀតក៏មានការពាក់ព័ន្ធដែរ គឺប្រជាពលរដ្ឋនិងអ្នកសារព័ត៌មានរាប់ទាំងវិស័យអប់រំដែលយើងបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាផងដែរ។ វិស័យសារព័ត៌មាន មានតួនាទីសំខាន់ តែវិស័យនេះក៏អាចធ្វើឱ្យមានភាពច្របូកច្របល់កើតឡើងដែរ។ សម្ដេចបន្តថា "យើងសូមទទួលយកការផ្សាយព័ត៌មានគ្រប់ជ្រុងជ្រោយត្រឹមត្រូវពិតប្រាកដ មិនមែនជាការបង្ខូចកេរ្ដិ៍ឈ្មោះពីសំណាក់អ្នកសារព័ត៌មាន ពីសំណាក់សង្គមស៊ីវិល ឬពីសំណាក់គណបក្សនៅក្រៅរដ្ឋាភិបាល ដើម្បីឱ្យយើងមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ចាត់វិធានការ"។

សម្ដេចបន្ថែមទៀតថា អំពើពុករលួយគឺជាជំងឺដែលមានវ័យចំណាស់ជាងគេនៅលើពិភពលោកនេះ។ នៅពេលកកើតទឹកដីមកវាបាននាំមកជាមួយរួចទៅហើយ។ ដូចនេះវាមិនមែនជាការងាយស្រួលនោះទេ ក្នុងការលុបបំបាត់អំពើពុករលួយនេះ។វាទាមទារឱ្យមានឆន្ទៈប្ដូរផ្ដាច់ និងបទដ្ឋានគតិយុត្តិមួយត្រឹមត្រូវ។

គួររំឭកថារយៈពេល ១១ ឆ្នាំហើយ ដែលកម្ពុជាបានក្លាយជាសមាជិកនៃគំនិតផ្ដួចផ្ដើមប្រឆាំងអំពើពុករលួយ នៃADB/OECD ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក ហើយនេះជាលើកទី ១ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះរៀបចំសន្និសីទនេះសម្រាប់សហគមន៍ក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក។

◆ ថ្ងៃទី៩ខែកញ្ញាសម្ដេចតេជោនាយករដ្ឋមន្ត្រីបាន អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបើកការដ្ឋានសាងសង់ស្ពានអាកាសតិចណូ ដែលជាស្ពានអាកាសទី ៤ នៅក្នុងរាជធានីភ្នំពេញ។ នាឱកាសនោះ សម្ដេចបានថ្លែងដោយប្រយោលតែគេអាចយល់បានថាសំដៅទៅរកលោក កឹម សុខា អនុប្រធានគណបក្សសង្គ្រោះជាតិ និងជាអនុប្រធានទី ១ នៃរដ្ឋសភា។

សម្ដេចមានប្រសាសន៍ថា "ប៉ុន្មានថ្ងៃនេះ មានការបាញ់កាំភ្លើងធំនៅខេត្តកំពត តាកែវ និងខេត្តសៀមរាប។ ខ្ញុំកំពុងតែតាមមើល ព្រោះឯកឧត្តម សម រង្ស៊ី បានប្រកាសពីបទឈប់បាញ់ ហើយខ្ញុំក៏បានប្រកាសពីបទឈប់បាញ់នៅក្នុងសភា កាលពីថ្ងៃទី ៨ ខែសីហា ឆ្នាំ ២០១៤ ដែរ"។

ដោយកត់សម្គាល់ទៅលើសេចក្ដីថ្លែងការណ៍ដំបូង បន្ទាប់ពីគណបក្សទាំងពីរបានចូលរួមប្រជុំរដ្ឋសភារួមគ្នានៅថ្ងៃទី ៨ ខែសីហា ឆ្នាំ ២០១៤ ក្រោមកិច្ចព្រមព្រៀងនយោបាយថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១៤ រវាងគណបក្សទាំងពីរនោះ សម្ដេចតេជោបានមានប្រសាសន៍ថា "ខ្ញុំបានប្រាប់នៅក្នុងសភាថា សូមប្រជាពលរដ្ឋកត់ត្រាទុកនូវសម្ដីរបស់ឯកឧត្តម សម រង្ស៊ី ប៉ុន្តែឥឡូវចាប់ផ្ដើមបាញ់បណ្ដើរៗហើយ" ។សម្ដេចបញ្ជាក់ថា បើចង់ទម្លាក់រដ្ឋមន្ត្រីអូខេ។ ចំណែកយើងទម្លាក់អនុប្រធានសភាបានដែរតើ។ វាដូចគ្នាមានទៅមានមក ដោយយកហេតុផលមួយចំនួនដែលលោកឯងធ្វើមិនត្រឹមត្រូវតាមរបៀបនេះ ហើយសុំបោះឆ្នោតដាក់មនុស្សជំនួសតែម្ដង ព្រោះគណៈអចិន្ត្រៃយ៍គណបក្សប្រជាជនមាន ៧ សម្រេចទៅគឺគណបក្សប្រជាជននៅតែឈ្នះ ព្រោះត្រឹមសំឡេង ៥០ បូក ១ មានអីពិបាក"។ សម្ដេចតេជោបញ្ជាក់ថា សូមកុំអាលភ្លេចប្រយ័ត្នគិតៗតែពីទម្លាក់គេហើយគេទម្លាក់ខ្លួនឯងវិញ។ ធ្វើការជាមួយគ្នាមិនទាន់បានប៉ុន្មានផង គិត

រកទម្លាក់នាយករដ្ឋមន្ត្រី និងទម្លាក់រដ្ឋមន្ត្រី។ បើអញ្ចឹងយើងទម្លាក់មុនទៅ។ កោះប្រជុំសភាវិសាមញ្ញគណៈអចិន្ត្រៃយ៍ប្រជុំទៅ ដាក់របៀបវារៈបោះឆ្នោតជ្រើសរើសអនុប្រធានសភាទី ១ ជំនួសអនុប្រធានសភាទី ១ បច្ចុប្បន្ន។ ប៉ុន្តែដើម្បីចៀសវាងកុំឱ្យមានបញ្ហា សូមកម្រិតធ្វើម៉េចត្រឹមតែសមរម្យ បកស្រាយឱ្យមន្ត្រីខ្លួនក៏បកស្រាយទៅប៉ុន្តែសូមកុំឱ្យប៉ះពាល់ដល់អ្នកដទៃ។

◆ ថ្ងៃទី១៨ខែកញ្ញាសម្តេចនាយករដ្ឋមន្ត្រីកម្ពុជាបានអញ្ជើញចូលរួមក្នុងពិធីផ្សព្វផ្សាយ និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (pyGC) ២០១៤-២០១៨ ដែលប្រារព្ធធ្វើនៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា។

នាពេលនោះសម្តេចតេជោនាយករដ្ឋមន្ត្រីបានមានប្រសាសន៍ថា ចំពោះមុខនេះសម្តេចយល់ថា ការអនុវត្តប្រកបដោយជោគជ័យនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨នេះនឹងទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងរួមគ្នាប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ពីសំណាក់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ សំដៅឈានទៅសម្រេចឱ្យបាននូវបណ្តាគោលដៅអាទិភាពរបស់ជាតិ ការដោះស្រាយបាននូវបញ្ហាប្រឈម និងបន្តចាប់ច្បាមយកកាលានុវត្តភាពនានា។សម្តេចក៏បានរំឭកដែរថា នៅក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ២០០៩-២០១៣ កន្លងទៅ កម្ពុជាបានរងនូវបន្ទុកដ៏ធ្ងន់ចំនួនបី ក្នុងនោះមាន ទី១.ការប្រឹងប្រែង ដោះស្រាយបញ្ហាការងារ ដើម្បីជំរុញកំណើនសេដ្ឋកិច្ចក្នុងពេលដែលពិភពលោកជួបប្រទះនូវវិបត្តិហិរញ្ញវត្ថុនិងការធ្លាក់ចុះដ៏ធ្ងន់ធ្ងរនៃសេដ្ឋកិច្ច ទី២. ភាពចាំបាច់ក្នុងកិច្ចការពារបូរណភាពទឹកដី និងទី៣. ការដោះស្រាយបញ្ហាគ្រោះធម្មជាតិបណ្តាលមកពីទឹកជំនន់។

សម្តេចបានកត់សម្គាល់ថា បញ្ហាទាំងអស់នេះបានកើតឡើងដោយយើងមិនបានដឹងមុន។ ជារួមបញ្ហាប្រឈម និងឧបសគ្គទាំងនេះ មិនត្រឹមតែបានរារាំងដល់ការសម្រេចគោលដៅអភិវឌ្ឍន៍ជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានគំរាមបំផ្លាញសមិទ្ធផលដែលយើងសម្រេចបានក្នុងរយៈកាលកន្លងមកទៀតផង។ ប៉ុន្តែទោះបីយ៉ាង ណាក៏ដោយ ឈរលើមូលដ្ឋានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ រាជរដ្ឋាភិបាលកម្ពុជាសម្រេចបាននូវជោគជ័យធំៗគួរជាទីមោទនៈ ជាពិសេសគឺការធានានូវលំនឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន និងការនាំប្រទេសជាតិទាំងមូលឱ្យបានឆ្លងផុតស្ថានការណ៍ដ៏លំបាកទាំងឡាយ ហើយបង្កើតនូវបរិយាកាសអំណោយផលមួយសម្រាប់ធានាឱ្យមានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ ការធ្វើឱ្យសេដ្ឋកិច្ចមានកំណើនឡើងវិញបន្ទាប់ពីត្រូវរងផលប៉ះពាល់នៃវិបត្តិក្នុងឆ្នាំ២០០៩។ នៅឆ្នាំ២០០៩ សេដ្ឋកិច្ចកម្ពុជារក្សាបាននូវកំណើនវិជ្ជមានក្នុងកម្រិត ០,១% ហើយហក់ងើបឡើងវិញភ្លាម ដោយសម្រេចបាននូវអត្រាកំណើន ៦%ក្នុងឆ្នាំ ២០១០។ អត្រា ៧,១% ក្នុងឆ្នាំ ២០១១។ អត្រា ៧,៣% ក្នុងឆ្នាំ២០១២និងអត្រា៧,៦% ក្នុងឆ្នាំ២០១៣។កម្ពុជាបានធ្វើសមាហរណកម្មខ្លួនយ៉ាងពេញលេញចូលទៅក្នុងតំបន់ និងពិភពលោក ហើយកំពុងដើរតួនាទីយ៉ាងសកម្មក្នុងកិច្ចសហប្រតិបត្តិការនានាក្នុងឋានៈជាសមាជិកស្មើភាព និងស្មើសិទ្ធិលើឆាកអន្តរជាតិ។



សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** មានប្រសាសន៍ក្នុងពិធីសម្ពោធបើកការដ្ឋានសាងសង់ស្ពានអាកាសតិចណូ

សម្តេចតេជោក៏បានថ្លែងទៅកាន់មន្ត្រីដែលចូលរួមទៀតថា ដើម្បីសម្រេចបាននូវគោលដៅទាំងអស់នេះ ចាំបាច់ត្រូវច្បាមឱ្យជាប់នូវកត្តាជាយុទ្ធសាស្ត្រមួយចំនួន។ ទី១. ការពង្រឹងសុខសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ដើម្បីលើកកម្ពស់វិធានការច្បាប់ ការពារសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់មនុស្សនិងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ បង្កើតនូវបរិយាកាសអនុគ្រោះសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុង រយៈពេលវែង។ ទី២. ក្រសួងស្ថាប័នត្រូវបង្កើនកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងសហគមន៍អភិវឌ្ឍន៍ជនបទ ដើម្បីធានាការបង្កើតការងារថ្មី និងបង្កើនប្រាក់ចំណូល សំដៅលើកកម្ពស់ស្ថានភាពសេដ្ឋកិច្ចនៅសហគមន៍ និងធ្វើឱ្យពួកគាត់អាចចូលរួមចំណែកកាន់តែច្រើនឡើងថែមទៀតក្នុងសកម្មភាពសេដ្ឋកិច្ចជាតិ។ ទី៣.ការបន្តពង្រឹងការសម្រួលពាណិជ្ជកម្ម និងការធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងទីផ្សារតំបន់ ជាពិសេសក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការអាស៊ាន មហាអនុតំបន់ទន្លេមេគង្គ និងតំបន់អភិវឌ្ឍន៍ត្រីកោណកម្ពុជា ឡាវ វៀតណាមនិងការបន្តកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ផ្លូវថ្នល់ផ្លូវរថភ្លើង កំពង់ផែនិងព្រលានយន្តហោះ ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស ការសម្របសម្រួលពាណិជ្ជកម្ម ឧស្សាហកម្ម ពិសេសការបង្កើតលក្ខខណ្ឌចាំបាច់នានាដើម្បីធ្វើសមាហរណកម្មសហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យមិនរៀបរយ ទៅក្នុងសេដ្ឋកិច្ចរៀបរយវិញ។ ទី៤.ការបន្តពង្រឹងសមត្ថភាពស្ថាប័នរបស់រាជរដ្ឋាភិបាលដើម្បីផ្តល់សេវារបស់ខ្លួនឱ្យមានប្រសិទ្ធភាព និងដើម្បីបន្តជំរុញវប្បធម៌តម្លាភាព គណនេយ្យភាព តាមរយៈការរៀបចំ និងអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពយ៉ាងទូលំទូលាយមួយដែលគ្របដណ្តប់លើគ្រប់ស្ថាប័នសាធារណៈទាំងអស់ និងមានកិច្ចសហការពីស្ថាប័នសាធារណៈទាំងនោះ។ ទី៥.ការដោះស្រាយបញ្ហាថវិកា ក្នុងនោះយើងបានកំណត់ចំណុចដៅនៃតម្រូវការវិនិយោគវិស័យសាធារណៈដែលអាចមានតម្លៃប្រមាណជាង ១១ ០០០ លានដុល្លារអាមេរិក ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី ៥ នៃរដ្ឋសភានេះ។ តម្រូវការធនធានសម្រាប់ការគាំទ្រគឺមានគោលដៅ

ច្បាស់លាស់ដល់ការអភិវឌ្ឍ និងពិពិធកម្មសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ រួមទាំងការគ្រប់គ្រងគ្រោះមហន្តរាយនានាផងដែរ ។

ក្នុងឱកាសនោះដែរ សម្តេចបានធ្វើការកត់សម្គាល់ និងរីករាយចំពោះដំណើរការតាមលទ្ធិប្រជាធិបតេយ្យ ដែលកំពុងប្រព្រឹត្តទៅនៅក្នុងរដ្ឋសភាជាតិ ។ សម្តេចមានប្រសាសន៍ថា ប្រសិនជាសភាពការណ៍នៅល្អបែបនេះជារៀងរហូតនោះ គឺកម្ពុជាបានដំណើរការទៅតាមគន្លងនៃសន្តិភាព ស្ថិរភាពនយោបាយ និងការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវលិទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស និងនីតិរដ្ឋ ។ សម្តេចបន្ថែមថា កន្លែងដែលគេត្រូវនិយាយគ្នា គឺរដ្ឋសភាមិនមែនតាមចិញ្ចើមថ្នល់នោះទេ ហើយក៏ត្រូវដឹងដែរថា អង្គុយលើកៅអីណាត្រូវនិយាយពីអ្វី នេះទើបជាបញ្ហាសំខាន់ ។ ក្នុងប៉ុន្មានថ្ងៃនេះ យើងពិនិត្យឃើញថាគណៈកម្មការនានានៃរដ្ឋសភាបានអញ្ជើញរដ្ឋមន្ត្រីទៅសួរ ក្នុងនោះ មានរដ្ឋមន្ត្រីសុខាភិបាល និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ។ ប្រជាធិបតេយ្យសេរី ពហុបក្ស គេធ្វើអញ្ចឹង ។ គេអត់ទៅនិយាយនៅតាមចិញ្ចើមថ្នល់ ឬឃោសនានោះទេ ។ ធ្វើដូចនេះទើបហៅថា រួមគ្នាដោះស្រាយបញ្ហាប្រទេសជាតិ មិនថាបក្សក្នុងរដ្ឋាភិបាល ឬបក្សក្រៅរដ្ឋាភិបាលទេ ដំណើរការវាយ៉ាងដូច្នេះឯង ។ សម្តេចចង់ឱ្យដំណើរការបែបនេះមានជាបន្ត ហើយអស់លោករដ្ឋមន្ត្រីកុំចាំបាច់មកសួរនាយករដ្ឋមន្ត្រីថា ខ្ញុំត្រូវទៅឆ្លើយឬអត់? តែគណៈកម្មការសភាកោះអញ្ជើញត្រូវតែទៅ ហើយកុំមកសួរនាយករដ្ឋមន្ត្រីថា ខ្ញុំត្រូវឆ្លើយបែបណា ។ ត្រូវមើលក្នុងរដ្ឋធម្មនុញ្ញឱ្យច្បាស់ រដ្ឋមន្ត្រីត្រូវទទួលខុសត្រូវចំពោះមុខនាយករដ្ឋមន្ត្រី និងសភា ។

◆ ថ្ងៃទី២៩ខែកញ្ញាសម្តេចតេជោ**ហ៊ុន សែន**បានអញ្ជើញចូលរួមក្នុងពិធីប្រគល់សញ្ញាបត្រជូនដល់និស្សិតជ័យលាភីនៃសាកលវិទ្យាល័យចម្រើនពហុបច្ចេកវិទ្យា សរុបចំនួន ២ ៣៩៨ នាក់ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ ។នាពេលនោះសម្តេចបានថ្លែងថា រាជរដ្ឋាភិបាលកម្ពុជាកំពុងកសាងប្រព័ន្ធបៀវត្សរ៍មួយ ខណៈដែលបច្ចុប្បន្នប្រព័ន្ធបៀវត្សរ៍មិនទាន់បានត្រឹមត្រូវ ហើយថែមទាំងនៅដាច់ដោយឡែក១ពីគ្នា ។ ប្រព័ន្ធបៀវត្សរ៍មួយជាក់លាក់នឹងចាប់ផ្តើមអនុវត្តនៅឆ្នាំ២០១៥ ខាងមុខ បន្ទាប់ពីការធ្វើកំណែទម្រង់ប្រព័ន្ធបៀវត្សរ៍ឡើងវិញ ។

សម្តេចបន្តថា យោងតាមការអនុវត្តផែនការថវិកាពាក់កណ្តាលឆ្នាំ រាជរដ្ឋាភិបាលបានផ្តល់អាទិភាពទៅលើក្រសួងអប់រំ និងក្រសួងសុខាភិបាល គឺជាក្រសួងអាទិភាពក្នុងការដំឡើងបៀវត្សរ៍មុនគេ ដោយសារថា នៅក្នុងក្របខណ្ឌមន្ត្រីរាជការជាង ១៨ ម៉ឺននាក់នោះ គ្រាន់តែក្របខណ្ឌគ្រូបង្រៀនមួយមានចំនួនជាង ១១ ម៉ឺននាក់ និងគ្រូពេទ្យមានជាង ១៩ 000 នាក់ ។

សម្តេចបញ្ជាក់ថា សម្រាប់ក្របខណ្ឌគ្រូបង្រៀនដែលមានប្រាក់ខែច្រើន ហើយពុំបានដំឡើងទៀតទេ ។ ការដំឡើងសម្រាប់ក្របខណ្ឌគ្រូដែលមានប្រាក់ខែទាប ដែលក្នុងនោះក្របខណ្ឌមន្ត្រីការិយាល័យនៅតាមសាលាដែលទាបបំផុត ៤២៤ 000 រៀល នោះនៅក្នុងខែកញ្ញានឹងឡើងដល់ ៥០៥ 000 រៀល ហើយចាប់ពីខែមករា ដល់ខែមីនា ២០១៥ នឹងឡើងដល់ ៥០៧ ៨00 រៀល ហើយចាប់ពីខែមេសាទៅឡើងដល់ ៥៥២ ៨00 រៀល ។ ចំណែកក្របខណ្ឌគ្រូបឋមសិក្សាដែលមានរហូតដល់ទៅ ៥១ ៦១៥ នាក់នោះ ប្រាក់ខែទាបបំផុត ៤៨២ ៨00 រៀល នោះចាប់ពីខែកញ្ញាទៅនឹងឡើងដល់ ៥៥0 000 រៀល ហើយចាប់ពីខែមករាដល់មីនាឆ្នាំ ២០១៥ នឹងឡើងដល់ ៥៦៦ ៤៨0 រៀល ហើយចាប់ពីខែមេសាទៅនឹងឡើងដល់ ៦៤៦ ៤៨0 រៀល ។ ចំពោះអ្នកដែលទៅបង្រៀននៅតំបន់ដាច់ស្រយាល ត្រូវបានបន្ថែមចំនួន ៨0 000 រៀលទៀត ។

សម្តេចក៏បានថ្លែងទាក់ទងពីការដំឡើងប្រាក់បៀវត្សរ៍ដល់គ្រូបង្រៀនដែរថានឹងឡើងចាប់ពីខែកញ្ញា ឆ្នាំ ២០១៤ នេះ ក៏ប៉ុន្តែដោយការរៀបចំមិនទាន់រួចរាល់ទាំងស្រុង ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងជំរុញការរៀបចំឱ្យរួចរាល់ក្នុងពេលខាងមុខ នៅពេលបើកប្រាក់បៀវត្សរ៍នៅខែតុលាខាងមុខ នឹងបើកប្រាក់រំពូកបន្ថែមជូនវិញ ហើយបន្ទាប់ពីការរៀបចំដល់គ្រូបង្រៀនរួច នឹងរៀបចំដល់គ្រូពេទ្យជាបន្តទៀត ដែលវិស័យទាំងពីរនេះជាអាទិភាពដើម្បីពង្រាយគ្រូបង្រៀន និងគ្រូពេទ្យឱ្យទៅដល់ជនបទ ។ ទាក់ទងនឹងប្រាក់បៀវត្សរ៍នេះដែរ សម្តេចក៏បានសរសើរដល់ក្រសួងមួយចំនួនដែលបានបើកប្រាក់ខែជូនមន្ត្រីរាជការបានមុនបុណ្យភ្ជុំបិណ្ឌ លើកលែងតែក្រសួងស្ថាប័នចំនួន ៧ ប៉ុណ្ណោះ ដោយសារតែសាមីក្រសួងមិនបានបញ្ជូនឯកសារដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានទាន់ពេលវេលា ។

សម្តេចបានឱ្យដឹងទៀតថា ក្រសួងទាំង៧នោះរួមមាន ក្រសួងផែនការ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងកិច្ចការនារី កសួងអភិវឌ្ឍន៍ជនបទ សាលាឧទ្ធរណ៍ អគ្គសវនកម្មជាតិ និងអង្គភាពប្រឆាំងពុករលួយ ។ សម្តេចបានបញ្ជាក់ថា ប្រធានស្ថាប័នទាំង៧នេះ ត្រូវតែបើកប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការរបស់ខ្លួនឱ្យបានមុនដំណាច់ខែ ។

ក្នុងពិធីនេះដែរ បានកត់សម្គាល់ទៅដល់ព្រឹត្តិការណ៍ពិធីបុណ្យកាន់បិណ្ឌ ភ្ជុំបិណ្ឌប្រពៃណីជាតិ ដែលទើបបញ្ចប់កន្លងទៅថ្មីៗនេះ ។ សម្តេចបានលើកឡើងថា កត្តាសន្តិភាពគឺជាកត្តាចម្បងបំផុតដែលធ្វើឱ្យប្រជាពលរដ្ឋមានសេចក្តីសុខ និងប្រទេសជាតិមានឱកាសអភិវឌ្ឍន៍ ។ ប្រជាពលរដ្ឋបានធ្វើដំណើរពេញទូទាំងប្រទេសក្នុងឱកាសភ្ជុំបិណ្ឌនេះ គឺដោយសារមានកត្តាចំនួន ៤ ។ ទីមួយសុខសន្តិភាពពេញផ្ទៃប្រទេស ទីពីររាជរដ្ឋាភិបាលបានខិតខំកសាងហេដ្ឋារចនាសម្ព័ន្ធនៅទូទាំងប្រទេស ទីបីមធ្យោបាយធ្វើដំណើររបស់ប្រជាពលរដ្ឋមានការកើនឡើង ទាំងមធ្យោបាយផ្ទាល់ខ្លួន និងរថយន្តឈ្នួល និងទីបួនគឺប្រាក់ចំណូលរបស់ប្រជាពលរដ្ឋមានការកើនឡើង ។

សម្តេចក៏បានជំរុញឱ្យសាលារាជធានីភ្នំពេញពិភាក្សាគ្នាជាមួយក្រសួងសាធារណការ និងក្រុមហ៊ុនស្ពានជ្រោយចង្វាយទី ២ ខិតខំធ្វើឱ្យហើយមុនព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប អកអំបុក សំពះព្រះខែ ដើម្បីឱ្យប្រជាពលរដ្ឋអាចធ្វើចរាចរទៅមកបានស្រួល បន្ធូរការកកស្ទះចរាចរ ។ សម្តេចបានញ្ជាក់ថា បុណ្យអុំទូក ឆ្នាំនេះត្រូវតែធ្វើឱ្យបាន ព្រោះយើងបានអាក់ខានធ្វើតាំងពីឆ្នាំ ២០១១ មកម្ល៉េះ ដោយសារព្រះមហាវរក្សត្រសោយទិវង្គត និងទឹកជំនន់ធំនៅឆ្នាំ ២០១១ និង ២០១៣ ។/

# សម្តេចចក្រី ហេង សំរិន បំពេញទស្សនកិច្ចនៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ



*សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ជូនវត្ថុអនុស្សាវរីយ៍ ដល់លោកជំទាវ **ប៉ានី យ៉ាថូទូ** ប្រធានរដ្ឋសភាឡាវ*



*សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ជួបពិភាក្សាការងារទ្វេភាគី ជាមួយលោកជំទាវ **ប៉ានី យ៉ាថូទូ***




*សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ធ្វើសេចក្តីថ្លែងការណ៍ក្នុងមហាសន្និបាតអន្តរសភា (AIPA)*

សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់នៃរដ្ឋសភាវិលត្រឡប់មកពីរដ្ឋធានីវៀងច័ន្ទ កាលពីថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ២០១៤ បន្ទាប់ពីបានបញ្ចប់ដំណើរទស្សនកិច្ចមិត្តភាពជាផ្លូវការ និងចូលរួមមហាសន្និបាតអន្តរសភា(AIPA)នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ប្រកបដោយជោគជ័យ។ ឯកឧត្តម **ប៉ែន បញ្ញា** ប្រធានគណៈកម្មការនីតិកម្ម និងយុត្តិធម៌នៃរដ្ឋសភា បានធ្វើសន្និសីទសារព័ត៌មាននៅពេលមកដល់ព្រលានយន្តហោះអន្តរជាតិភ្នំពេញនៅថ្ងៃនោះថា ដំណើរទស្សនកិច្ចរយៈពេល ៤ ថ្ងៃរបស់គណៈប្រតិភូជាន់ខ្ពស់រដ្ឋសភាកម្ពុជានៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវគឺទទួលបានលទ្ធផលដ៏ល្អប្រសើរ។

សម្តេចប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា និងគណៈប្រតិភូជាន់ខ្ពស់បានជួបពិភាក្សាការងារទ្វេភាគីជាមួយលោកជំទាវ **ប៉ានី យ៉ាថូទូ** ប្រធានរដ្ឋសភាឡាវ ជួបសម្តែងការគួរសមជាមួយឯកឧត្តម **ថងស៊ីង ថាំម៉ាវង្ស** នាយករដ្ឋមន្ត្រីឡាវ ជួបសម្តែងការគួរសមជាមួយឯកឧត្តម **ជុំម៉ាលី សៃយ៉ាសន** ប្រធានរដ្ឋ និងជាអគ្គលេខាធិការមជ្ឈិមបក្សប្រជាជនបដិវត្តន៍ឡាវ។

ឯកឧត្តម **ប៉ែន បញ្ញា** មានប្រសាសន៍ថា ក្នុងជំនួបនីមួយៗ ភាគីទាំងពីរបានជម្រាបជូនគ្នាទៅវិញទៅមកអំពីលទ្ធផលជាផ្លែផ្កាដែលទទួលបានក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងវប្បធម៌ នាពេលកន្លងមក ហើយក៏បានលើកឡើងអំពីការដែលត្រូវគិតគូរយ៉ាងណាដើម្បីឱ្យស្ថាប័ននីតិប្បញ្ញត្តិទាំងពីរជំរុញឱ្យរដ្ឋាភិបាលរៀងៗខ្លួនខិតខំអនុវត្តឱ្យបានល្អនូវកិច្ចព្រមព្រៀងទាំងឡាយដែលបានធ្វើកន្លងមក ទាំងក្នុងស្ថាប័ននីតិប្បញ្ញត្តិ ក៏ដូចជានីតិប្រតិបត្តិ ជាពិសេសធ្វើឱ្យទំនាក់ទំនងមិត្តភាព សហប្រតិបត្តិការកាន់តែបានរឹងមាំ និងស៊ីជម្រៅ ហើយជំរុញឱ្យការងារទាំងអស់ដែលបានចុះកិច្ចព្រមព្រៀងបានកាន់តែល្អប្រសើរ ដើម្បីផលប្រយោជន៍ខាងសេដ្ឋកិច្ចសង្គមទៅវិញទៅមករវាងប្រទេសទាំងពីរ។ ភាគីទាំងពីរក៏បានឯកភាពគ្នាថា ត្រូវតែខិតខំធ្វើយ៉ាងណាដើម្បីជំរុញការងារបោះបង្គោលព្រំដែនរវាងប្រទេសទាំងពីរឱ្យបានលឿន ដោយគោរពឱ្យបានហ្មត់ចត់នូវកិច្ចព្រមព្រៀងនានា សំដៅប្រែក្លាយព្រំដែនឱ្យទៅជាព្រំដែនសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍ។ ភាគីទាំងពីរក៏បានឯកភាពគ្នាដែរថា រាល់ការងារដែលមានការពាក់ព័ន្ធប្រឈមត្រូវខិតខំដោះស្រាយដោយការអត់ធ្មត់ ដោយមិនឱ្យមានការប៉ះទង្គិច ហើយខិតខំធ្វើយ៉ាងណាឱ្យមានការជឿជាក់លើគ្នាទៅវិញទៅមក។

ក្នុងដំណើរទស្សនកិច្ចនេះ សម្តេចចក្រី **ហេង សំរិន** និងគណៈប្រតិភូជាន់ខ្ពស់រដ្ឋសភាកម្ពុជាបានចូលរួមបើកមហាសន្និបាតអន្តរសភា អាស៊ាន ហៅកាត់ថា អាយប៉ា (AIPA) លើកទី ៣៥ ដែលនៅក្នុង នោះប្រទេសជាសមាជិកអាយប៉ាទាំង ១០ និងប្រទេសជាអ្នកសង្កេតការណ៍មួយចំនួនទៀតបានធ្វើសេចក្តីថ្លែងការណ៍ទៅកាន់មហាសន្និបាត ក្នុងនោះ សម្តេចប្រធានរដ្ឋសភាកម្ពុជាក៏បានធ្វើសេចក្តីថ្លែងការណ៍ផងដែរ ។

ក្នុងដំណើរទស្សនកិច្ចនេះដែរ សម្តេចចក្រី **ហេង សំរិន** និងគណៈប្រតិភូជាន់ខ្ពស់រដ្ឋសភាកម្ពុជាក៏បានអញ្ជើញចុះជួបសំណេះសំណាលជាមួយនិស្សិតខ្មែរចំនួន ៥៤ នាក់ ដែលទទួលបានអាហារូបករណ៍ទៅបន្តការសិក្សានៅប្រទេសឡាវ ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការរវាងប្រទេសពីរ។/

# ឯកឧត្តម សុខ អាន ប្រជុំត្រួតពិនិត្យការងាររបស់ក្រុមការងារថ្នាក់ជាតិ ចុះជួយខេត្តតាកែវរយៈពេល ១ ឆ្នាំ





*ឯកឧត្តម **សុខ អាន** ក្នុងឱកាសដឹកនាំប្រជុំត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលរយៈពេល ១ ឆ្នាំ នៅខេត្តតាកែវ*

ក្នុងឱកាសដឹកនាំប្រជុំត្រួតពិនិត្យនិងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលរយៈពេល ១ ឆ្នាំកន្លងមក នៅខេត្តតាកែវ នាព្រឹកថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ២០១៤ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**សុខ អាន**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះជួយខេត្តតាកែវ បានជំរុញឱ្យក្រុមការងារថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទាំងអស់ត្រូវចុះជួយដោះស្រាយបញ្ហាទាំងឡាយជូនប្រជាពលរដ្ឋឱ្យដល់មូលដ្ឋានបានឆាប់រហ័ស និងប្រកបដោយប្រសិទ្ធភាព។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានណែនាំដល់សមាជិកក្រុមការងារទាំងអស់ ត្រូវមានភាពសកម្មក្នុងការចុះជួបប្រជាពលរដ្ឋដោយផ្ទាល់នៅតាមផ្ទះទើបមើលឃើញបញ្ហា និងត្រូវសិក្សាស្វែងរកគន្លឹះដើម្បីដោះស្រាយ ជាពិសេស ត្រូវពន្លត់នូវគ្រប់ទំនាស់នានាដែលកើតមានឡើងប៉ះពាល់ដល់ការរស់នៅរបស់ប្រជាពលរដ្ឋ ក្នុងន័យថាក្រុមការងារទាំងអស់ត្រូវចុះធ្វើការងារ និងជំរុញចលនាឱ្យខ្លាំងក្លា ដោយមិនត្រូវដេកលក់នោះទេ។

ឯកឧត្តមក៏បានឱ្យក្រុមការងារលើកឡើងអំពីលទ្ធផលមួយចំនួននៅតាមមូលដ្ឋាន ដើម្បីធ្វើជាបទពិសោធន៍ក្នុងការសម្របសម្រួលដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋនៅតាមទីកន្លែងដទៃទៀតក្នុងខេត្តតាកែវ ក្នុងនោះ ដូចជាការលុបកិច្ចសន្យាពីក្រុមហ៊ុនបាទី ទូរីសឹម របស់លោកស្រី សុខ សារឿន ដែលបានរំលោភលើកិច្ចសន្យា និងគាបសង្កត់លើប្រជាពលរដ្ឋ យកមកប្រគល់ជូនប្រជាសហគមន៍គ្រប់គ្រងវិញ ការសម្រួលលើទំនាស់នៅផ្សារព្រៃល្វា ស្រុកព្រៃកប្បាស់ ការធ្វើប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងបញ្ចប់ទំនាស់ ១ ចំនួន ដែលបានកើតឡើង នៅស្រុកត្រាំកក់ វត្តឧត្តមសូរិយាជាដើម។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រីក៏បានជំរុញឱ្យមានការបង្កើតក្រុមទីប្រឹក្សាការងារបញ្ញត្តិករផ្សារ ដោយមានការចូលរួមពីមន្ត្រីថ្នាក់ស្រុក និងខាងតំណាងអ្នកគ្រប់គ្រងផ្សារធំៗទាំង ៤០ នៅទូទាំងខេត្តតាកែវ និងត្រូវយករូបមន្តល្អៗពីបណ្ដាផ្សារមួយចំនួនដែលដំណើរការល្អធ្វើជាយន្តការសម្រាប់ដោះស្រាយសម្រួលដល់អាជីវករ និងប្រជាពលរដ្ឋឱ្យទទួលបាននូវការសុខចិត្ត និងបញ្ចៀសបាននូវទំនាស់កុំឱ្យកើតមានឡើងក្នុងនោះមានដំណោះស្រាយពាក់ព័ន្ធនឹងបញ្ហាសត្តឃាតផងដែរ។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រីក៏បានជំរុញជាអាទិភាពផងដែរ ឱ្យរៀបចំបង្កើតសហគមន៍កសិកម្ម តាមរយៈសហគមន៍ដែលមានស្រាប់ ដើម្បីបង្កើតជាសហគមន៍ថ្មីឱ្យមានដំណើរការល្អទៅមុខ និងធ្វើការងារឱ្យសកម្ម និងហ្មត់ចត់ បន្ទាប់ពីមានការសិក្សាស្រាវជ្រាវដោយក្រុមអ្នកជំនាញមួយរយៈមកនេះ។

គួរបញ្ជាក់ថា នៅក្នុងខេត្តតាកែវមានសហគមន៍កសិកម្ម និងនេសាទតូចៗប្រមាណ ៥៨ ប៉ុន្តែសហគមន៍ទាំងនោះបង្កើតឡើងមានលក្ខណៈជាក្រុមតូចៗ និងបានសហការជាមួយអង្គការមួយចំនួន ប៉ុន្តែមិនទាន់ត្រូវបានរៀបចំឱ្យស្ថិតនៅក្នុងការគ្រប់គ្រងច្បាស់លាស់ពីក្រុមការងារថ្នាក់ជាតិ ដោយការទទួលខុសត្រូវខ្ពស់នៅឡើយ។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** បានអំពាវនាវឱ្យប្រធានក្រុមការងារថ្នាក់ស្រុកនីមួយៗចុះជួយខេត្តតាកែវ ត្រូវសហការជាមួយអ្នកជំនាញដែលមានបទពិសោធន៍និងគាំទ្រហិរញ្ញវត្ថុដើម្បីរៀបចំសហគមន៍កសិកម្មនៅក្នុងខេត្តតាកែវ ដោយឯកឧត្តមសន្យាថានឹងជួយពូជស្រូវ និងផ្ដត់ផ្គង់ជីដល់កសិករដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ។/

# ឯកឧត្តម អ៊ឹម ឈុនលឹម ប្រជុំជីវភាពនយោបាយនៅខេត្តមណ្ឌលគិរី

ថ្មីៗនេះនៅខេត្តមណ្ឌលគិរីមានរៀបចំប្រជុំជីវភាពនយោបាយប្រចាំខែសីហា ឆ្នាំ ២០១៤ ក្រោមអធិបតីភាពឯកឧត្តមទេសរដ្ឋមន្ត្រី **អ៊ឹម ឈុនលឹម** រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានក្រុមការងារថ្នាក់កណ្ដាលចុះជួយខេត្តក្រចេះ និងមណ្ឌលគិរី ។

នៅក្នុងវគ្គជីវភាពនយោបាយប្រចាំខែសីហាក្នុងខេត្តមណ្ឌលគិរីនេះ ឯកឧត្តមទេសរដ្ឋមន្ត្រី **អ៊ឹម ឈុនលឹម** បានមានប្រសាសន៍ថា នៅថ្ងៃទី២៥ខែកញ្ញាខាងមុខនេះគឺជាខួប១ឆ្នាំនៃរាជរដ្ឋាភិបាលដែលត្រូវធ្វើការប្រជុំផ្ទៃក្នុងទូទាំងប្រទេសគ្រប់ក្រសួងស្ថាប័នទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី បានណែនាំឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីធ្វើការណែនាំលម្អិតទាក់ទងនិងការប្រជុំផ្ទៃក្នុងថ្នាក់ក្រោមជាតិ និងឃុំស្រុក ។ ឯកឧត្តមទេសរដ្ឋមន្ត្រីបានឱ្យដឹងថា ការជួបប្រជុំគ្នាជាគោលការណ៍រួមគឺចង់លើកឱ្យឃើញពីចំណុចជឿនលឿនចំណុចថ្មីៗ ប្រៀបធៀបនឹងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេសការកែទម្រង់គ្រប់វិស័យ ថាតើក្នុង ១ ឆ្នាំបានធ្វើអ្វីខ្លះដែលជាចំណុចជឿនលឿនតាមវិស័យនីមួយៗ ។ ស្រុកខ័ណ្ឌនីមួយៗអាចលើកឡើងពីចំណុចកែទម្រង់ថ្មី និងទាក់ទងនឹងសេវាសាធារណៈ វេទិកាសាធារណៈ ការរៀបចំទីក្រុង និងកំណត់ចំណុចអាទិភាពចំពោះបញ្ហាណាដែលត្រូវដោះស្រាយដំបូង និងបន្តបន្ទាប់ ។ ឯកឧត្តមទេសរដ្ឋមន្ត្រីបានលើកឡើងថា បញ្ហាដែលជាកង្វល់ក្នុងសង្គមគឺបញ្ហាដីធ្លីជាបញ្ហាទី ១ ដែលលេចធ្លោជាងគេមុនបញ្ហាតុលាការ និងបញ្ហាពុករលួយទៅទៀត ។ បញ្ហាដីធ្លីជាបញ្ហាក្ដៅ និងជាអាទិភាពដែលរាជរដ្ឋាភិបាលកំពុងដោះស្រាយ ។

នៅក្នុងឱកាសនោះ ឯកឧត្តមទេសរដ្ឋមន្ត្រី **អ៊ឹម ឈុនលឹម** បានជំរុញឱ្យមន្ទីរអង្គភាព ស្ថាប័នពាក់ព័ន្ធ លើកឡើងនូវបញ្ហានានាដែលកំពុងប្រឈមនៅក្នុងដំណើរការអនុវត្តការងារ និងចំណុចកែទម្រង់ថ្មីណាមួយនៅក្នុងវិស័យនានាក្នុងខេត្តផងដែរ ។ ឆ្លើយតបនឹងបញ្ហានេះ បណ្ដាតំណាងអង្គភាព ស្ថាប័នពាក់ព័ន្ធ ក៏ដូចជាអាជ្ញាធរមូលដ្ឋាន បានជម្រាបជូនពីក្ដីកង្វល់ និងបញ្ហាប្រឈមនានា ដូចជាបញ្ហាពង្រឹងសាមគ្គីភាពផ្ទៃក្នុងដែលត្រូវកែសម្រួល សហការគ្នាឱ្យបានល្អបន្ថែមទៀតនៅគ្រប់លំដាប់ថ្នាក់ និងបញ្ហាផ្សេងទៀតដូចជាបញ្ហាព្រៃឈើបញ្ហាទឹកជំនន់ ការផ្ដល់សេវាសាធារណៈ ដែលរួមមានការដោះស្រាយបញ្ហាទឹក-ភ្លើង នៅស្រុកកោះញែក ការស្ថាបនាជួសជុលផ្លូវ ការដោះស្រាយ




*ឯកឧត្តមទេសរដ្ឋមន្ត្រី **អ៊ឹម ឈុនលឹម** រៀបចំប្រជុំជីវភាពនយោបាយ ប្រចាំខែសីហា ឆ្នាំ ២០១៤ នៅខេត្តមណ្ឌលគិរី*



វិវាទដីធ្លី និងបញ្ហាផ្សេងមួយចំនួនទៀតដែលខេត្តកំពង់ជួបប្រទះ ។ ឯកឧត្តមទេសរដ្ឋមន្ត្រី បានអបអរសាទរចំពោះស្រុកកោះញែកដែលមិនសូវជួបបញ្ហា ប៉ុន្តែក៏បានស្នើឱ្យអាជ្ញាធរពាក់ព័ន្ធទាំងអស់បន្តពិនិត្យបន្ថែមទៀតលើការងារទាំងអស់ ។

សរុបមក អាជ្ញាធរនិងសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ បានខិតខំដោះស្រាយការលំបាករបស់ប្រជាជននៅគ្រប់តំបន់ដែលត្រូវរងគ្រោះដោយទឹកជំនន់ សំដៅស្តារឡើងវិញឱ្យបានឆាប់រហ័សនូវហេដ្ឋារចនាសម្ព័ន្ធផលិតកម្ម និងជីវភាពរស់នៅរបស់ប្រជាជន ។ ការចុះសួរសុខទុក្ខ និងចែកអំណោយសង្គ្រោះរបស់ថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជា ដល់ប្រជាពលរដ្ឋដែលរងគ្រោះបានទាន់ពេលវេលា ដោយមិនប្រកាន់និន្នាការនយោបាយ ដែលបានផ្សារភ្ជាប់នូវមនោសញ្ចេតនាដ៏ល្អប្រពៃជាមួយប្រជាជននៅតាមមូលដ្ឋានភូមិ-ឃុំ ។ គណបក្សខេត្តមណ្ឌលគិរី ក៏បានកំណត់ទិសដៅ និងភារកិច្ចមួយចំនួនសម្រាប់អនុវត្តបន្តសំដៅជំរុញការកសាងនិងអភិវឌ្ឍខេត្តឱ្យកាន់តែមានការរីកចម្រើននិងកាត់បន្ថយនូវភាពក្រីក្ររបស់ប្រជាជន ។/

# សកម្មភាពសមាជិកព្រឹទ្ធសភា_រដ្ឋសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០១៤ ឯកឧត្តម **សាយ ឈុំ** ប្រធានស្ដីទីព្រឹទ្ធសភា ប្រធានគណៈប្រចាំការគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាល និងលោកជំទាវ បានអញ្ជើញចូលរួមពិធីបុណ្យកាន់បិណ្ឌវេនទី ៥ នៅវត្តពោធិឫទ្ធិ (ហៅវត្តត្នោត) និងវត្តវិសុទ្ធិវង្សា (ហៅវត្តកណ្ដាលកោះ) ស្ថិតក្នុងឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម ។ ក្នុងឱកាសនោះដែរ ឯកឧត្តមបានរៀបចំចង្ហាន់បិណ្ឌបាត្រទេយ្យវត្ថុ និងគ្រឿងឧបភោគបរិភោគ និងបច្ច័យប្រគេនព្រះសង្ឃគង់ចាំព្រះវស្សាក្នុងវត្តទាំង ២ មាន : ប្រគេនព្រះសង្ឃវត្ត ពោធិឫទ្ធិចំនួន ៦ អង្គក្នុងមួយអង្គៗ ១០០ ០០០៛ និងព្រះគ្រូចៅអធិការវត្ត ១៥០ ០០០៛ និងបច្ច័យកសាងវត្ត ១០ លានរៀល ។ ប្រគេនព្រះសង្ឃវត្តវិសុទ្ធវង្សា ៥ អង្គ ក្នុងមួយអង្គៗ ១០ ម៉ឺនរៀល និងព្រះគ្រូចៅអធិការ ១៥០ ០០០៛ និងទទួលឧត្ដម្ភការកសាងដងទង់មួយគូរ នៅមុខព្រះវិហារ ។ គ្រឿងឧបភោគបរិភោគសម្រាប់វត្តនីមួយៗរួមមាន : ទឹកដោះគោខាប់ ៣ កេស ស្ករស ២៥ គក្រ ត្រីខកំប៉ុង ៣ កេសធំ ទឹកក្រូច ១០ កេស មី ១០ កេស ទឹកសុទ្ធ ៣ កេស ផ្លែឈើស្រស់ ៣ កេស ។/









*ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៤ ឯកឧត្តមបណ្ឌិត **ឌួន ញ៉ិល** អនុប្រធានទី២ រដ្ឋសភា សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា បានអញ្ជើញជាអធិបតីភាពក្នុងពិធីសំណេះសំណាលសួរសុខទុក្ខ និងចែកជូនសម្ភារៈស្បៀងអាហារដល់ប្រជាជនរងគ្រោះដោយទឹកជំនន់ចំនួន៤៨០គ្រួសារក្នុងខេត្តកំពង់ធំ។ ពិធីបានរៀបចំឡើងក្នុងបរិវេណសាលាស្រុកកំពង់ស្វាយ។*

*បន្ទាប់ពីពិធីសំណេះសំណាលរួចមក ឯកឧត្តមបណ្ឌិត **ឌួនញ៉ិល** និងមន្ត្រីរាជការដែលរួមដំណើរ បានអញ្ជើញចែកជូនដល់បងប្អូនប្រជាជនរងគ្រោះទាំង ៤៨០ គ្រួសារ ក្នុង១គ្រួសារទទួលបានអង្ករ២៥គីឡូក្រាម មុងជ្រលក់ថ្នាំ១ កន្ទេល១ មី ១ កេស ទឹកស៊ីអ៊ីវ១ឡូត៍ ទឹកត្រី១ឡូត៍ និងត្រីខកំប៉ុង១យួរ។ ឧបត្ថម្ភសាលាស្រុកកំពង់ស្វាយ១លានរៀល ។*

*ឯកឧត្តមបណ្ឌិត **ឌួន ញ៉ិល** បានចូលបច្ច័យចំនួនមួយលានរៀលដល់ពិធីបុណ្យព្រះសពចៅអធិការវត្តអន្លង់ក្រាញ់ ស្ថិតក្នុងឃុំពពក ស្រុកស្ទោង ខេត្តកំពង់ធំដែលបានទទួលអនិច្ចធម៌ដោយភ្លើងឆេះកុដិ ។*

ថ្ងៃទី១៧ខែកញ្ញាឯកឧត្តមនាយឧត្តមសេនីយ៍ **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងការពារជាតិ ដោយមានការចូលរួមពីសំណាក់មន្ត្រីជាន់ខ្ពស់ នៃបណ្ដាស្ថាប័នចំណុះក្រសួងការពារជាតិ ព្រមទាំងក្រុមគ្រួសារញាតិមិត្តជិតឆ្ងាយយ៉ាងច្រើនកុះករ បានអញ្ជើញប្រារព្ធពិធីកាន់បិណ្ឌវេនទី ៩ នាវត្តបទុមវតី ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

*ថ្ងៃទី ១៣ ខែកញ្ញា ឯកឧត្តមនាយឧត្តមសេនីយ៍ **កែ គឹម យ៉ាន** ឧបនាយករដ្ឋមន្ត្រី សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងលោកជំទាវ រួមជាមួយថ្នាក់ដឹកនាំមន្ត្រីរាជការ អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានអញ្ជើញចូលរួមកាន់បិណ្ឌវេនទី៥នៅវត្តបទុមវតី ខណ្ឌដូនពេញ រាជធានីភ្នំពេញ។*

# សកម្មភាពសមាជិកព្រឹទ្ធសភា-រដ្ឋសភា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស







*ព្រឹកថ្ងៃទី ៣ ខែកញ្ញាឆ្នាំ២០១៤ ឯកឧត្តម **វង សូត** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រួមជាមួយអង្គការកុគីសៃខេជេអូ នៃប្រទេសជប៉ុនបានចែកកង់៤០០គ្រឿងដល់កុមារក្រីក្រ និងសិស្សានុសិស្សដែលជួបការលំបាកមកពីឃុំមួយចំនួនក្នុងស្រុកពញាក្រែកខេត្តត្បូងឃ្មុំ។*

ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤ លោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី សមាជិកាគណៈអចិន្ត្រៃយ៍ គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា តំណាងរាស្ត្រមណ្ឌលស្វាយរៀង បានដឹកនាំក្រុមការងារចុះសួរសុខទុក្ខកុមារកំព្រាដែលស្នាក់នៅក្នុងមណ្ឌលរបស់រាជរដ្ឋាភិបាល និងមណ្ឌលអង្គការ ASPECA ខេត្តស្វាយរៀងដែលពិធីនេះប្រព្រឹត្តនៅក្នុងមណ្ឌលរបស់រដ្ឋាភិបាល និងមណ្ឌល អង្គការ ASPECA ។

ក្នុងឱកាសនោះលោកជំទាវឧបនាយករដ្ឋមន្ត្រី ក៏បានចែកអំណោយដល់កុមារកំព្រាទាំង២មណ្ឌលដោយក្នុងម្នាក់ៗ ទទួលបានសៀវភៅ៥ក្បាលថវិកា១ម៉ឺនរៀល និងអាហារថ្ងៃត្រង់មួយពេល។ ចំណែកអ្នកមើលថែកុមារនិងមន្ត្រីបម្រើការទាំង ២ មណ្ឌលក្នុងម្នាក់ៗទទួលបានថវិកា៦ម៉ឺនរៀល សារុង១ព្រមទាំងទឹក ក្រូច៤កេះ ទឹកត្រចៀកកាំ៥កេះ ទឹកសុទ្ធ៥កេះជូនដល់មណ្ឌលទាំង២ផងដែរ ។

*ថ្ងៃទី ៣ ខែកញ្ញា ឆ្នាំ២០១៤នេះ នៅសាលមហោស្រពខេត្ត ឯកឧត្តមទេសរដ្ឋមន្ត្រី **អ៊ឹម ឈុនលឹម** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងនគូរបនីយកម្ម និងសំណង់ តំណាងដ៏ខ្ពង់ខ្ពស់ សម្ដេចតេជោនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចែកប័ណ្ណកម្មសិទ្ធិស្របច្បាប់ជូនប្រជាពលរដ្ឋចំនួន ៣២៩ គ្រួសារ ទទួលបានប័ណ្ណកម្មសិទ្ធិស្របច្បាប់ ៣៩១ ក្បាលដី ស្ថិតនៅចំណុចភូមិគ្រង ភូមិថ្លង ឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ ។*

*យោងតាមរបាយការណ៍គណៈកម្មការដោះស្រាយដីធ្លីខេត្តក្រចេះ បានឱ្យដឹងថា រាជរដ្ឋាភិបាលបានជួលផ្ទៃដីទំហំ ៩ ៩៩៦ ហ.ត ឱ្យក្រុមហ៊ុនហឺរ៉ាយហ្សិនរបស់កូរ៉េខាងត្បូងធ្វើការ វិនិយោគកាលពីអំឡុងឆ្នាំ២០០៨ តែដោយការអនុវត្តតាមបទបញ្ជា ០១ បប ស្ដីពីគោលនយោបាយដីធ្លីរបស់រាជរដ្ឋាភិបាល តម្រូវឱ្យកាត់យកផ្ទៃដីប៉ះពាល់មួយចំនួនជូនប្រជាពលរដ្ឋនោះ ដូច្នេះទំហំដីរបស់ក្រុមហ៊ុននៅសល់ប្រមាណ ២ ៣៤៧ ហ.ត តែប៉ុណ្ណោះ ។*

ថ្ងៃទី១៥ខែកញ្ញា ឯកឧត្តម **ជា ចាន់តូ** សមាជិកគណៈអចិន្ត្រៃយ៍ គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា ទេសាភិបាលនៃធនាគារជាតិ និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះជួយស្រុកសន្ទុកខេត្តកំពង់ធំ និងលោកជំទាវបានអញ្ជើញចូលរួមជាមួយប្រជាពលរដ្ឋជិតឆ្ងាយ ព្រមទាំងពុទ្ធបរិស័ទចំណុះជើងវត្តក្នុងស្រុកសន្ទុកកាន់បិណ្ឌទី ៥ និងទី ៦ នៅវត្តចំនួន ៧ ក្នុងស្រុកសន្ទុក ។ លោកក៏បានប្រគេននូវទេយ្យទាន និងគ្រឿងឧបភោគបរិភោគមួយចំនួនផងដែរ។



# សកម្មភាពសមាជិកព្រឹទ្ធសភា_រដ្ឋសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី៤ខែកញ្ញា ឯកឧត្តម **មិន ឃិន** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ប្រធានក្រុមការងារថ្នាក់ជាតិចុះជួយស្រុកកងមាស ខេត្តកំពង់ចាម បានអញ្ជើញចូលរួមក្នុងវេទិកាសាធារណៈក្នុងគោលបំណងស្តាប់មតិយោបល់ប្រជាពលរដ្ឋចំនួន ២៩១ គ្រួសារ មកពី ១០ភូមិ ក្នុងឃុំខ្ចៅស្រុកកងមាស។





*ថ្ងៃទី១៨ខែកញ្ញា ឆ្នាំ២០១៤ ឯកឧត្តមនាយឧត្តមសេនីយ៍ **មុឹង សំផន** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋលេខាធិការក្រសួងការពារជាតិ បានអញ្ជើញជួបសំណេះសំណាល និងសួរសុខទុក្ខដល់នាយទាហាននាយទាហានរង និងពលទាហាន និងសិក្ខាកាមវគ្គបំប៉នជំនាញបើកបររថយន្តធុនធ្ងន់ជំនាន់ទី២កងពលតូចដឹកជញ្ជូនលេខ៩៩ រាជធានីភ្នំពេញ នាឱកាសបុណ្យភ្ជុំបិណ្ឌ។*



ថ្ងៃទី១៣ខែកញ្ញា ឯកឧត្តម **ឡាយ វណ្ណៈ** អភិបាលនៃគណៈអភិបាលខេត្តតាកែវ បានអញ្ជើញចូលរួមកាន់បិណ្ឌទី៥ និងនាំយកបច្ច័យ និងទេយ្យទានទៅប្រគេនព្រះសង្ឃដែលគង់ចាំព្រះវស្សានៅវត្តមង្គលមានលក្ខណ៍ ដែលស្ថិតក្នុងឃុំត្រពាំងធំខាងជើងស្រុកត្រាំកក់ខេត្តតាកែវ។



*ព្រឹកថ្ងៃទី១៤ ខែកញ្ញា ឯកឧត្តម **ស្លូត សំបូរ** អនុប្រធានគណៈពង្រឹងគណបក្សប្រជាជនកម្ពុជា ស្រុកអង្គស្នួលខេត្តកណ្តាល និងជាប្រធានក្រុមការងារចុះជួយឃុំព្រៃពួច រួមជាមួយលោក គឹម សាន់លោក ស៊ឹង សុគង់ លោក សុខ ម៉ាធឿង លោក ខៃ ម៉ាធូរេន និងលោកឧត្តមសេនីយ៍ ធន វិមានច័ន្ទ តំណាងកងវិស្វកម្មសម្តេចធម្មពោធិសាល **ជា ស៊ីម** ព្រមទាំងសហការី ដោយមានការចូលរួមពីក្រុមប្រឹក្សាឃុំភូមិចូលរួមកាន់បិណ្ឌ នៅវត្តព្រៃពួចឃុំព្រៃពួច ស្រុកអង្គស្នួល។*

# លទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច

**ចំណូលពន្ធដារក្នុងខែសីហា និងរយៈពេល ៨ ខែ :**

អគ្គនាយកដ្ឋានពន្ធដារបានបញ្ជាក់ថា នៅក្នុងខែសីហានេះ ពន្ធដាររកបានចំណូលពន្ធប្រមាណ៣៩៣,៧៧ពាន់លានរៀលគឺប្រមាណ៩៨,៤លានដុល្លារ-អាមេរិក ។ ចំណូលខែសីហានេះបានបង្ហាញឱ្យឃើញថាមានកំណើន ៨,១% បើប្រៀបធៀបនឹងចំណូលខែកក្កដា ឆ្នាំ២០១៤កន្លងទៅនិងមានកំណើនដល់ទៅ ៤២,២% បើប្រៀបធៀបនឹងចំណូលខែកក្កដា ឆ្នាំ ២០១៣ ។

ដោយឡែកក្នុងរយៈពេល៨ខែនៃឆ្នាំ ២០១៤ នេះដែរ ពន្ធដាររកចំណូលបានសរុបស្មើនឹង ៧២,៦%នៃគោលដៅកំណត់ក្នុងច្បាប់ថវិកា ក្នុងនោះថវិកាវដ្ដសម្រេចបាន៧៤,៣% និងថវិកាថ្នាក់ក្រោមជាតិសម្រេចបាន៦២,២% ។ បើប្រៀបធៀបនឹងរយៈពេលដូចគ្នា (៨ខែ) នៃឆ្នាំ ២០១៣ ចំណូល ៨ ខែនៃឆ្នាំនេះមានកំណើនស្មើនឹង ១៩% ។

បើតាមការវិភាគប្រភេទពន្ធឃើញថា ចំណូលក្នុងឆ្នាំ២០១៤ មានការកើនឡើងគ្រប់ប្រភេទពន្ធ ក្នុងនោះប្រភេទពន្ធសំខាន់ៗដែលមានការកើនឡើងមានដូចជាពន្ធលើប្រាក់បៀវត្សមានការកើនឡើងប្រមាណ ៣៣,២% ។ ពន្ធលើប្រាក់ចំណេញកើនឡើង ២៩,៣% ។ អាករលើតម្លៃបន្ថែមកើនឡើង ១៣,៩% និងអាករពិសេសមានការកើនឡើង ១០,៨% ។

បើប្រៀបធៀបទៅនឹងរយៈពេល ៨ ខែដូចគ្នានៃឆ្នាំ ២០១៣ ដោយពិនិត្យតាមវិស័យក៏ឃើញថា ចំណូលក្នុងឆ្នាំ ២០១៤ មានការកើនឡើងស្ទើរគ្រប់សកម្មភាព ក្នុងនោះផ្នែកសេវាហិរញ្ញវត្ថុកើនឡើងប្រមាណ ២០,៩១% ។ ផ្នែកស្ថាបត្យកម្ម និងសំណង់កើនឡើង ៦៧,៣៦% ។ ផលិតភេសជ្ជៈកើនឡើង ២៤,៦៥% ។ ផ្នែកផលិតសម្លៀកបំពាក់កើនឡើង៤៦,៣៥% ។ ផ្នែកសណ្ឋាគារផ្ទះសំណាក់ កើនឡើង ៤៥,៦% ។ ផ្នែកផលិតថ្នាំជក់ កើនឡើង ១៣,៤៥% ។ លក់ភេសជ្ជៈកើនឡើង ៣០,៣២% ។ ផលិតម្ហូបអាហារកើនឡើង ៧៨,៤% ។ ផ្នែកលក់សំភារៈការិយាល័យកើនឡើង ៤០,៦% ។ ផ្នែកលក់គ្រឿងយន្តកើនឡើង ៦៨,៣% និងផ្នែកលក់គ្រឿង សំណង់ក៏កើនយ៉ាងខ្លាំងគឺ ២ ៦៨៤,៣% ។

**ការនាំចូលសម្ភារៈសំណង់ឆមាសទី ១ :**

ក្រសួងពាណិជ្ជកម្មបានបង្ហាញថា ការនាំចូលសំភារៈសំណង់ពីបរទេសនៅឆមាសទី ១ នៃឆ្នាំ ២០១៤ នេះ មានចំនួនប្រមាណជាង ១,២២ លានតោនពោលគឺកើនឡើង ១៨៥% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ដែលមានចំនួនត្រឹមតែ ៤៣ ម៉ឺនតោន ។ ការកើនឡើងនេះ គឺដោយសារតែគម្រោងសាងសង់សំណង់នៅកម្ពុជា កំពុងមានសន្ទុះកើនឡើងជាខ្លាំងនៅក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ ។

បរិមាណនៃការនាំចូលសំភារៈសំណង់ពីបរទេសមកកម្ពុជានៅឆមាសទី១ នេះដែរ មានតម្លៃសរុបជាង ២២៩ លានដុល្លារ គឺកើនឡើង ២,៣% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ដែលមានតម្លៃប្រមាណ ២២៣ លានដុល្លារ ។

យោងតាមរបាយការណ៍ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់បានឱ្យដឹងថា កំណើនសេដ្ឋកិច្ចរបស់កម្ពុជាបាននិងកំពុងជំរុញឱ្យវិស័យសំណង់មានសន្ទុះរីកចម្រើនជាមួយនឹងតម្លៃទុនវិនិយោគកើនឡើងផងដែរ ។ តម្លៃទុនវិនិយោគវិស័យសំណង់នៅកម្ពុជាពីខែមករាដល់ខែធ្នូ ឆ្នាំ ២០១៣ មានទឹកប្រាក់សរុបចំនួន ២ ៧៧៣ លានដុល្លារអាមេរិក ដោយមានគម្រោងសរុប ១ ៦៤១ គម្រោង និងមានផ្ទៃក្រឡាសាងសង់ចំនួន ៧,៥ លានម៉ែត្រ ការ៉េ ។ បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ ២០១២ មានចំនួន ១ ៦៩៤ គម្រោង ស្មើនឹង ៦,៥ លានម៉ែត្រការ៉េ គិតជាទឹកប្រាក់មានចំនួនត្រឹមតែ ២ ១០៩ លាន-ដុល្លារ ។

**ការចុះបញ្ជីក្រុមហ៊ុនពាណិជ្ជកម្មរយៈ ៧ ខែ :**

ក្រសួងពាណិជ្ជកម្មបានឱ្យដឹងថា ពីខែមករាដល់ខែកក្កដា ឆ្នាំ ២០១៤ ក្រុមហ៊ុនដែលមកចុះបញ្ជីមានចំនួន ២៤២៤ ក្រុមហ៊ុន គឺបានកើនឡើង ៤៤% ។ កាលពីឆ្នាំ ២០១៣ ក្នុងរយៈពេលដូចគ្នាមានចំនួនត្រឹមតែ ១ ៦៨៨ ក្រុមហ៊ុន ។

នៅក្នុងរយៈពេល ៧ ខែនៃឆ្នាំនេះដែរ ក្រុមហ៊ុនបរទេសដែលបានមកចុះបញ្ជីមានចំនួន ១ ០៧៦ ក្រុមហ៊ុន គឺកើនឡើងប្រមាណ ៣២% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ដែលកាលណោះមានចំនួន ៨១៦ ក្រុមហ៊ុន ។ ចំណែកឯក្រុមហ៊ុនខ្មែរដែលមកស្នើសុំចុះបញ្ជិកានៅក្រសួងមានចំនួន ១ ៣៤៨ ក្រុមហ៊ុន គឺកើនឡើង ៥៤% បើធៀបនឹងចំនួន ៨៧២ ក្រុមហ៊ុន នៅក្នុងរយៈពេលដដែលកាលពីឆ្នាំ ២០១៣ ។

ក្រុមហ៊ុនបរទេសដែលមកចុះបញ្ជីនៅក្នុងរយៈពេលនេះ ភាគច្រើនជាពា-ណិជ្ជករដែលមកពីប្រទេសចិន កូរ៉េខាងត្បូង ជប៉ុន ម៉ាឡេស៊ី និងវៀតណាម ។ ក្រុមហ៊ុនទាំងនោះបានមកចុះបញ្ជីធ្វើអាជីវកម្មទៅលើផ្នែកឧស្សាហកម្មវាយនភណ្ឌនិងកាត់ដេរស្បែកជើង កសិកម្ម កសិ-ឧស្សាហកម្ម ទេសចរណ៍ និងសំណង់ជាដើម ។

គួររំឮកថា ប្រទេសកម្ពុជាបានផ្ដល់លិខិតអនុញ្ញាតប្រតិបត្តិការពាណិជ្ជកម្មឱ្យទៅក្រុមហ៊ុនថ្មីៗចំនួន ២ ៩៨៦ ក្រុមហ៊ុននៅក្នុងឆ្នាំ ២០១៣ ។ តួលេខនេះបានធ្លាក់ចុះ ១២% បើប្រៀបធៀបកាលពីឆ្នាំ ២០១២ ។ តាមការវិភាគនៅក្នុងរង្វង់ត្រីមាសទី ៤ ឆ្នាំ ២០១៤ នេះ គេរំពឹងថា ចំនួនក្រុមហ៊ុនមកចុះបញ្ជីបើកអាជីវកម្មនៅក្នុងប្រទេសនឹងមានការកើនឡើងថែមទៀត ដោយសារតែការវិលមកវិញនៃប្រក្រតីភាពនៃនយោបាយនៅក្នុងប្រទេសជាពិសេស ។

**ការនាំចេញអង្កររយៈពេល ៨ ខែ :**

របាយការណ៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានឱ្យដឹងថា នៅក្នុងរយៈពេល ៨ ខែ ឆ្នាំ ២០១៤ នេះ កម្ពុជានាំចេញអង្ករបានចំនួនប្រមាណ ២៣៣ ៨៥៩ តោន គឺមានការថយចុះប្រមាណ ២ ៨៦៩ តោន ធៀបនឹងរយៈពេលដដែលកាលពីឆ្នាំ ២០១៣ ទោះបីជាបរិមាណនៃការនាំចេញនៅក្នុងខែសីហាកន្លងទៅមានការកើនឡើងប្រមាណ ១៤៣ តោនក៏ដោយ ។

នៅក្នុងរយៈពេលនេះ ប្រទេសដែលជាអតិថិជនអង្ករកម្ពុជាច្រើនជាងគេ គឺបារាំង ដែលបានទិញអង្ករពីប្រទេសកម្ពុជាក្នុងបរិមាណសរុប ៤៨ ៨៧៧ តោន ។ ទីពីរគឺប៉ូឡូញដែលមានបរិមាណ៤៣៨២៩តោននិង ប្រទេសម៉ាឡេស៊ីឈរនៅលំដាប់ទីបី ដែលមានបរិមាណ ២១ ៧៧៣ តោន ។

ទីផ្សារនាំចេញអង្កររបស់កម្ពុជាមានប្រទេសចំនួន ៥៥ ប្រទេស ក្នុងនោះមាននៅអឺរ៉ុប អាស៊ី និងអាហ្វ្រិក និងអាមេរិកខ្លះផងដែរ ។

ដោយឡែក នៅក្នុងរយៈពេល ៨ ខែនេះដែរ ក្រុមហ៊ុនដែលនាំអង្ករចេញនោះមានទាំងអស់ ៧៤ ក្រុមហ៊ុន ក្នុងនោះ ក្រុមហ៊ុនដែលនាំចេញច្រើនជាងគេគឺក្រុមហ៊ុនខ្មែរហ្វូត ។ ទីពីរគឺក្រុមហ៊ុនអាមរូ និងក្រុមហ៊ុនទីបី គឺក្រុមហ៊ុន

ហ្គោលដិនរ៉ាយ ។

ទោះបីជាបរិមាណនៃការនាំចេញអង្ករកម្ពុជារយៈពេល ៨ខែនេះ មានការថយចុះបន្តិចក្តី ក៏ក្រសួងកសិកម្មនៅតែមានសុទិដ្ឋិនិយម នឹងអាចនាំចេញអង្ករនៅឆ្នាំ ២០១៥ ខាងមុខនេះបានមួយលានតោនដដែល ។

ប្រភេទអង្ករកម្ពុជាដែលមានទីផ្សារធំបំផុតនៅក្នុងការនាំចេញ គឺប្រភេទអង្ករក្រអូបចម្រុះ អង្ករនាំចេញលំដាប់ទីពីរ គឺអង្ករក្រអូបនាងម្លិះ បន្ទាប់មកគឺអង្ករក្រអូបសូមាលី ។

**ទំនាក់ទំនងពាណិជ្ជកម្មកម្ពុជា-ជប៉ុន :**

ស្ថានទូតជប៉ុនប្រចាំនៅកម្ពុជាបានឱ្យដឹងថា នៅក្នុងផ្នែកទំនាក់ទំនងពាណិជ្ជកម្មជាមួយប្រទេសកម្ពុជា ជប៉ុនគឺជាដៃគូពាណិជ្ជកម្មធំលំដាប់ទី ៨ របស់កម្ពុជា ។ ទំហំពាណិជ្ជកម្មនៃប្រទេសទាំងពីរមានការកើនឡើងជាលំដាប់ ពីមួយឆ្នាំទៅមួយឆ្នាំ ដែលបច្ចុប្បន្នទំហំពាណិជ្ជកម្មមានការកើនឡើងរហូតដល់ទៅ ៦ ដង ក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយ ។

យោងទៅតាមស្ថិតិពីអង្គការពាណិជ្ជកម្មក្រៅប្រទេសរបស់ជប៉ុន (JET-RO) បានឱ្យដឹងថា នៅក្នុងរយៈពេល ៧ ខែនៃឆ្នាំ ២០១៤ (ខែមករា ដល់ ខែកក្កដា) ទំហំពាណិជ្ជកម្មទ្វេភាគីប្រទេសទាំងពីរបានកើនឡើងដល់ទៅ ៥៣៨ លានដុល្លារអាមេរិក ។ នៅក្នុងរយៈពេលនេះដែរ កម្ពុជាបាននាំចេញទៅកាន់ប្រទេសជប៉ុនមានទំហំប្រមាណ ៤០៥,៣ លានដុល្លារ គឺកើនឡើងប្រមាណ ៣៨,៥% ។ ដោយឡែកសម្រាប់ទំនិញដែលកម្ពុជាទិញនាំចូលពីជប៉ុនមកវិញនៅក្នុងរយៈពេលដដែលមានទំហំប្រមាណ ១៣២,៨ លានដុល្លារ គឺកើនឡើងប្រមាណ ៤,៥% ។

ផលិតផលរបស់កម្ពុជានាំចេញទៅកាន់ទីផ្សារជប៉ុននៅពេលនេះ មានដូចជា ផលិតផលឧស្សាហកម្មកាត់ដេរ គ្រឿងទេស ដូចជា ម្រេច អង្ករ និងគ្រឿងសមុទ្រ ។ ដោយឡែក ទំនិញដែលកម្ពុជានាំចូលពីជប៉ុនមកវិញមានដូចជាយានយន្ត គ្រឿងម៉ាស៊ីន គ្រឿងសម្លាង និងសាច់សត្វជាដើម ។

ក្រៅពីវិស័យពាណិជ្ជកម្មទំហំវិនិយោគជប៉ុននៅកម្ពុជា ក៏កំពុងតែមានកំណើនប្រកបដោយភាពវិជ្ជមានផងដែរ នោះមិនគិតអំពីទំហំទឹកប្រាក់សរុបនៃជំនួយអភិវឌ្ឍន៍ផ្លូវការជប៉ុនមកកាន់ប្រទេសកម្ពុជា ដែលមានចំនួនប្រមាណ ២,៤ ពាន់លានដុល្លារឡើយ ។

ក្រុមហ៊ុនជប៉ុនដែលកំពុងតែវិនិយោគនៅក្នុងប្រទេសកម្ពុជា គឺមានដូចជាផ្សារទំនើប រោងចក្រកាត់ដេរ រោងចក្រផលិតម៉ាស៊ីនខ្នាតតូច ឧស្សាហកម្មដែករណបសម្រាប់រថយន្ត និងគ្រឿងបន្លាស់នាឡិកាជាដើម ។

**ទំនាក់ទំនងពាណិជ្ជកម្មកម្ពុជា អាមេរិក :**

តាមតួលេខពីការិយាល័យស្ថិតិរបស់សហរដ្ឋអាមេរិកដែលបានផ្សព្វផ្សាយកាលពីពេលថ្មីៗកន្លងទៅនេះបានឱ្យដឹងថា ទំហំពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា និងអាមេរិករយៈពេល ៧ ខែ (មករាដល់កក្កដា) នៃឆ្នាំ ២០១៤ មានការកើនឡើងប្រមាណ ៦,២៥% ឬស្មើនឹងតម្លៃប្រមាណ ១០៧,៨ លានដុល្លារ ។ ពីខែមករា ដល់ខែកក្កដា ឆ្នាំ ២០១៤ ទំហំពាណិជ្ជកម្មទ្វេភាគីកម្ពុជា-សហរដ្ឋអាមេរិកមានតម្លៃ ១៨៣១,៤ លានដុល្លារ បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ ២០១៣ ដែលមានតម្លៃត្រឹម ១ ៧២៣,៦ លានដុល្លារ គឺមានការកើនឡើងប្រមាណ ៦,២៥% ។

នៅក្នុងរយៈពេលដដែលនេះ សន្ទុះនៃការនាំចេញទំនិញពីប្រទេសកម្ពុជាមានការកើនឡើងប្រមាណ ៤,២៦% ។ រីឯសន្ទុះនៃទំនិញនាំចូលពីអាមេរិកមកកាន់ទីផ្សារកម្ពុជាវិញនោះ កើនឡើងរហូតដល់ទៅ ៣១,៥២% ឯណោះ ។

នៅក្នុងរយៈពេល ៧ ខែនេះ កម្ពុជានាំចេញទៅកាន់សហរដ្ឋអាមេរិកមានតម្លៃ ១ ៦៤២ លានដុល្លារ ខណៈដែលកាលពីឆ្នាំ ២០១៣ មានតម្លៃត្រឹមតែ ១ ៥៧៩ លានដុល្លារ ។ ដោយឡែក សម្រាប់ទំនិញដែលកម្ពុជានាំចូលពីសហរដ្ឋអាមេរិកវិញនោះ ក្នុងរយៈពេល ៧ ខែដូចគ្នាមានតម្លៃ ១៨៩,៤ លានដុល្លារ ។ កាលពីឆ្នាំ ២០១៣ មានត្រឹមតែ ១៤៤ លានដុល្លារ ។

រហូតមកដល់ពេលនេះ ទំនិញដែលកម្ពុជានាំចេញទៅកាន់អាមេរិក គឺនៅតែជាផលិតផលឧស្សាហកម្មកាត់ដេរ បន្ទាប់មកគឺកសិកម្មដែលមានអង្ករ ម្រេចខ្លះៗ ។ ដោយឡែក ការនាំចូលមកពីអាមេរិកវិញ មានដូចជា រថយន្ត គ្រឿងម៉ាស៊ីន ថ្នាំ និងឧបករណ៍ពេទ្យជាដើម ។

ទំនាក់ទំនងពាណិជ្ជកម្មកម្ពុជា និងអាមេរិកនៅក្នុងឆ្នាំ ២០១៤ គេរំពឹងថានឹងមានកំណើនឡើងថែមទៀត ដោយសារតែសញ្ញាដ៏ល្អនៃស្ថានភាពនយោបាយនៅក្នុងប្រទេសកម្ពុជា ខណៈដែលនៅពេលនេះក្រុមហ៊ុន អាមេរិកមួយចំនួនកំពុងតែសំឡឹងមើលលទ្ធភាព និងឱកាសវិនិយោគនៅកម្ពុជា ។

**ចំណូលរដ្ឋាករទឹកស្វយ័តភ្នំពេញ :**

យោងទៅតាមសេចក្តីប្រកាសរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ នៅក្នុងផ្សារមូលប័ត្រកម្ពុជាបានឱ្យដឹងថា ក្នុងត្រីមាសទី ២ ឆ្នាំ ២០១៤ ខ្លួនរកបានប្រាក់ចំណូលសរុបចំនួន ៤០ ០៣៧ ៩៣៦ ០០០ រៀល ។ បើធៀបនឹងត្រីមាសទី ២ ឆ្នាំ ២០១៣ មានការកើនឡើង ៦,០២% ។ នៅក្នុងប្រាក់ចំណូលនេះ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញប្រកាសប្រាក់ចំណេញសរុបចំនួនប្រមាណ ១០ ៨១៧ ៩៩១ ០០០ រៀល កើនជាងត្រីមាសទី ២ ឆ្នាំ ២០១៣ ចំនួន ២៩,៥១% ។

ទ្រព្យសកម្មសរុបរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញបានឡើងរហូតដល់ ១ ១៣០ ២៥០ ៩២៦ ០០០ រៀល និងមូលធនសរុបកើនឡើងរហូតដល់ ៧០៦ ៥៨៧ ៩៤២ ០០០រៀល ។

នៅត្រីមាសទីពីរនេះដែរ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញអាចមានសមត្ថភាពផលិតទឹកស្អាតបាន ៣៧ ៩១៥ ៦៩៧ ម៉ែត្រគូប ស្មើនឹង ១០៤% នៃផែនការ និងបានដាក់បណ្តាញចែកចាយទឹកក្នុងរាជធានីភ្នំពេញបានប្រវែង ៣០ ៨០៥ ម៉ែត្រ ។

**ចំនួនយានយន្តចុះបញ្ជី :**

ចាប់តាំងពីខែមករារហូតមកដល់ដំណាច់ខែសីហា ឆ្នាំ ២០១៤ យានយន្ត រថយន្តដែលចុះបញ្ជីត្រឹមត្រូវនៅក្រសួងសាធារណការ និងដឹកជញ្ជូនមានចំនួន ២២៣ ០១៨ គ្រឿង ក្នុងនេះម៉ូតូមានចំនួន ១៩៤ ៧៦៧ គ្រឿង និងរថយន្ត ២៨ ២៥១ គ្រឿង ។ បើប្រៀបធៀបរយៈពេលដូចគ្នានៃឆ្នាំ ២០១៣ ឃើញថាចំនួនយានយន្តចុះបញ្ជីក្នុងរយៈពេលប្រាំបីខែនៃឆ្នាំ២០១៤ នេះ មានកើនឡើងជាងពីរម៉ឺនគ្រឿង ។ ចំនួននៃការកើនឡើងមានតែម៉ូតូទេ រីឯចំនួនរថយន្តបានថយចុះ ។

គួររំឭកឱ្យដឹងថា រយៈពេលប្រាំបីខែនៃឆ្នាំ ២០១៣ យានយន្តគ្រប់ប្រភេទដែលចុះបញ្ជីមានចំនួន២០៣៧៥០ គ្រឿង ក្នុងនេះមានរថយន្តចំនួន២៩៣៧៩ គ្រឿង និងម៉ូតូចំនួន ១៧៤ ៣៧១ គ្រឿង ។ ចំនួនយានយន្តដែលកំពុងធ្វើចរាចរនៅលើផ្លូវសាធារណៈក្នុងព្រះរាជាណាចក្រកម្ពុជាពេលនេះ បានកើនដល់ប្រមាណ ២,៦លាន គ្រឿង ក្នុងនេះមានម៉ូតូចំនួន ២,៣ លានគ្រឿង ។ តួលេខនេះមិនត្រូវបានគិតបញ្ចូលយានយន្តដែលបានចុះបញ្ជីនៅក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃផងទេ ។/

# សមិទ្ធិថ្មីនៅទឹកដីទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រ

*ខណៈដែលចំនួនទេសចរជាតិ និងអន្តរជាតិ បានកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ទន្ទឹមនឹងកត្តាប្រែប្រួលនៃស្ថានភាពភូមិសាស្ត្រ កត្តារីកចម្រើននៃសំណង់នានាដែលបម្រើឱ្យវិស័យទេសចរណ៍និងការរស់នៅផងនោះ ទឹកដីនៃខេត្តសៀមរាបនិយាយជារួម និងក្រុងសៀមរាបនិយាយដោយឡែក បានប្រឈមនឹងបញ្ហាមួយចំនួននាពេលកន្លងទៅ និងបច្ចុប្បន្ន ។ ក្នុងនោះដូចជាការបង្ហូរចេញនូវកាកសំណល់រាវ ការយាយីដោយជំនន់ទឹកភ្លៀងដែលហៀរចេញពីស្ទឹងសៀមរាប ពីបឹងទន្លេសាប ។ល ។ ប៉ុន្តែសមិទ្ធផលថ្មីដែលមានតម្លៃជិត ៣០ លានដុល្លារអាមេរិក កំពុងតែរួមចំណែកដោះស្រាយនូវបញ្ហាប្រឈមនៃក្រុងទេសចរណ៍ដ៏ធំរបស់កម្ពុជាមួយនេះបានមួយផ្នែកធំ ។*



*ឯកឧត្តម **យឹម ឆៃលី** កាត់ខ្សែបូសម្ពោធដាក់ឱ្យប្រើប្រាស់ស្ថានីយចម្រោះទឹកសំណល់ប្រព័ន្ធលូបង្ហូរ និងស្ពានស្ទឹងសៀមរាប*

ស្ថានីយចម្រោះទឹកសំណល់ប្រព័ន្ធលូបង្ហូរ និងស្ពានស្ទឹងសៀមរាប បានសម្ពោធដាក់ឱ្យប្រើប្រាស់កាលពីព្រឹកថ្ងៃទី ២៨ ខែសីហា ឆ្នាំ ២០១៤ កន្លងទៅក្រោមអធិបតីភាពរបស់ឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកជាប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ តំណាងដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តម **ត្រាំ អ៊ីវតឹក** រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ឯកឧត្តម **គីម ហានស៊ូ** (KIM HAN SOO) ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋកូរ៉េប្រចាំព្រះរាជាណាចក្រកម្ពុជា ។ ស្ថានីយនេះមានទីតាំងស្ថិតនៅភូមិកន្ទ្រាក សង្កាត់ស្វាយដង្គុំ ក្រុងសៀមរាប ខេត្តសៀមរាប ។

បើតាមការបញ្ជាក់របស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ស្ថានីយមួយនេះចំណាយថវិកាចំនួន ២៩,៩៦ លានដុល្លារអាមេរិក ជាមួយនឹងថវិកាបដិភាគរបស់រាជរដ្ឋាភិបាល ក្នុងដោះស្រាយផលប៉ះពាល់មួយចំនួនផង ។ គម្រោងនេះបានចាប់ផ្តើមសាងសង់នៅថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ២០១១ និងបានបញ្ចប់នៅថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០១៤ ដោយប្រើរយៈពេលស្ទាបនា ៣២ ខែ ។ ក្រុមហ៊ុន KUM-HO-KUKDONG-KYUNGAN Join Venture បានទទួលសិទ្ធិក្នុងការសាងសង់ និងត្រួតពិនិត្យបច្ចេកទេសដោយក្រុមហ៊ុន Kunhwa Engineering & Consulting in association with Yooshin Engineering Corporation ។ ថវិកាដែលយកមកប្រើប្រាស់គឺក្រោមកម្ចីឥណទានពីធនាគារអាហ័រណេនីហ័រណៃនៃសាធារណរដ្ឋកូរ៉េ ។

ស្ថានីយចម្រោះទឹកសំណល់ប្រព័ន្ធបង្ហូរ និងការស្តារស្ទឹងសៀមរាប មានវិសាលភាពគ្របដណ្តប់ប្រមាណ ១០,៨៣ គីឡូម៉ែត្រក្រឡា លើតំបន់ដែលមានប្រជាពលរដ្ឋរស់នៅច្រើនមានប្រព័ន្ធទឹកស្អាតប្រើប្រាស់ និងជាតំបន់មានអ្នកទេសចរច្រើននៃភាគខាងកើត និងខាងលិចក្រុងសៀមរាប ។ គួររំឭកថា ប្រព័ន្ធដែលមានស្រាប់ ដែលសាងសង់ឡើងដោយឥណទានពីធនាគារអភិវឌ្ឍន៍អាស៊ី ហើយបើកឱ្យប្រើប្រាស់កាលពីឆ្នាំ ២០១០ កន្លងទៅ គឺមានត្រឹមតែ ២,៦៤ គីឡូម៉ែត្រក្រឡានៃផ្នែកកណ្តាលក្រុងសៀមរាបតែប៉ុណ្ណោះ ។ តែហេដ្ឋារចនាសម្ព័ន្ធដែលបានសាងសង់រួចរាល់នាពេលនេះរួមមាន : ស្ថានីយចម្រោះទឹកសំណល់ដែលមានសមត្ថភាព ៥ ២២៤ ម៉ែត្រត្រីគុណ ប្រឡាយបេតុងប្រវែង ៤,៨៥ គីឡូម៉ែត្រ បំពង់បង្ហូរទឹកសំណល់ប្រវែង ១៣,១២ គីឡូម៉ែត្រ ស្ថានីយបូមបន្តពីរកន្លែងមានសមត្ថភាព ១៣ ១២៧ ម៉ែត្រត្រីគុណ/មួយថ្ងៃ និង ១១ ៣៣៩ ម៉ែត្រត្រីគុណ/មួយថ្ងៃ ស្តារស្ទឹងសៀមរាបប្រវែង ៣,៣៩ គីឡូម៉ែត្រ ។

ហេដ្ឋារចនាសម្ព័ន្ធថ្មីខាងលើនេះ រួមនឹងប្រព័ន្ធដែលមានស្រាប់ នឹងបំពេញបន្ថែមនូវសមត្ថភាពប្រមូលកាកសំណល់រាវនៅតាមលំនៅស្ថានប្រជាពលរដ្ឋ ភោជនីយដ្ឋាន សណ្ឋាគារ រោងសិប្បកម្ម សហគ្រាស ស្ថាប័នសាធារណៈ និងឯកជនទាំងអស់ដែលស្ថិតនៅផ្នែកខាងកើត និងខាងលិចក្រុងសៀមរាប បញ្ចូលទៅក្នុងអាងចម្រោះទឹកដែលមានប្រព័ន្ធប្រព្រឹត្តកម្មដើម្បីចម្រោះសម្អាតកាកសំណល់បន្ថយភាពកខ្វក់ក្លិន និងជាតិពុលជាបន្តបន្ទាប់ឱ្យនៅកម្រិតទាបមុនពេលបង្ហូរចូលទៅក្នុងបឹងទន្លេសាបដោយពុំមានប៉ះពាល់ដល់បរិស្ថាន និងអាយុជីវិតមនុស្ស សត្វ ឬរុក្ខជាតិឡើយ ហើយទឹកនេះអាចបង្ហូរទៅតាមប្រព័ន្ធស្រោចស្រពដែលមានស្រាប់សម្រាប់ផ្ទៃដីកសិកម្មចំនួន ២៨០ ហិកតាទៀតផងដែលស្ថិតនៅក្រោមស្ថានីយចម្រោះ ។

ឯកឧត្តម **ត្រាំ អ៊ីវតឹក** បានបញ្ជាក់ថា ប្រព័ន្ធរចនាសម្ព័ន្ធលូបង្ហូរ និងចម្រោះនេះជាហេដ្ឋារចនាសម្ព័ន្ធមួយថ្មីមានសារប្រយោជន៍បំផុតរបស់ខេត្តសៀមរាប ។ ប្រព័ន្ធនេះអាចគ្របដណ្តប់ និងបម្រើឱ្យផ្នែក



*ស្ថានីយចម្រោះទឹកសំណល់ប្រព័ន្ធលូបង្ហូរ និងស្ពារស្ទឹងសៀមរាប*

មួយយ៉ាងធំរបស់ក្រុងសៀមរាប គឺផ្នែកខាងកើតស្ទឹង និងផ្នែកខាងលិចស្ទឹងបន្ថែមទៀតដែលស្របទៅតាមតម្រូវការ នៃការរស់នៅរបស់ប្រជាពលរដ្ឋ និងរួមចំណែកយ៉ាងធំបម្រើវិស័យទេសចរណ៍ និងការអភិវឌ្ឍក្រុងសៀមរាប អង្គរ ដែលជាបេះដូងនិងជាព្រលឹងរបស់កម្ពុជា និងប្រជាពលរដ្ឋខ្មែរគ្រប់រូប ។

គេអាចដាក់ជាសំណួរថា ហេតុអ្វីបានជាចាំបាច់ត្រូវបង្កើតនូវស្ថានីយមួយដែលមានតម្លៃខ្ពស់នេះ? ពិតណាស់ នារយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ក្រុងសៀមរាបមានការអភិវឌ្ឍយ៉ាងឆាប់រហ័សនូវវិស័យទេសចរណ៍ រួមទាំងសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងផ្ទះប្រជាពលរដ្ឋ ។ អ្វីៗទាំងនេះបានបង្ហូរទឹកកខ្វក់ចូលទៅប្រព័ន្ធប្រឡាយក្នុងក្រុង ហើយបានបង្កភាពកខ្វក់យ៉ាងធ្ងន់ធ្ងរ ។ ម្យ៉ាងដោយសារតែខ្វះការថែទាំ និងការទន្ទ្រានស្នាក់នៅ បណ្ដាលឱ្យកកស្ទះអន្លើៗ ធ្វើឱ្យប៉ះពាល់សុខភាពប្រជាពលរដ្ឋ អ្នកទេសចរ ព្រមទាំងបំផ្លាញដល់ជីវចម្រុះក្នុងបឹងទន្លេសាប រួមទាំងបរិស្ថាន និងជីវធម្មជាតិផងដែរ ។

សំខាន់ជាងនេះទៀត គឺស្ទើរតែជារៀងរាល់ឆ្នាំ ក្រុងសៀមរាប និងតំបន់ជុំវិញ តែងតែជួបប្រទះនូវការជន់លិចនៅរដូវវស្សា ដែលរងឥទ្ធិពលព្យុះទីហ្វុង ដូចជាព្យុះកេតសាណាកាលពីប៉ុន្មានឆ្នាំមកជាដើម រួមនិងឥទ្ធិពលនៃរបបទឹកភ្លៀងដ៏ច្រើនធ្លាក់ចុះយ៉ាងគំហុកពីតំបន់ខ្ពង់រាបខាងជើងនៃជួរភ្នំដងរែក និងពីតំបន់ជួរភ្នំគូលែនហូរចុះតាមស្ទឹងសៀមរាប បង្កឱ្យកម្ពស់ទឹកស្ទឹងសៀមរាបឡើងខ្ពស់ហៀរច្រាំង បណ្ដាលឱ្យជន់លិចលង់ និងហូរកាត់ក្រុងសៀមរាប និងតំបន់ជុំវិញ ពិសេសតំបន់កណ្ដាលទីក្រុងដែលជាតំបន់ពាណិជ្ជកម្ម សណ្ឋាគារ ផ្ទះសំណាក់ សាលារៀន លំនៅស្ថានប្រជាពលរដ្ឋជាដើម ធ្វើឱ្យរំខានដល់ការធ្វើអាជីវកម្ម ការរស់នៅរបស់ប្រជាពលរដ្ឋ ការកំសាន្ត ការស្នាក់នៅរបស់ទេសចរជាតិ និងអន្តរជាតិ ព្រមទាំងខូចខាតទ្រព្យសម្បត្តិ អាយុជីវិតមនុស្សសត្វពាហនៈថែមទៀតផង ។ មួយចំណែកទៀតទីក្រុងសៀមរាបក៏ទទួលឥទ្ធិពលខ្លាំងផងដែរពីឥទ្ធិពលទឹកជំនន់ នៃបឹងទន្លេសាប ។ ជាក់ស្ដែងដូចជាកាលពីឆ្នាំ ២០១១ ក្រុងសៀមរាប និងតំបន់ជុំវិញបានរងគ្រោះយ៉ាងធ្ងន់ធ្ងរជាបន្តបន្ទាប់រហូតដល់ទៅ ៥ ដង ដែលបណ្ដាលមកពីព្យុះទីហ្វុង ជំនន់ទឹកភ្លៀងធ្លាក់ជាប់ៗគ្នា ជំនន់បឹងទន្លេសាប ព្រមទាំងជំនន់ពីប្រទេសថៃថែមទៀត ដែលធ្វើឱ្យលិចលង់ និងខូចខាតយ៉ាងដំណំដល់ហេដ្ឋារចនាសម្ព័ន្ធទីក្រុង មាន ផ្លូវ ស្ពាន ផ្សារ សាលារៀន ផ្ទះសម្បែង សណ្ឋាគារ ផ្ទះសំណាក់ទីទួលប្រាសាទមួយចំនួន ពិសេសមានការគំរាមកំហែងដោយផ្ទាល់ភ្ញៀវទេសចរអន្តរជាតិនៅប្រាសាទបន្ទាយស្រីជាដើម ។

គឺផ្ដើមចេញពីស្ថានភាពធ្ងន់ធ្ងរនៃទីក្រុងទេសចរណ៍មួយនេះ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានផ្ដល់អនុសាសន៍ឱ្យក្រសួងសាធារណការ និងដឹកជញ្ជូនដោះស្រាយកង្វល់មួយនេះ តាមរយៈនៃការរៀបចំឱ្យប្រសើរឡើងវិញនូវស្ថានភាពដែលជួបការគំរាមកំហែងជាបន្តបន្ទាប់ តាមរយៈការរៀបចំហេដ្ឋារចនាសម្ព័ន្ធចម្រោះបង្ហូរដោះទឹកចេញពីតំបន់រងគ្រោះ ។

ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូនបានបញ្ជាក់ថា ដោយទទួលនូវអនុសាសន៍នេះក្រសួង បានខិតខំចរចាស្វែងរកជំនួយជាថវិកាបន្ថែមពីដៃគូអភិវឌ្ឍន៍ និងប្រទេសជាមិត្តនានាដើម្បីសាងសង់បន្ថែមនូវស្ថានីយចម្រោះទឹកសំណល់ និងប្រព័ន្ធលូបង្ហូរ និងស្ពារស្ទឹងសៀមរាបនេះឡើង ។ ទាំងនេះ គឺដើម្បីប្រមូលទឹកសំណល់ យកទៅច្រោះសម្អាតមុនពេលបង្ហូរចេញទៅបឹងទន្លេសាប ចៀសវាងការបំពុលបរិស្ថានទឹកទាំងផ្នែកក្រោមដី និងផ្នែកខាងលើដី និងដើម្បីការពារទឹកជំនន់ដែលជន់លិចដល់ក្រុងសៀមរាប ។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **យឹម ឆៃលី** ដែលអញ្ជើញចូលរួមក្នុងការប្រកាសដាក់ឱ្យដំណើរការជាផ្លូវការនូវសមិទ្ធិថ្មីមួយនេះ បានទាញអារម្មណ៍ភ្ញៀវជាតិ អន្តរជាតិ និងប្រជាពលរដ្ឋដែលមានវត្តមាននាពេលនោះ ថាការសាងសង់ហេដ្ឋារចនាសម្ព័ន្ធគ្រប់វិស័យនៅទូទាំងប្រទេសអាចសម្រេចបានជោគជ័យ គឺអាស្រ័យដោយការខិតខំប្រឹងប្រែង និងការយកចិត្តទុកដាក់ និងឆន្ទៈមោះមុតរបស់រាជរដ្ឋាភិបាលដែលមានសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាប្រមុខដ៏ឆ្នើម និងឈ្លាសវៃបានលះបង់នូវកម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី និងពេលវេលាដើម្បីបុព្វហេតុជាតិប្រជាជន ថែរក្សាសុខសន្តិភាព ស្ថិរភាពនយោបាយ និងស្វះស្វែងរកប្រភពធនធាន មកជំរុញការស្តារ និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ពិសេសរចនាសម្ព័ន្ធសាធារណៈក្នុងទីក្រុង មានបណ្ដាញ ផ្លូវ ស្ពាន ស្ថានីយចម្រោះ និងប្រព័ន្ធលូបង្ហូរទឹក ប្រព័ន្ធការពារបរិស្ថានអេកូឡូស៊ី និងប្រព័ន្ធការពារទឹកជំនន់ជាដើម ។

សមិទ្ធិដ៏ថ្លៃថ្លានេះនឹងជួយជំរុញដល់ការកសាង និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តចាំបាច់សម្រាប់ខេត្តសៀមរាប ដែលជាខេត្តកំពុងមានការរីកចម្រើន មានសក្ដានុពល និងជាប៉ូលសេដ្ឋកិច្ចដ៏សំខាន់របស់កម្ពុជា ។/

# គោលដៅអាទិភាព ៣ របស់ក្រសួងបរិស្ថាន និង លទ្ធផលការងារជិតមួយឆ្នាំនេះ



*ឯកឧត្តម **សាយ សំអាល់** ក្នុងឱកាសសម្ពោធដាក់ឱ្យប្រើប្រាស់សួនបណ្ដុះកូនឈើនៅសហគមន៍ការពារធម្មជាតិ ជីខិក បឹងប្រិយ ក្នុងខេត្តព្រះវិហារ*

ដើម្បីអនុវត្តទិសដៅនៃការងារបរិស្ថានរបស់រាជរដ្ឋាភិបាល នីតិកាលទី ៥ ដឹកនាំដោយសម្ដេចតេជោ **ហ៊ុន សែន** ក្រសួងបរិស្ថានបានរៀបចំពង្រឹងសមត្ថភាពស្ថាប័នតាមរយៈការកែសម្រួលមុខងារ រចនាសម្ព័ន្ធ គ្រប់គ្រងរបស់ក្រសួង ការកែសម្រួលរបៀបរបបការងារ ទាំងក្នុងកិច្ចការគ្រប់គ្រងបុគ្គលិករដ្ឋបាល និងហិរញ្ញវត្ថុសំដៅធ្វើទំនើបកម្មស្ថាប័ន បង្កើនប្រសិទ្ធភាពការងារ ដើម្បីសម្រេចនូវបេសកកម្មរបស់ក្រសួងលើគោលដៅអាទិភាពចំនួនបី គឺកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប ។

ជាក់ស្ដែងក្នុងរយៈពេលជិត ១ឆ្នាំកន្លងមកនេះ ក្រសួងបានសម្រេចលទ្ធផលលើកិច្ចការ ចំនួន ៨ គឺ :



*ក្រសួងបរិស្ថានយកចិត្តទុកដាក់លើបញ្ហាបរិស្ថាន នៅតាមរមណីយដ្ឋានប្រវត្តិសាស្ត្រ និងធម្មជាតិ*

១-ការពង្រឹងសមត្ថភាពមន្ត្រីរាជការ តាមរយៈការបណ្ដុះបណ្ដាលជំនាញរដ្ឋបាល និងគ្រប់គ្រងហិរញ្ញវត្ថុ នៅសាលាភូមិន្ទរដ្ឋបាល ។

២-ជំរុញឱ្យមានការបង្កើតគម្រោងស្រាវជ្រាវដើម្បីជាមូលដ្ឋានដល់ការរៀបចំគោលនយោបាយ ។

៣-រៀបចំឱ្យមានយន្តការសម្រាប់សម្របសម្រួលលើការងារគ្រប់គ្រងឧទ្យានជាតិភ្នំគូលែន ។

៤-រៀបចំឱ្យមានយន្តការអន្តរក្រសួង ដើម្បីកំណត់ព្រំដីតំបន់ការពារធម្មជាតិ ។

៥-រៀបចំឱ្យមានកិច្ចប្រជុំ ពិគ្រោះយោបល់ជាមួយក្រុមហ៊ុនវិនិយោគលើដីសម្បទានសេដ្ឋកិច្ច ។

៦-ពង្រឹងការផ្សព្វផ្សាយ និងអប់រំអំពីបរិស្ថាន ដល់សាធារណជន ។

៧-រៀបចំយន្តការសម្របសម្រួលលើការប្រើប្រាស់ធនធានធម្មជាតិឱ្យមានចីរភាព ។

៨-យកចិត្តទុកដាក់ជួយដោះស្រាយបញ្ហាជីវភាពជូនមន្ត្រីរាជការក្រោមឱវាទក្រសួង ។ ជាមួយគ្នានេះ ក្រសួងបានពង្រឹងទំនាក់ទំនង និងកិច្ចសហការជាមួយបណ្ដាក្រសួង ស្ថាប័ន អាជ្ញាធរដែនដី និងកងកម្លាំងមានសមត្ថកិច្ចពាក់ព័ន្ធគ្រប់ប្រភេទ ក្នុងការបំពេញមុខងារ និងតួនាទី ដើម្បីធានានូវគុណភាពបរិស្ថាន តាមរយៈការគ្រប់គ្រង សំណល់រឹងរាវ និងការទប់ស្កាត់ការបំពុលបរិស្ថានគ្រប់ប្រភេទ ក៏ដូចជាដើម្បីធានានូវការថែរក្សា ការពារ និងអភិរក្សជីវៈចម្រុះ តាមរយៈការទប់



*កិច្ចប្រជុំលើការគ្រប់គ្រងបរិស្ថានតំបន់ឆ្នេរសមុទ្រកម្ពុជា*



*វគ្គបណ្ដុះបណ្ដាលគ្រូបង្គោលស្ដីពីសហគមន៍ទេសចរណ៍ និងមន្ត្រីឧទ្យានុរក្ស ជាមគ្គុទ្ទេសក៍ទេសចរណ៍ ក្នុងតំបន់ការពារធម្មជាតិ ខេត្តសៀមរាប*



*ក្រសួងបរិស្ថាន បាន និងកំពុងរឹតបន្តឹងការអនុវត្តវិធានការទប់ស្កាត់បទល្មើសព្រៃឈើគ្រប់ប្រភេទ រួមទាំងពង្រឹងកិច្ចសហប្រតិបត្តិការយ៉ាងស្អិតរមួតជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ*

ស្កាត់បទល្មើសគ្រប់ប្រភេទ នៅក្នុងតំបន់ការពារធម្មជាតិ ដែលរួមមាន : ឧទ្យានជាតិដែនជម្រកសត្វព្រៃ តំបន់ការពារទេសភាព និងតំបន់ប្រើប្រាស់ច្រើនយ៉ាង ។ ក្រសួងក៏បាន និងកំពុងជំរុញឱ្យមានការសិក្សាស្រាវជ្រាវ វាយតម្លៃហេតុប៉ះពាល់បរិស្ថានលើធនធានធម្មជាតិ ដើម្បីជូនយោបល់ទៅក្រសួងជំនាញដែលពាក់ព័ន្ធនឹងការធ្វើអាជីវកម្មនានា សំដៅធានាការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប ។ ក្រសួងនឹងបន្តអនុវត្តការងារឱ្យបានជោគជ័យ ធ្វើឱ្យកម្ពុជាមានបរិស្ថានល្អ និងការអភិវឌ្ឍដោយចីរភាព ។

### ចំពោះវិធានការទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើ ការទន្ទ្រានកាន់កាប់ដីដោយខុសច្បាប់នៅតំបន់ការពារធម្មជាតិ

ឯកឧត្ដម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានមានប្រសាសន៍ថា : ក្រសួងបាន និងកំពុងរឹតបន្តឹងការអនុវត្តវិធានការទប់ស្កាត់បទល្មើសគ្រប់ប្រភេទ រួមទាំងពង្រឹងកិច្ចសហប្រតិបត្តិការយ៉ាងស្អិតរមួត ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ តាមរយៈការចេញសេចក្ដីប្រកាសរួមគ្នា ដើម្បីទប់ស្កាត់រាល់សកម្មភាពបំផ្លិចបំផ្លាញព្រៃឈើ និងការទន្ទ្រានកាន់កាប់ដីដោយខុសច្បាប់ ។ ជាក់ស្ដែងក្រសួងបរិស្ថានបានធ្វើការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងពាណិជ្ជកម្ម ក្រសួងរ៉ែ និងថាមពល និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយបណ្ដាប្រទេសជាមិត្ត ដៃគូអភិវឌ្ឍន៍និងអង្គការជាតិ អន្តរជាតិ ក្នុងការកំណត់ព្រំដីតំបន់ឧទ្យានជាតិ តំបន់ការពារទេសភាព ដែនជម្រកសត្វ សំដៅទប់ស្កាត់ការចូលទន្ទ្រានកាន់កាប់ដីធ្លីដោយខុសច្បាប់ ពីសំណាក់ជនខិលខូចមួយចំនួនតូច ។

ក្រសួងក៏បានសម្របសម្រួលជាមួយស្ថាប័ន និងភាគីពាក់ព័ន្ធនានា ដើម្បីដោះស្រាយបញ្ហាប្រឈមនានា ដែលកើតមាននៅក្នុងសហគមន៍មូលដ្ឋាន ។ ក្រសួងបរិស្ថានបានចាត់វិធានការតាមផ្លូវច្បាប់លើជនទាំងឡាយ ដែលរំលោភបំពានច្បាប់ និងបំផ្លិចបំផ្លាញធនធានធម្មជាតិ ។ ប្រសិនបើនរណាប្រព្រឹត្តខុស អ្នកនោះត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ។ ជាពិសេស ក្រសួងបានព្រមានដល់មន្ត្រីបរិស្ថានទាំងអស់ឱ្យប្រុងប្រយ័ត្នចំពោះទង្វើរបស់ខ្លួន ចៀសវាងពាក់ព័ន្ធនឹងបទល្មើសបំផ្លិចបំផ្លាញព្រៃឈើ និងទន្ទ្រានកាន់កាប់ដីធ្លី ។

### យន្តការដោះស្រាយបញ្ហាវិវាទដីធ្លីមួយចំនួនជាមួយក្រុមហ៊ុនដែលទទួលបានដីសម្បទានសេដ្ឋកិច្ចពីរាជរដ្ឋាភិបាលកម្ពុជា

ឯកឧត្ដម **សាយ សំអាល់** បានមានប្រសាសន៍ថា ក្រសួងបរិស្ថាន និងស្ថាប័នពាក់ព័ន្ធនានា បានយកចិត្តទុកដាក់ខ្ពស់ចំពោះការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច និងការពារផលប្រយោជន៍របស់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់នោះ និងបញ្ចៀសឱ្យបាននូវជម្លោះដីធ្លីជាមួយក្រុមហ៊ុនវិនិយោគលើដីសម្បទានសេដ្ឋកិច្ចនានា ។ ក្នុងស្មារតីនេះ ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី ៩ ខែឧសភា ឆ្នាំ ២០១៤ លើប្រកាសអន្តរក្រសួងស្ដីពីការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច ។ ប្រកាសនេះមានគោលដៅពង្រីកការអនុវត្តបទប្បញ្ញត្តិ និងបច្ចេកទេសនានា ដែលទាក់ទងនឹងការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីឱ្យគម្រោងទាំងអស់ធានាបាននូវការអភិវឌ្ឍប្រកបដោយចីរភាព តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព ។ ក្រុមហ៊ុនវិនិយោគដែលមានដីសម្បទានសេដ្ឋកិច្ចទាំងអស់ ត្រូវអនុវត្តតាមគោលការណ៍ដែលបានសម្រេច រួមមានគម្រោងវិនិយោគរបស់ក្រុមហ៊ុនត្រូវអនុវត្តតាមគោលការណ៍រូបមន្ត ស្បែកខ្លា ដោយត្រូវធានាថា មិនត្រូវធ្វើឱ្យប៉ះពាល់ដីធ្លីប្រើប្រាស់អាស្រ័យផលរបស់ប្រជាជន ដីព្រៃសម្បទាន ដីព្រៃសហគមន៍និងដីអភិរក្សដែលត្រូវថែរក្សា ។ ជាមួយគ្នានេះ ក្រសួងបរិស្ថានកំពុងសិក្សាដើម្បីកាត់បន្ថយ រយៈពេលនៃការផ្ដល់ដីសម្បទានសេដ្ឋកិច្ចដល់ក្រុមហ៊ុនវិនិយោគនានា និងធ្វើការត្រួតពិនិត្យជាប្រចាំលើរាល់ គម្រោងអភិវឌ្ឍន៍នានា ដែលត្រូវគោរពតាមលក្ខណៈបច្ចេកទេស និងគោរពបទដ្ឋានបរិស្ថានត្រឹមត្រូវ ។ កន្លងមកនេះក្រសួងបានទទួលមកវិញនូវដីសម្បទានសេដ្ឋកិច្ចមួយចំនួន ដែលក្រុមហ៊ុនវិនិយោគយល់ព្រមផ្ដល់ត្រឡប់មករាជរដ្ឋាភិបាលវិញ ហើយក្រសួងបានកំណត់ឡើងវិញនូវតំបន់ទាំងនោះ ដើម្បីគ្រប់គ្រង និងការពារឱ្យបានល្អ ។ ម្យ៉ាងទៀតក្រសួងបានខិតខំប្រឹងប្រែងក្នុងការធ្វើសេចក្ដីព្រាងច្បាប់ស្ដីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលច្បាប់នេះនឹងក្លាយជាលិខិតបទដ្ឋានគតិយុត្តដ៏មានសារៈសំខាន់សម្រាប់ជំរុញនិងលើកកម្ពស់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅកម្ពុជា ដើម្បីសម្រេចបាននូវកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប ។

លទ្ធផលកិច្ចសហការជាមួយស្ថាប័នឯកជន និងដៃគូអភិវឌ្ឍន៍ដើម្បីកិច្ចគាំពារលើវិស័យបរិស្ថាន ។ ក្រសួងបរិស្ថានបានធ្វើកិច្ចសហប្រតិបត្តិការយ៉ាងស្អិតរមួតជាមួយផ្នែកឯកជន ដើម្បីតាមដានលើដំណើរការ



*ទិដ្ឋភាពព្រៃឈើលើខ្ពង់រាបនៃតំបន់ ឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម ភ្នំគូលែន*

អភិវឌ្ឍន៍ ក៏ដូចជាស្នើធ្វើប្រតិបត្តិលើកិច្ចការពារបរិស្ថាន ដើម្បីកាត់បន្ថយផលប៉ះពាល់បរិស្ថានដែលបង្កឡើង ពីការអនុវត្តគម្រោងវិនិយោគរបស់ខ្លួន ។ ក្រសួងបរិស្ថានបានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការ ដែលមានជាមួយដៃគូអភិវឌ្ឍន៍នានា ដូចជាសហភាពអឺរ៉ុបជាដើម ។ ដោយសារតែកិច្ចសហការនេះ មន្ត្រីរាជការរបស់ក្រសួងបរិស្ថានបានទទួលនូវការបណ្តុះបណ្តាល បំពាក់បំប៉នបន្ថែមលើជំនាញរបស់ខ្លួន ដើម្បីបង្កើនប្រសិទ្ធភាពការងារ ។ ដៃគូអភិវឌ្ឍន៍បានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសលើការអនុវត្តគម្រោងមួយចំនួនរបស់ក្រសួង ។ ប្រសិនបើគ្មានការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុបន្ថែមពីដៃគូអភិវឌ្ឍន៍ទេនោះ យើងអាចនឹងប្រឈមមុខនឹងការលំបាកលើការអនុវត្តគម្រោង ។ ម្យ៉ាងទៀតទាំងដៃគូអភិវឌ្ឍន៍ និងផ្នែកឯកជន ក្រុមហ៊ុនវិនិយោគបានដើរតួនាទីយ៉ាងសំខាន់ជាកម្លាំងចលករ ដើម្បីបង្កើតការងារ ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា ព្រមទាំងបានចូលរួមគាំពារបរិស្ថាន ការអភិរក្ស ជីវៈចម្រុះ និងធានាថាការប្រើប្រាស់ធនធានធម្មជាតិ ត្រូវបានធ្វើឡើងសមស្រប និងប្រកបដោយនិរន្តរភាព ។ ក្រសួងបរិស្ថានបានជួបប្រជុំជាមួយក្រុមហ៊ុនវិនិយោគគម្រោងអភិវឌ្ឍន៍ ដើម្បីពិនិត្យលើវឌ្ឍនភាពនៃការអនុវត្តគម្រោងនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាពនៃតំបន់ការពារធម្មជាតិ ។ គោលបំណងសំខាន់នៃកិច្ចប្រជុំនេះ គឺ ពិនិត្យប្រសិទ្ធភាពនៃការគ្រប់គ្រងគម្រោងវិនិយោគលើវិស័យមួយចំនួនដូចជាកសិឧស្សាហកម្ម ទេសចរណ៍ ការសាងសង់ទំនប់វារីអគ្គិសនី និងការរុករករ៉ែនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាពនៃតំបន់ការពារធម្មជាតិ ព្រមទាំងពិនិត្យដោះស្រាយបញ្ហាប្រឈមនានា ដែលកំពុងកើតមានពាក់ព័ន្ធនឹងគម្រោងវិនិយោគអភិឌ្ឍន៍ទាំងនេះ ជាពិសេសគឺការអនុវត្តបទបញ្ជាលេខ ០១ ចុះថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០១២ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីវិធានការពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច ។ ក្រសួងក៏បានជំរុញឱ្យក្រុមហ៊ុនវិនិយោគទាំងអស់ បន្តខិតខំអនុវត្តគម្រោងដោយគោរពតាមកិច្ចសន្យា នីតិវិធី និងគោលការណ៍ច្បាប់ជាធរមាន ដើម្បីរួមចំណែកដល់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលអាចឆ្លើយតបទៅនឹងកិច្ចគាំពារបរិស្ថាន ការអភិរក្ស ជីវចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប ។

នៅក្នុងទិវាបរិស្ថានជាតិ និងទិវាបរិស្ថានអន្តរជាតិនៅឆ្នាំ ២០១៤ ឯកឧត្តម **សាយ សំអាល់** បានលើកឡើងថា ឆ្នាំ២០១៤ នេះ ពិភពលោកបានប្រារព្ធទិវាបរិស្ថាន ក្រោមប្រធានបទ "រួមគ្នាទប់ស្កាត់កំណើនកម្ពស់ទឹកសមុទ្រ" ដែលឆ្លុះបញ្ចាំងអំពីតថភាពនៃស្ថានភាពបរិស្ថានភពផែនដី និងមានបង្កប់នូវអត្ថន័យអប់រំអំពីសកម្មភាពការពារបរិស្ថាន រួមទាំងបញ្ហានានាដែលពិភពលោកកំពុងប្រឈម ។ ឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ ដែលរួមមានការកើនឡើងកម្តៅនៃភពផែនដី រដូវកាលមិនទៀងទាត់ គ្រោះរាំងស្ងួត គ្រោះទឹកជំនន់ និងខ្យល់ព្យុះ បានបង្កឱ្យបណ្តាប្រទេសទាំងអស់លើសកលលោក ជាពិសេស ប្រទេសដែលអាស្រ័យលើកសិកម្មទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដោយសារតែសមត្ថភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៃប្រទេសទាំងនោះនៅមានកម្រិត ។នៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រទេសកម្ពុជាយើងក៏បានប្រឈមនឹងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតដែលបង្កគ្រោះថ្នាក់ដល់អាយុជីវិតហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងខាតបង់ខាងសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរដែរ ។ឆ្លើយតបទៅនឹងបញ្ហាទាំងនេះ រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុក កិច្ចការពារបរិស្ថានជាវិធានការដ៏ចាំបាច់បំផុត ដើម្បីធានាចីរភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ។ជាក់ស្តែង ឆ្នាំ ២០១៤នេះ រាជរដ្ឋាភិបាលបានអនុម័ត ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣ ដោយមានចក្ខុវិស័យគាំទ្រឱ្យកម្ពុជាអភិវឌ្ឍឆ្ពោះទៅរកសង្គមមួយ ដែលបៃតងបញ្ចេញកាបូនតិច ធន់នឹងការប្រែប្រួលអាកាសធាតុ សមធម៌ចីរភាព និងពឹងផ្អែកលើចំណេះដឹងជាគោល ។ ផែនការនេះជាត្រីវិស័យសម្រាប់តម្រង់ទិសសកម្មភាព ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា ទាំងវិធានបន្សាំ និងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ សំដៅធានាឱ្យបាននូវការអភិវឌ្ឍដោយចីរភាព ក្រោមលក្ខខណ្ឌនៃការប្រែប្រួលអាកាសធាតុ ។ ក្នុងក្របខ័ណ្ឌអន្តរជាតិ រាជរដ្ឋាភិបាលបានផ្តល់សច្ចាប័នដល់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ ហើយក៏បានចូលជាសមាជិកនៃពិធីសារក្យូតូ សំដៅរួមចំណែកដោះស្រាយបញ្ហាពិភពលោកដ៏ប្រឈមនេះ ។ នៅក្នុងឱកាសទិវាបរិស្ថាននេះ ក្រសួងបរិស្ថានបានអំពាវនាវដល់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ សូមចូលរួមទាំងអស់គ្នាក្នុងកិច្ចការពារបរិស្ថាន អភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប ស្របតាមកម្មវិធីបរិស្ថាននៃអង្គការសហប្រជាជាតិ ដើម្បីបុព្វហេតុបរិស្ថាននៃភពផែនដី សុខុមាលភាពសង្គម និងការអភិវឌ្ឍ ប្រកបដោយចីរភាព ។/

# លទ្ធផលនៃការប្រឡងមធ្យមសិក្សាទុតិយភូមិឆ្នាំនេះ បង្ហាញពីជំហានទៅមុខមួយដ៏សំខាន់ នៃកំណែទម្រង់វិស័យអប់រំ



*ឯកឧត្តម **ហង់ ជួនណារ៉ុន** ក្នុងឱកាសពិនិត្យដំណើរការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំនេះ*

រាជរដ្ឋាភិបាលកម្ពុជាដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ក្នុងនីតិកាលទី ៥ នេះ បាន និងកំពុងសកម្មអនុវត្តកម្មវិធីកំណែទម្រង់ស៊ីជម្រៅ ដើម្បីប្រែក្លាយប្រទេសកម្ពុជាពីប្រទេសដែលមានចំណូលទាបទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាបក្នុងរយៈពេលខ្លីខាងមុខ និងបន្តប្រែក្លាយទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ ២០៣០ ហើយបន្តប្រែក្លាយទៅជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ ២០៥០ ។

ដើម្បីសម្រេចបាននូវគោលដៅប្រកបដោយមហិច្ឆតានេះ គឺពឹងផ្អែកមួយផ្នែកធំទៅលើការលើកកម្ពស់សមត្ថភាពរបស់ប្រជាជនយើង តាមរយៈការអភិវឌ្ឍចំណេះដឹង និងជំនាញវិជ្ជាជីវៈ ប្រកបដោយគុណភាពខ្ពស់ និងរត់ឱ្យទាន់សភាពការណ៍វិវឌ្ឍន៍របស់ទីផ្សារ និងពិភពលោក ។ ជាក់ស្តែង ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំនេះ ជាឆ្នាំដំបូងនៃកំណែទម្រង់ក្នុងវិស័យអប់រំលើការប្រឡងនេះ ដោយមានការចូលរួមពីស្ថាប័នពាក់ព័ន្ធជាច្រើន រាប់ទាំងស្ថាប័នអង្គភាពប្រយុទ្ធប្រឆាំងអំពើពុករលួយផងដែរ ។ ក្រសួងអប់រំ យុវជន និងកីឡា វាយតម្លៃថា ដំណើរការទទួលបានលទ្ធផលជោគជ័យទាំងដំណើរការគ្រប់គ្រង និងរដ្ឋបាល រួមទាំងកាតព្វកិច្ចរបស់ភាគីពាក់ព័ន្ធទាំងអស់ដែល



*សកម្មភាពត្រួតពិនិត្យបេក្ខជនមុនពេលចូលប្រឡង*

បានប្រព្រឹត្តទៅតាមការគ្រោងទុក ។

ការប្រឡងនេះ មានរយៈពេលពីរថ្ងៃ គឺថ្ងៃទី ៤ និងទី ៥ ខែសីហា ឆ្នាំ ២០១៤ ។ នៅទូទាំងប្រទេសមានបេក្ខជនសរុបចំនួន ៩៣ ៤៥៦ នាក់ ចែកចេញជា ១៥៤ មណ្ឌល ក្នុងនោះថ្នាក់វិទ្យាសាស្ត្រ ១៤០ មណ្ឌល និងថ្នាក់វិទ្យាសាស្ត្រសង្គម ១៤ មណ្ឌល ស្មើនឹង ៣ ៧៧៩ បន្ទប់ ។ មុខវិជ្ជាចំនួន ៧ ចែកចេញជាថ្នាក់វិទ្យាសាស្ត្រ និងថ្នាក់វិទ្យាសាស្ត្រសង្គម ។ នៅថ្ងៃទីមួយមាន ៤ មុខវិជ្ជា គឺមីវិទ្យា ជីវវិទ្យា ប្រវត្តិវិទ្យា និងភាសាបរទេសសម្រាប់ថ្នាក់វិទ្យាសាស្ត្រ មុខវិជ្ជាភូមិវិទ្យា ប្រវត្តិវិទ្យា រូបវិទ្យា និងភាសាបរទេសសម្រាប់ថ្នាក់វិទ្យាសាស្ត្រសង្គម ។ នៅថ្ងៃទីពីរមាន ៣ មុខវិជ្ជា គឺអក្សរសាស្ត្រខ្មែរ រូបវិទ្យា និងគណិតវិទ្យា សម្រាប់ថ្នាក់វិទ្យាសាស្ត្រ មុខវិជ្ជាគណិតវិទ្យា សីលធម៌ ពលរដ្ឋវិជ្ជា និងអក្សរសាស្ត្រខ្មែរសម្រាប់ថ្នាក់វិទ្យាសាស្ត្រសង្គម ។

ជាលទ្ធផលនៃការប្រឡងដែលបានប្រកាសនៅថ្ងៃទី ២៩ និង ៣០ សីហា នៅតាមបណ្តារាជធានី-ខេត្ត គឺខេត្តស្វាយរៀង មានបេក្ខជនប្រឡងចំនួន ៣ ០៤៨ នាក់ ស្រី ១ ២០៥ នាក់ ជាប់ ៨០០ នាក់ ស្រី ៣៧២ នាក់ ភាគច្រើនជាប់និទ្ទេស E ។ ខេត្តព្រៃវែងមានបេក្ខជនប្រឡងចំនួន ៥ ៣២៨ នាក់ ស្រី ២ ៣១១ នាក់ ជាប់ ១ ១៥១ នាក់ ស្រី ៥៥៦ នាក់ ក្នុងនោះ ជាប់និទ្ទេស A ម្នាក់ និងនិទ្ទេស B មាន១១នាក់ ។ ខេត្តកំពង់ចាម មានបេក្ខជនប្រឡងចំនួន ៨ ៥០៧ នាក់ ស្រី ៤ ១៤១ នាក់ ជាប់ ២ ១១៤ នាក់ ស្រី ១ ១៥២ នាក់ ក្នុងនោះជាប់និទ្ទេស A ម្នាក់ និង និទ្ទេស B មាន ១២ នាក់ ។ ខេត្តកំពង់ធំ មានបេក្ខជនប្រឡងចំនួន ៣ ៨០៩ នាក់ ស្រី ១៧៤៧ នាក់ ជាប់ ៩១៦ នាក់ ស្រី ៥០៤ នាក់ ជាប់និទ្ទេស B ៩ នាក់ ។ ខេត្តតាកែវ មានបេក្ខជនប្រឡង ៨ ២៨១ នាក់ ស្រី ៣ ៩៣៥ ប្រឡងជាប់ ២ ១១៥ នាក់ ស្រី ១ ០២៧ ជាប់និទ្ទេស B ១៣ នាក់ ។ ខេត្តស្ទឹងត្រែង មានបេក្ខជនប្រឡងសរុប ចំនួន ៧១៣ នាក់ ស្រី ២៨៧ នាក់ ប្រឡងជាប់ ១៤៤ នាក់ ក្នុងនោះស្រី ៧០ នាក់ ។ ខេត្តកំពត មានបេក្ខជនប្រឡងសរុបចំនួន ៤ ៣១៧ នាក់ ស្រី ២ ០០៥ នាក់ ប្រឡងជាប់ ១ ០៩៨ នាក់ ស្រី ៥៥៤ នាក់ ជាប់និទ្ទេស B មាន ៦ នាក់ ។ ខេត្តកោះកុងមានបេក្ខជនប្រឡងសរុបចំនួន ៨១៩ នាក់ ស្រី ៣៧៤ នាក់ ប្រឡងជាប់ ១៨៣ នាក់ ក្នុងនោះ ស្រី ៩១ នាក់ ។ ខេត្តបន្ទាយមានជ័យ មានបេក្ខជនប្រឡងសរុបចំនួន ៣ ៣២៤ នាក់ ស្រី ១ ៥០១ នាក់ ប្រឡងជាប់ ៧២០ នាក់ ស្រី ៤០៨ នាក់ ជាប់និទ្ទេស ៣ ២ នាក់ ។ ខេត្តមណ្ឌលគិរី មានបេក្ខជនប្រឡងសរុបចំនួន ១៩១ នាក់ ស្រី ៧៧ នាក់ ប្រឡងជាប់ ៤៥ នាក់ ក្នុងនោះ ស្រី ២៧ នាក់ ។ ខេត្តព្រះវិហារ មានបេក្ខជនប្រឡងសរុបចំនួន ១ ១៦១ នាក់ ស្រី ៥៧០ នាក់ ប្រឡងជាប់ ៤៥៤ នាក់ ក្នុងនោះ ស្រី ២៤៧ នាក់ ។ ខេត្តកំពង់ស្ពឺ មានបេក្ខជនប្រឡងសរុបចំនួន ៣ ៤៨០ នាក់ ស្រី ១ ៥០៣ នាក់ ប្រឡងជាប់ ៥៨០ នាក់ ស្រី ២៩៤ នាក់ ជាប់ និទ្ទេស A ម្នាក់ និងនិទ្ទេស B មាន ៦ នាក់ ។ ខេត្តបាត់ដំបង មានបេក្ខជនប្រឡងសរុបចំនួន ៥ ៥៧៣ នាក់ ស្រី ២ ៧៩២ នាក់ ប្រឡងជាប់ ១ ០៩៧ នាក់ ស្រី ៥៨៩ នាក់ ជាប់និទ្ទេស B ១៦ នាក់ ។ ខេត្តព្រះសីហនុ មានបេក្ខជន ប្រឡងសរុបចំនួន ១ ៦៤៩ នាក់ ស្រី ៧៤០ នាក់ ប្រឡងជាប់



*គណៈមេប្រយោគនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ កាត់យកវិញ្ញាសារប្រឡងពីក្នុងសំបុត្រ*

៩១០ នាក់ ស្រី ១៦៨ នាក់ ជាប់និទ្ទេស B ២ នាក់។ ខេត្តរតនគិរី មានបេក្ខជនប្រឡងសរុបចំនួន ៦៣១ នាក់ ស្រី ២៤៦ នាក់ ប្រឡងជាប់ ១៥១ នាក់ ក្នុងនោះស្រី ៦៣ នាក់។ ខេត្តកែប មានបេក្ខជនប្រឡងសរុបចំនួន ២៨៨ នាក់ ស្រី ១៤៥ នាក់ ប្រឡងជាប់ ៦៨ នាក់ ស្រី ៤០ នាក់។ ខេត្តក្រចេះ មានបេក្ខជនប្រឡងសរុបចំនួន ១ ៥២៨ នាក់ ស្រី ៧៩៧ នាក់ ប្រឡងជាប់ ៤៧៧ នាក់ ស្រី ២៩៩ នាក់ ជាប់និទ្ទេស ព មាន ២ នាក់។ ខេត្តឧត្តរមានជ័យ មានបេក្ខជនប្រឡងសរុបចំនួន ៨៣៧ នាក់ ស្រី ៣៣៥ នាក់ ប្រឡងជាប់ ២៣៧ នាក់ ក្នុងនោះ ស្រី ៩១ នាក់។ ខេត្តសៀមរាប មានបេក្ខជនប្រឡងសរុបចំនួន ៥ ៥៦៤ នាក់ ស្រី ២ ៨១៦ នាក់ ប្រឡងជាប់ ១ ៥១៦ នាក់ ក្នុងនោះ ស្រី ៨៦៦ នាក់ ជាប់និទ្ទេស A ២ នាក់ និង និទ្ទេស B ២៤ នាក់។ ខេត្តពោធិ៍សាត់ មានបេក្ខជនប្រឡងសរុបចំនួន ២ ២៤៥ ស្រី ១ ០៤៨ នាក់ ប្រឡងជាប់ចំនួន ៥៥០ នាក់ ក្នុងនោះ ស្រី ៣០៤ នាក់ និទ្ទេស B ៣ នាក់។ ខេត្តកំពង់ឆ្នាំង មានបេក្ខជនប្រឡងសរុបចំនួន ៣ ០៨៧ ស្រី ១ ៥០៩ នាក់ ប្រឡងជាប់ ៨២៤ នាក់ ស្រី ៤៣៦ នាក់ ជាប់និទ្ទេស A ម្នាក់ និងនិទ្ទេស B ៦ នាក់។ ប៉ៃលិន មានបេក្ខជនប្រឡងសរុបចំនួន ២៣៧ នាក់ ស្រី ១០០ នាក់ ប្រឡងជាប់ ៨៦ នាក់ ក្នុងនោះ ស្រី ៤០ នាក់។ នៅរាជធានីភ្នំពេញ ក្នុងចំណោមបេក្ខជនប្រឡងជាប់នៅទូទាំប្រទេសចំនួន ២៣ ១២៦ នាក់ ប្រឡងជាប់ត្រូវជា ២៥,៧២% នៅមានបេក្ខជនប្រឡងជាប់ចំនួនជាង ៣៣% ស្មើនឹង ៥ ៩៧០ នាក់ ស្រី ២ ៩៥៣ នាក់ ក្នុងចំណោមបេក្ខជនប្រឡង ១៧ ០៥៦ នាក់។ ក្នុងនោះ មាននិទ្ទេស A ៣ នាក់ និងនិទ្ទេស B ៦៨ នាក់។ ដោយឡែកនៅមណ្ឌលប្រឡងខេត្តកណ្ដាល មានបេក្ខជនប្រឡងជាប់ចំនួន ១ ៨៤៨ នាក់ស្រី ៩៩៧ នាក់ ក្នុងចំណោម



*បេក្ខជនប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ កំពុងធ្វើវិញ្ញាសារប្រឡង*

បេក្ខជនចូលរួមប្រឡង ៩ ៩៣០ នាក់ ក្នុងនោះមាននិទ្ទេស A ចំនួន ២ នាក់ និងនិទ្ទេស B ចំនួន ២១ នាក់។

សរុបបេក្ខជនប្រឡងដែលមានចំនួន ៨៩ ៩៣៧ នាក់នៅទូទាំងប្រទេស ក្នុងនោះ បេក្ខជនប្រឡងជាប់មាន ២៣ ១២៦ នាក់ ត្រូវជា ២៥,៧២%។ ដោយឡែកសិស្សជាប់និទ្ទេស A ទូទាំងប្រទេសមានចំនួន ១១ នាក់ និទ្ទេស B មាន ២៨៩ នាក់ និទ្ទេស C មាន ៨០០ នាក់ និទ្ទេស D ១ ៨៣២ នាក់ និងនិទ្ទេស E មាន ២០ ០០០ នាក់។

ឯកឧត្តម **ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាបានឱ្យដឹងថា ឆ្នាំនេះជាវិញ្ញាសាសាកល្បងមួយសម្រាប់ក្រសួង គឺរៀបចំការប្រឡងឱ្យប្រព្រឹត្តទៅបានល្អ។ជាគោលដៅក្នុងការអប់រំគឺក្រសួងចង់ឱ្យសិស្សធ្វើម៉េចរៀនឱ្យបានច្រើន ចង់ឱ្យសិស្សចេះដឹងទូលំទូលាយអាចប្រើប្រាស់ចំណេះដឹង ដើម្បីទទួលបានជំនាញមួយពិតប្រាកដរកការងារធ្វើបានអាចប្រណាំងប្រជែងជាមួយយុវជន យុវនារីដទៃទៀតនៅក្នុងតំបន់ ក៏ដូចជានៅឆាកអន្តរជាតិ។ ដើម្បីឱ្យប្រទេសកម្ពុជាមានការអភិវឌ្ឍ ដើម្បីទាក់ទាញការវិនិយោគយើងត្រូវការមនុស្សមានជំនាញ បើយើងមិនមានពលករមានជំនាញទេ យើងមិនអាចអភិវឌ្ឍប្រទេសបានទេ យើងក៏មិនអាច ទាក់ទាញអ្នកវិនិយោគបានដែរ។

ទាំងអស់នេះគឺជាខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងការអនុវត្តគោលនយោបាយជាតិស្ដីពីការអភិវឌ្ឍយុវជនកម្ពុជា សំដៅអភិវឌ្ឍយុវជនទាំងខាងចំណេះដឹង ចំណេះធ្វើ សុខភាពកាយសម្បទានិងសីលធម៌ឱ្យក្លាយទៅជាមូលធនមនុស្សប្រកបដោយសក្ដានុពល និងធានាបាននូវការបង្កើតកាលានុវត្តភាព ការងារសម្រាប់យុវជន។ សាធារណមតិជាទូទៅសុទ្ធតែបានវាយតម្លៃខ្ពស់ចំពោះការកែទម្រង់របស់ក្រសួង អប់រំ ដែលនឹងធ្វើឱ្យការប្រឡងមធ្យមសិក្សាទុតិយភូមិឆ្នាំ ២០១៤ នេះ ពិតជាមានការពង្រឹងគុណភាពមួយដែលគួរឱ្យកត់សម្គាល់។ ការប្រាថ្នាចង់ឃើញការពង្រឹងគុណភាពប្រឡងមានភាពប្រសើរឡើងនោះ ឥឡូវបាន និងកំពុងក្លាយជាការពិតហើយ។ កំណែទម្រង់អប់រំថ្មីនេះមិនត្រឹមតែបានដោះស្រាយបញ្ហានូវដំណើរការពិតប្រាកដនៅក្នុងការប្រឡងមធ្យមសិក្សាទុតិយភូមិនោះទេ ប៉ុន្តែថែមជាសារវិព្វកដល់សិស្សានុសិស្សឆ្នាំក្រោយៗទៀត ព្រមទាំងមាតាបិតាថា ការស៊ីសំណូកនិងការបើកចម្លងក្នុងពេលប្រឡងគឺមិនមានទៀតឡើយ។ កំណែទម្រង់ក្នុងវិស័យអប់រំនេះគឺជាគំរូដ៏ល្អមួយក្នុងការធានាឱ្យបាន "យុវជនប្រាសចាកពីអំពើពុករលួយ" ដែលជាសារៈប្រយោជន៍សំខាន់បំផុតសម្រាប់អនាគតរបស់ពួកគេនិងរបស់ប្រទេសជាតិ។

នៅក្នុងឱកាសជួបសំណេះសំណាលជាមួយសិស្សឆ្នើមទាំង ១១ នាក់ ដែលបានប្រឡងជាប់និទ្ទេស A នៅវិមានសន្តិភាព កាលពីរសៀលថ្ងៃទី ៥ ខែកញ្ញា ឆ្នាំ ២០១៤ សម្ដេចតេជោ **ហ៊ុន សែន** បានហៅថានេះគឺជាលទ្ធផលដ៏ត្រចះត្រចង់ និងឧត្តមបំផុតបង្ហាញពីសមត្ថភាពពិតរបស់យុវសិស្សទាំង ១១ នាក់ ដែលបានផ្ដល់នូវកិត្តិយសដល់ខ្លួនឯងផ្ទាល់ ក្រុមគ្រួសារ និងសង្គមទាំងមូល និងជាពិសេសទៅទៀតគឺការចូលរួមចំណែកយ៉ាងសកម្មដល់ការអនុវត្តនូវកម្មវិធីកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលនីតិកាលទី ៥ នៃរដ្ឋសភា ដែលបាន និងកំពុងអនុវត្តនោះ។/

# ប្រាសាទគោកងារ នៅខេត្តបុរីរម្យ



*រូបភាព ១-២ : ប្រាសាទគោកងារ និងគោបុរៈខាងកើត ខេត្តបុរីរម្យ (ម.ត ១៩៨៣)*

ព្រះរាជាណាចក្រកម្ពុជាសព្វថ្ងៃ ក៏ដូចជានៅបណ្ដាខេត្តនានានៃប្រទេសថៃ ឡាវ និងវៀតណាមខាងត្បូង គឺមានសិល្បៈស្ថាបត្យកម្មខ្មែរជាច្រើន ដែលត្រូវបានស្ថាបនាឡើងគ្រប់សម័យកាលទាំងអស់ តាំងពីកកើតប្រទេសជាលើកដំបូងបង្អស់រហូតដល់បច្ចុប្បន្នភាព។ ក្នុងវិស័យស្ថាបត្យកម្មបុរាណមានប្រាង្គប្រាសាទ និងមូលនិធិសង្គមជាច្រើន តែនៅទីនេះយើងគ្រាន់តែសូមលើកប្រាសាទតែមួយមកអធិប្បាយនៅខេត្តបុរីរម្យ គឺប្រាសាទគោកងារប៉ុណ្ណោះ។

គោលបំណងសំខាន់របស់អត្ថបទនេះ គឺបង្ហាញនូវសារសំខាន់តែសំណង់ស្ថាបត្យកម្មនេះ ដែលស្ថិតនៅចម្ងាយមិនឆ្ងាយប៉ុន្មានពីស្រុកភូមិ ដែលយើងបានពិនិត្យសិក្សាស្រាវជ្រាវតាំងពី ឆ្នាំ ១៩៨៣ មកម្ល៉េះ។ តាមពិតទៅ ប្រាសាទនេះគេរកឃើញ និងអភិរក្សតាំងពីឆ្នាំ ១៩៣៤ មកម្ល៉េះ ក៏ប៉ុន្តែវត្តមានពុំត្រូវបានគេដឹងឮប៉ុន្មាននៅឡើយទេ។

សូមបញ្ជាក់ថា ប្រាសាទគោកងារ ឬប្រាសាទថ្ម ភូមិគោកប្រាសាទ មានទីតាំងស្ថិតក្នុងភូមិគោកងារ ឃុំផ្គាំ (ប្រោះគាំ) ស្រុកផ្គាំ ប្រមាណជា ៣ គីឡូម៉ែត្រ ពីទីរួមស្រុក។ គេបានរកឃើញនូវសិលាចារឹកនៅក្នុងបរិវេណនៃបុរាណស្ថាន ដែលបង្ហាញឱ្យដឹងថា សំណង់នេះគឺជាអរោគ្យសាលា (មន្ទីរពេទ្យ) មួយ សាងសង់ឡើងក្នុងរាជ្យរបស់ព្រះបាទជ័យវរ្ម័នទី ៧ យ៉ាងប្រាកដ។ ប្រភពសិលាចារឹកនៃប្រាសាទគោកងារបានបញ្ជាក់ឱ្យដឹងថា មានការថ្វាយអំណោយចំពោះអរោគ្យសាលានេះ ដោយមន្ត្រីជាន់ខ្ពស់ម្នាក់ មានគោរមងារ កម្រតែងអញ ស្រីជ័យវម្មទេវៈ នៅមហាសករាជ ១១១៥ ដែលត្រូវ និងឆ្នាំ ១១៩៣ នៃគ.ស.។

ដោយបែរមុខទៅរកទិសខាងកើត ហើយសាងសង់អំពីថ្មបាយក្រៀម ប្រាសាទគោកងារមានរាងជា ៤ ជ្រុង ទ្រវែង ហើយដូចសំណង់ដទៃៗឯទៀតក្នុងសម័យនោះ គេឃើញមានគោបុរៈ ឬទ្វារចូលពីរបាក់បែក រាងជាកាក់បាទមួយនៅខាងកើត និងមួយទៀតខាងលិច ដែលរលុះធ្វើអំពីថ្មបាយក្រៀម។ ប្រាសាទគោកងារ ហ៊ុមព័ទ្ធទៅដោយកំពែងពីរជាន់ កំពែងខាងក្នុងមានទំហំ ២៥ ម៉ែត្រ គុណ ២៥ ម៉ែត្រ រីឯកំពែងខាងក្រៅ ៤០ ម៉ែត្រ ព្រមទាំងស្រះមួយនៅពីមុខដែលមានទំហំ ១០០ ម៉ែត្រ គុណ ៥០ ម៉ែត្រ។ ស្រះនេះស្ថិតឆ្ងាយពីប្រាសាទប្រមាណ៥០ម៉ែត្រ ហើយមានទំហំប្រមាណ១០០ម៉ែត្រគុណ១៥០ម៉ែត្រ។

ថ្វីត្បិតតែស្ថិតឆ្ងាយពីទីរួមខេត្តបន្តិច បូជនីយដ្ឋាននេះនៅតែទទួលការរាប់អានពីសំណាក់អ្នកស្រុកភូមិជិតឆ្ងាយដែលតែងតែមកបន់ស្រន់មិនដាច់។ តែមុនឈានទៅកាន់តួប៉មកណ្ដាល គេត្រូវតែសំពះអ្នកតានៅមុខក្លោងទ្វារចូលជាមុនសិន ព្រោះអ្នកស្រុកខ្មែរបុរីរម្យជឿថា បុគ្គលណាដែលមិនថ្វាយបង្គំ ប្រតិបត្តិតាមទំនៀមទម្លាប់ប្រជាប្រិយទេ បុគ្គលនោះនឹងល្មើសច្បាប់យ៉ាងជាក់ច្បាស់ ហើយអាចនឹងទទួលនូវបាបកម្ម ទោះបីជាមកថ្វាយបង្គំព្រះពុទ្ធរូបនៅទីនោះក្ដី។ បើក្នុងពេលដែលគេមកថ្វាយបង្គំព្រះពុទ្ធបដិមាដែលស្ថិតក្នុងប្រាង្គទោលខាងលើបន្ទាប់ពីការសំពះអ្នកតារួចនោះ បុគ្គលនោះនឹងបានបុណ្យច្រើនមួយជាទ្វេរដង។

ដូចនេះ ទោះបីជាលទ្ធិព្រះពុទ្ធមហាយានត្រូវបានជំនួសដោយលទ្ធិហិនយានថេរវាទក្ដី ក៏យើងឃើញអ្នកស្រុកស្រែចម្ការរមែងតែមកសំពះព្រះពុទ្ធអង្គនិងអ្នកតាដែលតំណាងឱ្យដូនតាម្ចាស់ស្រុករក្សាប្រាសាទនៅទីនេះ។ ម្យ៉ាងវិញទៀត ទោះបីជាពួកគេជាពុទ្ធសាសនិកក៏ដោយ ក៏នៅតែគោរពបូជាអ្នកតាចាស់ស្រុកដែលបានក្លាយទៅជាឆ្នាំនៃកន្លែងពិសិដ្ឋខាងលើនេះដែរ។

ចំពោះយើងៗយល់ថា ជំនឿរបស់ប្រជានុរាស្ត្រនៅទីនេះ មានលក្ខណៈសំយោគយ៉ាងប្រាកដ។ យ៉ាងណាស័ក្តិសិទ្ធិគួរឱ្យគោរពសក្ការៈបូជាជាទីបំផុត។

(ម.ត្រាណេ)

# ក្រអៅឈូកជួយកម្ចាត់ជាតិពុល និងការឡើងកម្ដៅក្នុងខ្លួន



*ក្រអៅឈូក ឬមើម ឈូក មានអត្ថប្រយោជន៍ ជួយកម្ចាត់ជាតិពុល និងបញ្ឈប់មិនឱ្យខ្លួនប្រាណឡើងកម្ដៅ*

កង្វះខាតការយល់ដឹងពីគុណប្រយោជន៍នៃអាហារ ជាកត្តាសំខាន់នាំឱ្យប៉ះពាល់សុខភាព ហើយបន្លែ ផ្លែឈើមួយចំនួនដែលមានតម្លៃថ្លៃនោះ មិនមែនសុទ្ធតែមានប្រយោជន៍ដល់សុខ-ភាពទេ ប្រសិនបើអ្នកជ្រើសរើសបន្លែផ្លែឈើទាំងនោះយកទៅទទួលទានមិនបានត្រឹមត្រូវ ។

ក្រុមអ្នកស្រាវជ្រាវឱសថរុក្ខជាតិរបស់វៀតណាមបានឱ្យដឹងថា ក្រអៅឈូក ឬមើមឈូក មានអត្ថប្រយោជន៍ជួយកម្ចាត់ជាតិពុល ហើយបញ្ឈប់មិនឱ្យខ្លួនប្រាណឡើងកម្ដៅបានទៀតផង ។

ក្រុមអ្នកស្រាវជ្រាវឱសថរុក្ខជាតិបានអះអាងទៀតថា ក្រអៅឈូកក្នុងពេលខ្លះក៏អាចជួយសម្រួលដល់ការចរាចរទៅមករបស់ឈាមនៅក្នុងរាងកាយមនុស្សបានផងដែរ ។ លើសពីនេះទៀត ក្រអៅឈូក ឬមើមឈូក ក៏អាចជាថ្នាំប៉ូវកម្លាំងនិងលើកទឹកចិត្តផងដែរ ។សម្រាប់ការទទួលទានជាទូទៅ ក្រអៅឈូកត្រូវបានគេយកទៅស្លជាសម្លទឹក ឬជាសម្លគោក ។

ក្រៅពីអត្ថប្រយោជន៍ខាងលើ ក្រអៅ-ឈូក នៅផ្ដល់អត្ថប្រយោជន៍ផ្នែកសុខភាពជាច្រើនមុខទៀត ក្នុងនោះមានដូចជា :

-*បញ្ឈប់ការហូរឈាមច្រមុះ* : លាងវាឱ្យបានស្អាត បុករួចច្របាច់យកទឹកឱ្យបាន ២០០ ក្រាម ផឹកនៅពេលថ្ងៃ ។ វិធីម្យ៉ាងទៀតគឺអាចយកទឹកដែលកិនរួចបន្តក់លើច្រមុះដែលកំពុងហូរឈាម ។

-*ជួយឱ្យឃ្លានអាហារ* : យកក្រអៅឈូកស្រស់ចិតស្ដើងៗចំនួន ៥០ ក្រាម ហើយយកទៅបបរ និងរោយស្ករតិចៗពីលើ ។

-*ជួយសម្រួលដល់ដំណេកក្នុងពេលយប់* : អស់លោកអ្នកអាចយកក្រអៅឈូក ៥០០ ក្រាមលាយជាមួយផ្លែពុទ្រាក្រហម២០០ក្រាម ទៅធ្វើជាស៊ុបផ្អែមដោយចម្អិនជាមួយស្ករដុំឱ្យបានកន្លះម៉ោង ។ បន្ទាប់មកហុតស៊ុបនោះទាំងនៅក្ដៅឧណ្ហៗ នឹងជួយសម្រួលដល់ដំណេករបស់លោកអ្នក ។/

# ទុរេន Viagra ធម្មជាតិ





*ផ្លែទុរេននៅត្រូវបានប្រដូចនឹង Viagra ធម្មជាតិ ព្រមទាំងជួយព្យាបាលជំងឺខ្សោយផ្លូវភេទទាំងស្ត្រី និងបុរស*

ទុរេនពុំត្រឹមតែជាផ្លែឈើដ៏មានឱជារសឆ្ងាញ់ពិសាប៉ុណ្ណោះទេ ប៉ុន្តែផ្លែទុរេននៅត្រូវបានប្រដូចនឹង Viagra ធម្មជាតិ ជួយព្យាបាលជំងឺខ្សោយផ្លូវភេទទាំងស្ត្រី និងបុរសទៀតផង ។

ទុរេនផ្ទុកប្រូតេអ៊ីនច្រើន និងគ្មានកូឡេស្តេ-រ៉ូល ។ ក្រៅពីនេះវានៅមានអាណូអាស៊ីត វីតា-មីន C យ៉ាងច្រើន ។ វាជួយកែប្រែឱ្យប្រសើរឡើងនូវស្មារតី បន្ថយស្ត្រេសក្រោយធ្វើការងារតានតឹង ១ ថ្ងៃៗ ។ នៅប្រទេស ជប៉ុនគេច្រើនទទួលទានទុរេនមុនពេល "សិច" ព្រោះគេជឿថាវាមានសមាសធាតុមួយជំនួយអារម្មណ៍ "សិច" សម្រាប់ទាំង ២ ភេទ ហើយវាត្រូវបានប្រដូចទៅនឹង Viagra ធម្មជាតិ ។

ផ្លែទុរេនទោះបីមានក្លិនម្យ៉ាងធ្វើឱ្យពិបាកទ្រាំ តែជាប្រភេទផ្លែឈើសម្បូរជីវជាតិមានលទ្ធភាពប្រឆាំងភាពចំណាស់យ៉ាងល្អ រក្សាសម្ផស្សស្បែក និងបង្កើនការចងចាំ ។ ពិសេសវាមានប្រសិទ្ធភាពដ៏អស្ចារ្យក្នុងការព្យាបាលជំងឺខ្សោយផ្លូវភេទ ។

ទោះបីទុរេនល្អចំពោះសុខភាព តែយើងមិនត្រូវទទួលទានច្រើនពេកក្នុងពេលតែមួយទេ ។

-ពេលទទួលទានទុរេន គប្បីចាប់អារម្មណ៍លើប្រការមួយចំនួនគឺ :

-មិនត្រូវផឹកស្រា ឬស្រាបៀរក្រោយពេលទទួលទានទុរេន ព្រោះវាអាចបណ្ដាលឱ្យបាត់បង់ជីវិត ។

-អ្នកមានជំងឺទឹកនោមផ្អែម លើសឈាមកំពុងកើតជំងឺរលាក ឆ្លងមេរោគ កើតមុន ស្ត្រីមានគភ៌នោះ មិនគួរទទួលទានទេ ។

-មិនត្រូវទទួលទានទុរេនដំណាលគ្នាជាមួយកាហ្វេព្រោះនឹងធ្វើឱ្យការរំលាយអាហារមិនប្រក្រតីដូចជាទល់ ខ្យល់ ចង់ក្អួត អស់កម្លាំងពិបាកទ្រាំ ។/



# ឃុំបន្ទាយឆ្មារ : ទឹកដីចាស់ ផ្លាស់មុខមាត់ថ្មី





*លោក វ៉ែន សំអួន ( ពាក់អាវ ស ) ក្នុងពេលពិនិត្យប្រាសាទបន្ទាយឆ្មារ*

ជាឃុំមួយក្នុងចំណោមឃុំទាំង ៦ របស់ស្រុកថ្មពួក ដែលស្ថិតនៅចុងខាងជើងបំផុតរបស់ខេត្តបន្ទាយមានជ័យ ក្នុងចម្ងាយ ៥៦ គីឡូម៉ែត្រ ពីទីរួមខេត្តនោះ ឃុំនេះមានផ្ទៃដីធំជាងគេបើធៀបនឹងឃុំដទៃនៃស្រុក។ ឃុំមានភូមិសាស្ត្រជាប់ព្រំដែន កម្ពុជា-ថៃ ដែលខ័ណ្ឌដោយជួរភ្នំដងរែកនៅប៉ែកខាងលិចនិងជាប់ព្រំប្រទល់ខេត្តឧត្តរមានជ័យ នៅប៉ែកខាងជើង និងខាងកើត។ ខាងត្បូងជាប់ព្រំប្រទល់នឹងឃុំថ្មពួក។

បន្ទាយឆ្មារជាឃុំមានប្រវត្តិទឹកដីចាស់ និងរុងរឿងតាំងពីសម័យអង្គរ ក្នុងនោះ មានប្រាសាទទូលប្រាសាទ និងបេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្របុរាណយ៉ាងច្រើនដែលបន្សល់ទុកដោយបុព្វបុរសខ្មែរ។

## មនុស្ស និងភូមិសាស្ត្រ

ឃុំបន្ទាយឆ្មារមាន ១៦ ភូមិ ក្នុងនោះ គឺភូមិគោកសំរោងកើត គោកសំរោងលិច ក្បាលទន្សោង បន្ទាយឆ្មារជើង បន្ទាយឆ្មារលិច បន្ទាយឆ្មារត្បូង ក្បាលក្របី ត្រពាំងធ្លក ធ្លក ថ្មដែកកេះ ស្រះជ្រៃ ព្រៃសង្ហារ ប្រាសាទត្បែង ដងរែក ថ្មរមៀលកើត និងថ្មរមៀលលិច។ ឃុំមានផ្ទៃដី ៣៦ ៤៦១ ហ.ត ក្នុងនោះផ្ទៃដីដំណាំស្រូវវស្សា ១០ ១០០ ហ.ត ផ្ទៃដីស្រូវប្រាំង ១០០ ហ.ត ផ្ទៃដីដំណាំដំឡូងមី ២៤ ០០០ ហ.ត ផ្ទៃដីដំណាំឈើហូបផ្លែ ៥០ ហ.ត និង ផ្ទៃដីដំណាំរួមផ្សំ ៤០ ហ.ត។ ផ្ទៃដីព្រៃតំបន់ការពារទេសភាពបន្ទាយឆ្មារនៅសល់មានព្រៃសហគមន៍ការពារត្រពាំងធ្លកចំនួន ២៨០ ហ.ត និងព្រៃសហគមន៍ការពារដងរែក ២០០ ហ.ត ។

បច្ចុប្បន្នមានពលរដ្ឋ ៤ ៥៨១ គ្រួសារ ស្មើនឹងមនុស្សរាយចំនួន ១៧ ៦១៧ នាក់ ក្នុងនោះ ស្រីចំនួន ៨ ៤១៩ នាក់ ( អាយុ ១៨ ឆ្នាំឡើង ចំនួន ១១.៥៥៤ នាក់ ស្រីចំនួន ៥ ៧៣៤ នាក់) ។ មានផ្ទះចំនួន ៣ ៨៤៣ ខ្នង។

ឃុំស្ថិតនៅជាប់ផ្លូវជាតិលេខ ៥៦A ប្រវែង ១២ គីឡូម៉ែត្រ និងនៅជាប់ផ្លូវជាតិ ៥៦B ប្រវែង ១៤ គីឡូម៉ែត្រ។ ឃុំមានប្រាសាទបុរាណដែលធំ និងល្បីឈ្មោះ មានប្រាសាទបន្ទាយឆ្មារ ជាប្រាសាទដែលត្រូវបានគេយករូបចម្លាក់អវតាលោកិស្វរៈព្រហស្ត ៣២ នៅជញ្ជាំងខាងលិចបាស្រោទធ្វើជានិមិត្តរូបរបស់ខេត្ត និងប្រាសាទមេបុណ្យ។ ក្រៅពីនោះ នៅមានប្រា-



*វិទ្យាល័យបន្ទាយឆ្មារ ក្នុងឃុំបន្ទាយឆ្មារ*



*មណ្ឌលសុខភាពបន្ទាយឆ្មារ ក្នុងឃុំបន្ទាយឆ្មារ*



*លំនៅដ្ឋានរបស់ប្រជាជនឃុំបន្ទាយឆ្មារនាពេលបច្ចុប្បន្ន*



*លោក វ៉ែន សំអូន និងប្រជាជនមូលដ្ឋានកំពុងលើកទំនប់ការពាទឹកជំនន់*

សាទរណបជាច្រើនទៀត ដូចជា ប្រាសាទតាព្រហ្ម ប្រាសាទតាប្លឹង ប្រាសាទសំណាង តាសុខ ប្រាសាទចិញ្ចឹមត្រី ប្រាសាទយាយគុំ ប្រាសាទតាណែម និងមានទួលប្រាសាទបុរាណ ផ្លូវ ប្រព័ន្ធធារាសាស្ត្រ (អាងទឹកបុរាណមាន : កសិណប្រាសាទបន្ទាយឆ្មារ កសិណប្រាសាទមេបុណ្យ អាងភ្លោះ អាងទំនប់លាវ អាងក្បាលទង្សេង អាងក្បាលក្របី អាងជើងក្រួស អាងព្រហ្មមុខបួន អាងអម្ពិលបិទទឹក)។ ក្រៅពីនេះមានទីទួលកប់សពបុព្វបុរស ទីទួលបុរាណដែលជាមជ្ឈមណ្ឌលវប្បធម៌ប្រវត្តិសាស្ត្រសង្គម និងប្រពៃណីជាច្រើនទៀតផងដែរ។

## កែប្រែមុខមាត់ឆ្លើយតបនឹងសំណូមពរពលរដ្ឋ

លោក *វ៉ែន សំអូន* ប្រធានគណៈកម្មាធិការគណបក្សប្រជាជនកម្ពុជាឃុំ និងជាមេឃុំបន្ទាយឆ្មារបានប្រាប់ទស្សនាវដ្ដីប្រជាជនដោយរំឭកអំពីអ្វីដែលកើតឡើងពីអតីតកាល និងអ្វីដែលមានកើតឡើងបន្ទាប់ពីការចាប់ផ្ដើមនៃរាជរដ្ឋាភិបាលនីតិកាលទី ១ ក្រោយការបោះឆ្នោតឆ្នាំ ១៩៩៣ រហូតមកដល់ពេលនេះ។ អ្វីដែលលោកមេឃុំពន្លេចប្រាប់យើងគឺរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះនូវជីវភាពរបស់ប្រជាជនឃុំបន្ទាយឆ្មារមានការប្រែប្រួលយ៉ាងខ្លាំង។ លោកបានបញ្ជាក់ថា គិតត្រឹមដើមខែកញ្ញាឆ្នាំនេះ ក្នុងឃុំមានយានយន្ត និងរោងម៉ាស៊ីនជាច្រើន ដូចជា ឡានធំ ១៣២ គ្រឿង ឡានតូច ៣១ គ្រឿង ត្រាក់ទ័រ ៣៤ គ្រឿង គោយន្ត ១ ៥២៥ គ្រឿង ម៉ាស៊ីនបូតស្រូវ ៣៨ គ្រឿង ម៉ាស៊ីនកិនស្រូវធុនតូច ២២ គ្រឿង ម៉ូតូ ១ ៥៤៤ គ្រឿង។

លោកមេឃុំបញ្ជាក់ថា មុខរបរសំខាន់របស់ប្រជាជននៅឃុំនេះគឺការធ្វើកសិកម្ម និងការធ្វើអាជីវកម្មផ្សេងៗ។ ដោយសារភូមិសាស្ត្រនៃឃុំជាប់នឹងព្រំដែនផងបានធ្វើឱ្យរបរកសិកម្មរបស់ប្រជាជននៅទីនោះទទួលបាននូវចំណូលខ្ពស់គួរសម។ លោកបន្តថា ចំនួនគ្រឿងយន្តកសិកម្មខាងលើ គឺបានបង្ហាញច្បាស់អំពីលទ្ធភាព និងការវិវឌ្ឍនូវជីវភាពគ្រួសាររបស់ពួកគេ។

លោកនិយាយដោយមោទនភាពថា ប្រជាជនឃុំនេះ ៨៥% ប្រកបរបរកសិកម្ម ក្នុងនោះស្ទើរគ្រប់គ្រួសារ យ៉ាងហោចណាស់មានគោយន្តមួយគ្រឿង ម៉ូតូមួយគ្រឿង។ ក្រៅពីដំណាំស្រូវពលរដ្ឋដាំដំឡូងមីដែលធ្វើឱ្យជីវភាពពួកគេធូរធារ។

លោក *វ៉ែន សំអូន* បន្តដោយសំឡេងទៅរកផែនទីឃុំថា ដោយមានអំណោយផលពីប្រវត្តិទឹកដីកេរដំណែលដូនតាដ៏ចំណាស់ពីលក្ខណៈភូមិសាស្ត្រ ប្រភេទស្ថានភាពដី និងជាពិសេសពីការដឹកនាំរបស់រាជរដ្ឋាភិបាល អាជ្ញាធរ និងជំនាញពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់នោះ ឃុំបន្ទាយឆ្មារត្រូវបានស្ដារ និងអភិវឌ្ឍឡើងវិញលើគ្រប់វិស័យ។ ឃុំទទួលបានសមិទ្ធផលជាច្រើនបុន្មានឆ្នាំចុងក្រោយពីប្រមុខគណបក្សប្រជាជនកម្ពុជា មន្ត្រីក្រុមការងារគណបក្សប្រជាជនកម្ពុជា រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា ដូចជា វិទ្យាល័យមួយកន្លែង អនុវិទ្យាល័យ មួយកន្លែង សាលាបឋមសិក្សា និងសាលាមត្តេយ្យ ១៨ កន្លែង។ មណ្ឌលសុខភាពមួយកន្លែង ប៉ុស្តិ៍សុខភាពមួយកន្លែង និងត្រៀមកសាងមណ្ឌលសុខភាពមួយកន្លែងទៀត។

លោកបានរំឭកថា អគារសិក្សាទាំងនោះកសាងឡើងក្រោមជំនួយរបស់អង្គការដៃគូអភិវឌ្ឍន៍ជាជំនួយបរទេស កសាងដោយថវិការដ្ឋ សប្បុរជន និងក្នុងនោះមានអគារសិក្សា ៣ ខ្នង ជាអំណោយរបស់សម្ដេចតេជោ **ហ៊ុន សែន** និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត និង ២ ខ្នង ទៀតជាអំណោយរបស់ឯកឧត្ដមឧបនាយករដ្ឋមន្ត្រី **កែ គឹមយ៉ាន**។ មានស្រះទឹកមួយកន្លែងនៅភូមិប្រាសាទត្បែងជាអំណោយសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន**។ មានប្រឡាយទឹកដែលទើបស្ដារឡើងវិញដោយក្រសួងធនធានទឹក ២ ខ្សែ ប្រវែង ៣៨០០ ម៉ែត្រ ប្រឡាយទឹក មូលនិធិឃុំ ប្រវែង ៥ ៥៨៧ ម៉ែត្រ សំណង់ស្នាក់ទឹក ៣ កន្លែង ក្រោមគម្រោងកាត់បន្ថយភាពក្រីក្រតំបន់បឹងទន្លេសាប។ មានផ្លូវលំក្រាលក្រួសទើបស្ថាបនា ៦ខ្សែ ប្រវែង៣ ៣៨៨ ម៉ែត្រ (បន្ថែមលើផ្លូវលំមានស្រាប់រាប់សិបខ្សែនៅក្នុងឃុំ)។

លោកបន្តថាឃុំមានផ្លូវជាតិលេខ៥៦A និង ៥៦B ឆ្លងកាត់ចំពាក់កណ្ដាលឃុំនេះ ដែលកំពុងស្ថាបនា ក្រោមគម្រោងធនាគារអភិវឌ្ឍន៍អាស៊ី(ADB) ប្រើមូលនិធិធនាគារអភិវឌ្ឍន៍កូរ៉េ។ សមិទ្ធផលហេដ្ឋារចនាសម្ព័ន្ធក្នុងឃុំ ក្រៅពីជាអំណោយរបស់ថ្នាក់ដឹកនាំគណបក្សប្រជាជន មន្ត្រីក្រុមការងារ សប្បុរសជន នៅក្នុងឃុំក៏បានទទួលជំនួយពីអង្គការដៃគូអភិវឌ្ឍន៍ជាច្រើនដូចជា ECOSORN,OKENDEN, RACHA, HIFFER, VSG, WFP, EDM, 3MEKONG, KBA WORLD VISION, HALO TRUST, WHF ។ល។



*ការដ្ឋានស្ថាបនាផ្លូវជាតិលេខ ៥៦ ឆ្លងកាត់ឃុំបន្ទាយឆ្មារ*

ក្នុងឃុំក៏មានរមណីយដ្ឋានទេសចរណ៍វប្បធម៌ និងធម្មជាតិ មានសហគមន៍ទេសចរណ៍ និងផ្ទះស្នាក់។

### ធ្វើត្រូវ អ្នកគាំទ្រកើន សំណូមពរក៏កើន

លោកមេឃុំបាននិយាយបន្ថែមថា សមិទ្ធផលទាំងអស់បានជួយឱ្យពលរដ្ឋក្នុងឃុំមានជីវភាពប្រសើរឡើងៗ និងញ៉ាំងឱ្យឃុំនេះប្រែប្រួលមុខមាត់ថ្មី។ ពលរដ្ឋកាន់តែមានជំនឿ និងគាំទ្រគណបក្សប្រជាជនកម្ពុជា។ ប្រជាជនជឿជាក់ព្រោះបានឃើញច្បាស់ថាមានការជួយស្តារ និងអភិវឌ្ឍឃុំនេះយ៉ាងពិតប្រាកដ ថ្វីត្បិតតែមានដៃគូអភិវឌ្ឍន៍ជាច្រើនដែរក៏ដោយ តែជំនួយពីរាជរដ្ឋាភិបាល និងគណបក្សប្រជាជន គឺជាស្នូលនៃការអភិវឌ្ឍយ៉ាងពិតប្រាកដ។

សូមបញ្ជាក់ថា ឃុំបន្ទាយឆ្មារក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់តាំងពីឆ្នាំ ២០០២ មក គណបក្សប្រជាជនកម្ពុជាបាននាំមុខរហូត។ការបោះឆ្នោតឃុំឆ្នាំ២០១២អាសនៈគណបក្សកើនចំនួនមួយ គឺ គណបក្សប្រជាជនកម្ពុជាចំនួន៦អាសនៈ គណបក្សសង្គ្រោះជាតិ ៤ និងគណបក្សហ៊្វុនស៊ិនប៉ិច ១។

លោកមេឃុំនិយាយទៀតថា ពលរដ្ឋក្នុងមូលដ្ឋានបានជឿជាក់ និងគាំទ្រខ្លាំងចំពោះរាជរដ្ឋាភិបាល និងគណបក្សប្រជាជនកម្ពុជាគឺ ដោយសារការស្តារ និងអភិវឌ្ឍចំបំណងរបស់ពួកគេ ដូចជា ស្រះទឹក ផ្លូវ ទំនប់ ប្រឡាយ សាលារៀន ជាពិសេសគឺ ពលរដ្ឋបានទទួលសិទ្ធិស្របច្បាប់ លើដីធ្លីធ្លាប់ប្រើប្រាស់ និងកាន់កាប់ពុំទាន់មានការអនុញ្ញាតតាមរយៈការអនុវត្តបទបញ្ជាលេខ០១បប លើគោលនយោបាយចាស់សកម្មភាពថ្មីក្នុងវិស័យដីធ្លី ។ នោះគឺក្រុមការងារបច្ចេកទេសសុរិយោដី និងយុវជនស្ម័គ្រចិត្តសម្តេចតេជោវាស់វែងដី និងចេញប័ណ្ណកម្មសិទ្ធិដីធ្លី ៩ ៤៤៥ ក្បាលដី ស្មើដីទំហំជាង ២ ម៉ឺនហ.ត ក្នុងនោះពលរដ្ឋមានភ័ព្វវាសនាបានទទួលប័ណ្ណកម្មសិទ្ធិលើកដំបូងផ្ទាល់ពីដៃសម្តេចតេជោនាយករដ្ឋមន្ត្រី កាលពីថ្ងៃទី ៧ វិច្ឆិកា ២០០៧។ មន្ត្រីគ្រប់ជាន់ថ្នាក់បានធ្វើអំពើល្អ ជួយដោះស្រាយបញ្ហាជូនពលរដ្ឋ ដោយបានឆ្លើយតបរាល់សំណូមពរព្រមទាំងអនុវត្តបានល្អនូវគោលនយោបាយភូមិឃុំមានសុវត្ថិភាព។

លោកមេឃុំបានរំឭកថា ទោះបីយើងដោះស្រាយសំណូមពរប្រជាជនបានច្រើនក៏ដោយ តែដោយការវិវឌ្ឍមានឥតឈប់ ដូចនេះសំណូមពររបស់ប្រជាជនក្នុងការរស់នៅក៏កាន់តែច្រើនថែមទៀត។លោកបញ្ជាក់ថា ចំពោះទិសដៅបន្ត និងជាសំណូមពររបស់ពលរដ្ឋ គឺចង់បានប័ណ្ណកម្មសិទ្ធិដីធ្លីដែលនៅសេសសល់។ ប្រជាជនសុំឱ្យបន្តជួយស្ថាបនាលូ ផ្លូវ និងប្រព័ន្ធធារាសាស្ត្រ។ ប្រជាជនចង់បានផ្លូវកៅស៊ូ និងបេតុង ជំនួសផ្លូវដីដែលសំខាន់ៗមួយចំនួន។ ចង់បានការអភិរក្ស និងអភិវឌ្ឍវិញប្រាសាទ។ ចង់បានភ្លើងអគ្គិសនី និងទឹកស្អាតប្រើប្រាស់។ ប្រជាជនចង់បានរកការងារធ្វើ និងរកទីផ្សារដំណាំស្រូវ ដំឡូងមី ឱ្យបានសមស្រប។



*ប្រជាជនឃុំបន្ទាយឆ្មារ ចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ*

អ្នកស្រី *សាយ ឡៅ* នៅភូមិបន្ទាយឆ្មារលិច និយាយថា ជីវភាពពលរដ្ឋ ២ ឆ្នាំចុងក្រោយនេះបានប្រែប្រួលធូរធារកាន់តែខ្លាំង។ ប៉ុន្តែដោយសារចំនួនសមាជិកកើនពលរដ្ឋមួយចំនួននៅតែខ្វះខាតដីធ្លីបង្កបង្កើនផលខ្លះនៅតែធ្វើចំណាកស្រុកទៅរកការងារធ្វើនៅក្រៅប្រទេស។

ឯយុវជន *ថៃ សុផុង* នៅភូមិបន្ទាយឆ្មារជើង និយាយថាខ្លួននិងប្រជាជនក្នុងឃុំពេញចិត្តគាំទ្រនូវកម្មវិធីនយោបាយ គោលនយោបាយ និងការដឹកនាំរបស់រាជរដ្ឋាភិបាល និងគណបក្សប្រជាជនកម្ពុជា ដោយសារភាពត្រឹមត្រូវ ជាក់ស្តែង និងឆ្លើយតបបានសំណូមពរ ហើយទាន់ពេលវេលា។ យុវជនបន្តថា ខ្លួនបានមើលឃើញពីសមិទ្ធផលអភិវឌ្ឍន៍ សន្តិសុខ សុវត្ថិភាពក្នុងប្រទេស និងក្នុងមូលដ្ឋានរបស់ខ្លួន។ ហេតុនេះខ្លួនបានពន្យល់ប្រាប់ដល់អ្នកភូមិ ពិសេសយុវជនដទៃទៀត ឱ្យស្រឡាញ់ និងជឿជាក់លើគណបក្សប្រជាជនកម្ពុជា ក្រោមការដឹកនាំរបស់សម្តេចទាំងបី និងរាជរដ្ឋាភិបាលដឹកនាំដោយសម្តេចតេជោ **ហ៊ុន សែន** ក៏ដូចជាមន្ត្រីគ្រប់ជាន់ថ្នាក់។

យើងបានចាកចេញពីឃុំបន្ទាយឆ្មារ ខណៈមានភ្លៀងធ្លាក់មួយមេយ៉ាងធំ។ ដីស្អិតប្រកបដោយជីវជាតិ និងដំណាំកសិកម្មពណ៌ខៀវស្រងាត់ប្របសងខាងផ្លូវ បានរំលេចនូវរូបរាងនៃឃុំជាប់ព្រំដែនមួយនេះឱ្យកាន់តែស្រស់បំព្រងឡើង។ យើងក៏បាននឹកឃើញដល់ពាក្យពេចន៍ជាច្រើនរបស់អ្នកភូមិក្នុងពេលសន្ទនាជាមួយយើងថា ប្រសិនបើទីនេះមានផ្លូវកាន់តែល្អ តម្លៃកសិផលកាន់តែសមស្របមិនធំណុះលើឈ្មួញខ្លាំងពេក ហើយរមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រនានាត្រូវបានកែលម្អដើម្បីទាក់ទាញបាននូវទេសចរណ៍អន្តរជាតិ និងជាតិ ដែលជាប្រភពចំណូលថ្មីនោះ ជីវភាពអ្នកឃុំបន្ទាយឆ្មារ និងឃុំជនបទជាប់ព្រំដែនមួយនេះនឹងកាន់តែរីកចម្រើនថែមទៀតជាក់ជាពុំខាន។/




(បទពាក្យ៧)

- ថ្ងៃល្អបរិសុទ្ធរលត់ទៅ សល់នៅតែម្លប់ក្រអូបសាយ
សុរិយាទន់ទាបបង្អប់កាយ នាជើងមេឃនាយឆ្ងាយផុតដី ។
- មើលមេឃហ្វូងកុករំសាយជួរ វិលពីបឹងបួររកចំណី
សាសងសាកសួរគ្នាសល់អ្វី ផ្ញើឱ្យកូនឆីបានឆ្អែតផង ។
- ពួកចាបចេចចាចហាហៅគ្នា កុំរង់រេរាសោះសៅហ្មង
ឆាប់ចូលសំបុកសុខកន្លង សម្បុកដូងចងសំយាបផ្ទះ ។
- សត្វរកស៊ីថ្ងៃទីជិតឆ្ងាយ ជម្ពះអន្តរាយព្រោះក្រពះ
មេឃអន់ពន្លឺថ្ងៃចាំងជះ ខំស្រូតរូតរះរកទ្រទ្រង់ ។
- ព្រលប់យប់យន់គ្មានទិនករ សត្វរាត្រីចរទាំងតូចធំ
ចេញចាកសម្បុកកុកសម្ងំ ស្វះស្វែងខិតខំទម្លាប់វា ។
- អំពិលអំពែកតូចទាបពិត អួតអាងមានឫទ្ធិមហិមា
ថាខ្លួនភ្លឺចាំងជាងចន្ទ្រា ហិចហើររេរាឫកសម្បើម ។
- ហ្វូងមេអំបៅស្រស់បវរ ប្រាណចម្រុះពណ៌ដ៏ល្អឆើម
ឃើញដង្កូវវារខ្ចើមរអើម ភ្លេចកំណើតដើមដង្កូវដែរ ។
- តួកមៀមញ៉ោកញ៉ាកខ្លែងស្រាកស្រែក សូរដូចដួងបែកភ្នែកលៀនតែ
ទីទុយភ្នែកធំសម្លក់ត្មែរ ទន្ទ្រាំភ្លឺស្រែស៊ីក្ដាមខ្យង ។
- ឯប្រចៀវជ្រើងប្រឹងរំពៃ រកផ្លែឈើព្រៃតតរំលង
ដេកដាក់ក្បាលចុះជើងទាំងសង ប្រតោងត្រកងនោមស្រោចមុខ ។
- អាសូរសត្វស្វាប្រាជ្ញាឆ្លាត ព្យាយាមសង្វាតសាងសម្បុក
លុះមានភ្លៀងមកឡើងសំកុក ពីលើសម្បុកមុខម្លហ្មង ។
- កូនពៅសំណព្វឱបជាប់ពោះ កូនបងសោតនោះនៅលើខ្នង
ឃ្លានឆីផ្លែឈើព្រៃកន្លង បានកូនលើខ្នងបេះបញ្ចុក ។
- ញាតិអើយកុំឡើយសើចសត្វស្វា រស់ក្នុងលោកាប្រាថ្នាសុខ
សាងល្អសុចរិតឥតរិតក្ដ ចិត្តឥតស្មាញស្មុគយ៉ុកបាបកម្ម ។/

*ដោយ : នឹម ណាំ*




## សំណូមពរ

លោកទន្តពេទ្យវិសាល និយាយប្រាប់នាយសុច ដែលចូលទៅព្យាបាលធ្មេញនៅគ្លីនិករបស់ខ្លួន :

- ខ្ញុំមានសំណូមពរមួយសូមប្អូនជួយខ្ញុំផង ។ សំណូមពររបស់ខ្ញុំគឺសុំឱ្យប្អូនស្រែកអូយ!អូយ! ឱ្យខ្លាំងៗ ។

- ម៉េចខ្ញុំចាំបាច់ស្រែកអីចឹងបើអត់មានឈឺបន្តិចផង?

-ជិតដល់ម៉ោងទូរទស្សន៍ផ្សាយកម្មវិធីប្រកួតបាល់ទាត់ពិភព-លោកហើយតែមនុស្សនៅរង់ចាំខាងក្រៅជិតដប់នាក់ទៀតឯណោះ ។ ខ្ញុំ ចង់ឱ្យអ្នកទាំងនោះត្រឡប់ទៅផ្ទះវិញនឹងអាលខ្ញុំបើកទូរទស្សន៍មើលបាល់ទាត់ ។ សុំជួយខ្ញុំម្ដងទៅស្រែកអូយ ! អូយ ! ឱ្យខ្លាំងៗទៅ ខ្ញុំមិនយកថ្លៃឈ្នួលពីប្អូនទេ ។

## ផ្លាស់ប្ដូរ

ថ្ងៃមួយ នាយច្រែង បាននាំប្រពន្ធចូលអាហារដ្ឋាន ។ ពេលកម្មង់មុខម្ហូបរួច នាងច្រែត និយាយថា :

- បងឯងឥឡូវផ្លាស់ប្ដូរច្រើនណាស់ អ្វីៗសុទ្ធតែផ្ទុយពីមុន ។

- អ្វីស បងប្លែកយ៉ាងម៉េចខ្លះ?

-ចាះ កាលពីបងនៅកំលោះឱ្យតែនារីរត់តុហុចតារាងមុខម្ហូបឱ្យជ្រើសរើស គឺបងតែងតែសំឡឹងមើលមុខនាងសិន ទើបមើលតារាងមុខម្ហូបជាក្រោយ ។ ប៉ុន្តែឥឡូវនេះ បងមើលតារាងមុខម្ហូបសិន ទើបមើលមុខនាងជាក្រោយ ។

- ម៉េចអូនច្រែត ចាំច្បាស់ម្ល៉េះ ?

- ចាះ មិនចាំច្បាស់ម៉េចកើត បើឯងនិងខ្ញុំ កាលទាក់ទងគ្នាដំបូងមុនក្លាយជាប្ដីប្រពន្ធ ក៏ដោយសារបងមើលមុខខ្ញុំទាល់តែភ្លឹក ពេលខ្ញុំកាន់តារាងមុខម្ហូបហុចដូចឱ្យជ្រើសរើសមុខម្ហូបហ្នឹងឯង ។ បងនឹកឡើងវិញមើល ពេលនោះបងបានញញឹមញញែមនិយាយជាមួយខ្ញុំយ៉ាងម៉េចខ្លះ ។

## មហិច្ឆតា

ពេលរសៀលថ្ងៃមួយ តាសារាត់ អួតប្រាប់ចៅៗប្អូនប្រាំនាក់ដែលអង្គុយក្បែរ :

-ចៅៗដឹងទេកាលពីតានៅជាយុវវ័យតាមានមហិច្ឆតាចង់ផ្លាស់ប្ដូរពិភពលោកនេះទាំងមូលណ៎ា ។

- បាទ បាទ ចុះឥឡូវនេះលោកតា ?

- អ្ហេស ឥឡូវ គ្រាន់តែប្ដូរខោមួយក៏មិនចង់បានផង ។/

បោះពុម្ពដោយ រោងពុម្ព អរិយធម៌ ផ្ទះលេខ ៩២, ផ្លូវលេខ ៥៩៤, សង្កាត់បឹងកក់ II ខណ្ឌទួលគោក-ភ្នំពេញ
H/P : 012 935 822 / Tel : 023 885 188 / Fax : 023 885 189 E-mail : ariyathoar@yahoo.com / ariyathoar@online.com.kh

# អ្នកឧបត្ថម្ភ ទស្សនាវដ្តី ប្រជាជន លេខ ១៦០

| | | | | | |
|---|---|---|---|---|---|
| ១- | ឯ.ឧ | កែ | គឹមយ៉ាន | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ប្រធានក្រុមការងារចុះខេត្តបន្ទាយមានជ័យ | ១០០ ដុល្លារ |
| ២- | ឯ.ឧ | មិន | ឃិន | ប្រធានគណៈកម្មាធិការគណបក្សក្រសួងធម្មការ និងសាសនា និងលោកជំទាវ **ខួន ឆួន** | ១០០ ដុល្លារ |
| ៣- | ឯ.ឧ | ត្រាំ | អ៊ីវតឹក | ប្រធានគណៈកម្មាធិការគណបក្សក្រសួងសាធារណការ និងដឹកជញ្ជូន | ១០០ ដុល្លារ |
| ៤- | ឯ.ឧ | ថោង | ខុន | ប្រធានគណៈកម្មាធិការគណបក្សក្រសួងទេសចរណ៍ | ១០០ ដុល្លារ |
| ៥- | ឯ.ឧ | ប្រាក់ | ចំរើន | សមាជិកព្រឹទ្ធសភា | ១០០ ដុល្លារ |
| ៦- | ឯ.ឧ | គង់ | វិបុល | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយកដ្ឋាន នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១០០ ដុល្លារ |
| ៧- | ឯ.ឧ | លន់ | លឹមថៃ | ប្រធានគណៈកម្មាធិការគណបក្សខេត្តកំពង់ចាម | ១០០ ដុល្លារ |
| ៨- | ឯ.ឧ | ជៀង | អំ | ប្រធានគណៈកម្មាធិការគណបក្សខេត្តស្វាយរៀង | ១០០ ដុល្លារ |
| ៩- | ឯ.ឧ | អូស្មាន | ហាសស្សាន់ | ប្រធានគណៈចលនាសាសនិកឥស្លាមនៃគណបក្សប្រជាជនកម្ពុជា | ១០០ ដុល្លារ |
| ១០- | ឯ.ឧ | សរ | ចំរុង | ប្រធានគណៈកម្មាធិការគណបក្សខេត្តក្រចេះ | ១០០ ដុល្លារ |
| ១១- | ឯ.ឧ | ឃាំ | សុជាតិវង្ស | ប្រធានគណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ | ១០០ ដុល្លារ |
| ១២- | ឯ.ឧ | ឈិត | សុខុន | អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ | ១០០ ដុល្លារ |
| ១៣- | ឯ.ឧ | ម៉ម | ប៊ុននាង | សមាជិកព្រឹទ្ធសភា | ១០០ ដុល្លារ |
| ១៤- | ឯ.ឧ | ម៉ៅ | ធនិន | អភិបាលនៃគណៈអភិបាលខេត្តពោធិ៍សាត់ | ១០០ ដុល្លារ |
| ១៥- | ឯ.ឧ | អ៊ីន | វីរជាតិ | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ១០០ ដុល្លារ |
| ១៦- | ឯ.ឧ | យូ | តិរម្យ | សមាជិកក្រុមការងារចុះខេត្តកំពង់ស្ពឺ ប្រធានក្រុមការងារចុះស្រុកឱរ៉ាល់ | ១០០ ដុល្លារ |
| ១៧- | គណៈកម្មាធិការគណបក្សខេត្តបាត់ដំបង | | | | ១០០ ដុល្លារ |
| ១៨- | គណៈកម្មាធិការគណបក្សខេត្តសៀមរាប | | | | ១០០ ដុល្លារ |
| ១៩- | គណៈកម្មាធិការគណបក្សខេត្តបន្ទាយមានជ័យ | | | | ៥០ ដុល្លារ |
| ២០- | គណៈកម្មាធិការគណបក្សក្រសួងកិច្ចការនារី | | | | ៥០ ដុល្លារ |
| ២១- | ឯ.ឧ | លឹម | គានហោ | ប្រធានគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក | ២០០.០០០ ៛ |
| ២២- | ឯ.ឧ | ម៉ម | ប៊ុនហេង | ប្រធានគណៈកម្មាធិការគណបក្សក្រសួងសុខាភិបាល | ៥០ ដុល្លារ |
| ២៣- | ឯ.ឧ | ជា | យ៉ាវ | អនុប្រធានគណៈកម្មាធិការគណបក្សធនាគារជាតិនៃកម្ពុជា | ២១៣.៤៧០៛ |
| ២៤- | ឯ.ឧ | ជូ | យិនស៊ឹម | រដ្ឋលេខាធិការក្រសួងសុខាភិបាល | ៥០ ដុល្លារ |
| ២៥- | ឯ.ឧ | អ៊ុក | ប្រាថ្នា | រដ្ឋលេខាធិការក្រសួងព័ត៌មាន | ២០០.០០០ ៛ |
| ២៦- | ឯ.ឧ | ប៉ាវ | ហមផាន | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ៥០ ដុល្លារ |
| ២៧- | ឯ.ឧ | សូ | ជុងហួរ | ប្រធានក្រុមប្រឹក្សាខេត្តព្រះសីហនុ | ៥០ ដុល្លារ |
| ២៨- | ឯ.ឧ |ចាយ | បូរិន | អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាម | ៥០ ដុល្លារ |
| ២៩- | ឯ.ឧ | នរៈ | រតនៈវឌ្ឍនោ | រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា | ២០០.០០០ ៛ |
| ៣០- | ឯ.ឧ | ឃួន | រ៉ានីន | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៥០ ដុល្លារ |
| ៣១- | ឯ.ឧ.ឧ.សេនីយឯក | មាស | វីរិទ្ធ | អគ្គលេខាធិការនៃអជ្ញាធរជាតិប្រឆាំងគ្រឿងញៀន | ៥០ ដុល្លារ |
| ៣២- | ឯ.ឧ. | ប៊ុន | លឹមហេង | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ២០០.០០០៛ |
| ៣៣- | ឯ.ឧ | សេង | ទៀង | ជំនួយការផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** | ២០០.០០០៛ |
| ៣៤- | ឯ.ឧ | ថោង | ឃិន | សមាជិកគណៈកម្មាធិការត្រួតពិនិត្យ នៃគណៈកម្មាធិការកណ្តាល | ៥០ ដុល្លារ |
| ៣៥- | ឯ.ឧ | ម៉ៅ | ប៊ុនណារិន | សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា | ១០០.០០០៛ |
| ៣៦- | ឯ.ឧ | ប៉ាន | ប៊ុនធឿន | រដ្ឋលេខាធិការក្រសួងផែនការ | ១០០.០០០៛ |
| ៣៧- | លោកជំទាវ | ស៊ឹង | ស៊ុំយុត | | ១០០.០០០៛ |
| ៣៨- | ឯ.ឧ | គឹម | ឆា | ប្រធានក្រុមប្រឹក្សាខេត្តស្វាយរៀង | ១០០.០០០៛ |
| ៣៩- | ឯ.ឧ | ប៊ិច | សុវណ្ណ | | ១០០.០០០៛ |
| ៤០- | ឯ.ឧបណ្ឌិត | មាស | ប៉ូ | អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ១០០.០០០៛ |
| ៤១- | លោកជំទាវ | និត្យ | ច័ន្ទតារីន | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ១០០.០០០៛ |
| ៤២- | ឯ.ឧ | ឆា | ច័ន្ទលីដា | ទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** | ១០០.០០០៛ |
| ៤៣- | ឯ.ឧ | ម៉ែន | វិបុល | ប្រធានគណៈហិរញ្ញវត្ថុនៃគណៈកម្មាធិការគណបក្សខេត្តស្វាយរៀង | ១០០.០០០៛ |
| ៤៤- | ឯ.ឧ | ជួន | ថេរ៉ាវ៉ាត | ទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី ហេង សំរិន | ១០០.០០០៛ |
| ៤៥- | ឯ.ឧ | ម៉ៅ | ឡាំង | ទីប្រឹក្សាឯកឧត្តម **ខួន ញឹល** អនុប្រធានទី ១ រដ្ឋសភា | ១០០.០០០៛ |
| ៤៦- | ឯ.ឧ | ឆាយ | ឫទ្ធិសែន | អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | ១០០.០០០៛ |
| ៤៧- | ឯ,ឧ | អ៊ុន | ឆាលី | សមាជិកគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណបក្សខេត្តកោះកុង | ១០០.០០០៛ |
| ៤៨- | លោក | អោម | ចន | ប្រធាននាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិនៃអគ្គនាយកដ្ឋានពន្ធដារ | ១០០.០០០៛ |
| ៤៩- | លោក | សាំ | ពិសិដ្ឋ | ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន រាជធានីភ្នំពេញ | ១០០.០០០៛ |
| ៥០- | លោក | សុខ | វិសាលសម្បត្តិ | អនុប្រធានក្រុមការងារចុះជួយឃុំព្រៃដើមថ្នឹង និងឃុំត្នោត១ ស្រុកស៊ីធរកណ្តាល ប្រធានក្រុមហ៊ុនសម្បត្តិមហាសាល | ១០០.០០០៛ |
| ៥១- | លោក | សារ៉ូ | រដ្ឋជាតិ | មន្ត្រីសាលាខេត្តប៉ៃលិន | ៧០.០០០៛ |
| ៥២- | លោកជំទាវ | ខេង | សំវ៉ាដា | រដ្ឋលេខាធិការក្រសួងកិច្ចការនារី | ៥០.០០០៛ |
| ៥៣- | ឯ.ឧ | សាយ | បូរិន | ទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** | ៥០.០០០៛ |
| ៥៤- | ឯ.ឧ | សេង | គឹមសាន | ជំនួយការសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** | ៥០.០០០៛ |
| ៥៥- | ឯ.ឧ | ពត | ចាន់នី | សមាជិកក្រុមការងារចុះជួយខេត្តកំពង់ចាម | ៥០.០០០៛ |
| ៥៦- | ឯ.ឧ | ហេង | វណ្ណា | សមាជិកក្រុមការងារគណៈកម្មាធិការកណ្តាលចុះជួយខេត្តព្រះសីហនុ | ៥០.០០០៛ |
| ៥៧- | លោក | ស៊ាង | ចាន់ | សមាជិកក្រុមការងារគណៈកម្មាធិការកណ្តាលចុះជួយខេត្តព្រះសីហនុ | ៥០.០០០៛ |
| ៥៨- | លោក | ឃួន | សំបូរ | សមាជិកក្រុមការងារគណៈកម្មាធិការកណ្តាលចុះជួយខេត្តព្រះសីហនុ | ៥០.០០០៛ |
| ៥៩- | លោកជំទាវ | សឿ | ច័ន្ទថា | | ៥០.០០០៛ |
| ៦០- | លោក | ជា | វុទ្ធី | សមាជិកក្រុមការងារគណៈកម្មាធិការកណ្តាលចុះជួយខេត្តព្រះសីហនុ | ៥០.០០០៛ |

# អ្នកឧបត្ថម្ភ ទស្សនាវដ្ដី ប្រជាជន លេខ ១៦០

| | | | | | |
|---|---|---|---|---|---|
| ៦១- | លោក | ហួត | ពៅ | ប្រធាននាយកដ្ឋាននីតិវិធីនៃអគ្គលេខាធិការដ្ឋានវុឌ្ឍសភា | ៥០.០០០៛ |
| ៦២- | កញ្ញា | ផាង | និតហ្វៀរី | មន្ត្រីក្រសួងទេសចរណ៍ | ៥០.០០០៛ |
| ៦៣- | លោក | ង៉ោ | ម៉េងជ្រួន | អភិបាលក្រុងប៉ោយប៉ែត | ៥០.០០០៛ |
| ៦៤- | លោក | អ៊ុំ | រាត្រី | ប្រធានគណៈកម្មាធិការគណបក្សក្រុងសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ | ៥០.០០០៛ |
| ៦៥- | លោក | កែវ | សែន | ប្រធានគណៈកម្មាធិការគណបក្សស្រុកអូរជ្រៅ | ៥០.០០០៛ |
| ៦៦- | លោក | សួន | សុធី | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តបន្ទាយមានជ័យ | ៥០.០០០៛ |
| ៦៧- | លោក | គាត | ហ៊ុល | ប្រធានគណៈកម្មាធិការគណបក្សសង្កាត់ផ្សារកណ្តាល ខេត្តបន្ទាយមានជ័យ | ៥០.០០០៛ |
| ៦៨- | លោក | ចាប | ឌីណា | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស ខណ្ឌដូនពេញ | ៥០.០០០៛ |
| ៦៩- | ឯ.ឧ | ទេង | សាខុន | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | ៤០.០០០៛ |
| ៧០- | លោក | លី | សារី | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស ប្រធានមន្ទីររៀបចំដែនដី ខេត្តបន្ទាយមានជ័យ | ៤០.០០០៛ |
| ៧១- | លោក | គីម | សុវណ្ណ | ប្រធានមន្ទីរសាធារណការ ខេត្តបន្ទាយមានជ័យ | ៤០.០០០៛ |
| ៧២- | ឯ.ឧ | ស៊ិន | ធុន្នី | សមាជិកអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួងធនធានទឹក | ៣០.០០០៛ |
| ៧៣- | ឯ.ឧ | ឈុំ | វណ្ណារិទ្ធ | អភិបាលរងខេត្តបន្ទាយមានជ័យ | ៣០.០០០៛ |
| ៧៤- | លោក | ម៉ៅ | សុខលីម | អនុប្រធានមជ្ឈមណ្ឌលជាតិវេជ្ជសាស្ត្របូរាណក្រសួងសុខាភិបាល សមាជិកក្រុមការងារចុះខេត្តតាកែវ | ៣០.០០០៛ |
| ៧៥- | លោក | ចាន់ | ស៊ីណាត | សមាជិកគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក | ៣០.០០០៛ |
| ៧៦- | លោក | ឃុ | ពៅ | អភិបាលស្រុកស្វាយចេក | ៣០.០០០៛ |
| ៧៧- | លោក | ទេព | វិសិដ្ឋ | អនុប្រធានគណៈត្រួតពិនិត្យគណបក្សខេត្តព្រះសីហនុ | ៣០.០០០៛ |
| ៧៨- | កញ្ញា | កែវ | សុជាតា | អនុប្រធានលេខាធិការដ្ឋានអមគណៈកម្មការទី ៤ នៃព្រឹទ្ធសភា | ៣០.០០០៛ |
| ៧៩- | ឯ.ឧ | ចុង | ផែត | អភិបាលរងខេត្តបន្ទាយមានជ័យ | ២០.០០០៛ |
| ៨០- | លោក | ឈា | ប៊ុនរិទ្ធ | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ២០.០០០៛ |
| ៨១- | លោក | ម៉ៅ | ហាក់ | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ២០.០០០៛ |
| ៨២- | លោក | លឹម | វីរក្ស | សមាជិកគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក និងឧតុនិយម | ២០.០០០៛ |
| ៨៣- | លោក | លឹម | ថេង | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ២០.០០០៛ |
| ៨៤- | លោក | ឃ្លោក | សំអាង | សមាជិកក្រុមការងារចុះខេត្តកំពង់ចាម | ២០.០០០៛ |
| ៨៥- | លោក | ជា | គីមលីន | ប្រធានលេខាធិការដ្ឋានអមគណៈកម្មការទី ៤ នៃព្រឹទ្ធសភា | ២០.០០០៛ |
| ៨៦- | លោក | ទូច | សារ៉េត | ប្រធានការិយាល័យគណនេយ្យកសិកម្ម ខេត្តបន្ទាយមានជ័យ | ២០.០០០៛ |
| ៨៧- | លោក | ហ៊ុង | ជ្រិន | ប្រធានគណៈហិរញ្ញវត្ថុនៃគណៈកម្មាធិការគណបក្សខេត្តបាត់ដំបង | ២០.០០០៛ |
| ៨៨- | លោក | ម៉ី | វុទ្ធា | មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង | ២០.០០០៛ |
| ៨៩- | លោក | អ៊ុក | គីមអាន | មន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ២០.០០០៛ |
| ៩០- | លោក | គួច | ចាន់និត្យ | អាជីវករ ខេត្តបន្ទាយមានជ័យ | ២០.០០០៛ |
| ៩១- | លោក | លី | សារុន | មន្ត្រីក្រសួងហិរញ្ញវត្ថុ | ១៥.០០០៛ |
| ៩២- | លោក | អ៊ុច | សាវន | អនុប្រធានមន្ទីរកសិកម្ម ខេត្តបន្ទាយមានជ័យ | ១៥.០០០៛ |
| ៩៣- | ឯ.ឧ | សេង | សុមុនី | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួងធម្មការ និងសាសនា | ១០.០០០៛ |
| ៩៤- | ឯ.ឧ | ប៊ុញ | សច្ចៈ | អគ្គនាយកកិច្ចការបច្ចេកទេសនៃក្រសួងធនធានទឹក និងឧតុនិយម | ១០.០០០៛ |
| ៩៥- | លោក | ម៉ី | លីហួត | សមាជិកក្រុមការងារចុះខេត្តកំពង់ចាម | ១០.០០០៛ |
| ៩៦- | លោក | ជួន | វណ្ណរិទ្ធ | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ៩៧- | លោក | ម៉ម | ឫស | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងធនធានមនុស្សនៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ៩៨- | លោក | សៅ | សម្ផស្ស | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងនៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ៩៩- | លោក | ឈុន | ប៊ុនឈឿន | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១០០- | លោក | ថេង | ប៊ុនតេង | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១០១- | លោក | ស្វាយ | សុគន្ធី | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១០២- | លោក | សុខ | ចំណាន | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១០៣- | លោក | សៅ | សម្ការ | ប្រធានការិយាល័យបណ្តុះបណ្តាលនៃនាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស នៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ១០៤- | លោក | និត | ចរិយា | ប្រធានការិយាល័យគណនេយ្យនាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ១០៥- | លោក | សែម | សំណាង | ប្រធានការិយាល័យគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រនាយកដ្ឋានធារាសាស្ត្រ កសិកម្ម នៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ១០៦- | លោក | សុខ | តារា | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១០៧- | លោក | សូ | ផល្លី | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១០៨- | លោក | ហួត | ធាន | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១០៩- | លោក | ទឹម | វុឌ្ឍារី | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១០- | លោក | ណុប | វៀមណី | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១១- | លោក | សារុន | សម្បត្តិ | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១២- | លោក | សរ | វិចិត្រ | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១៣- | លោក | ទូច | សុផល្លា | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១៤- | លោក | ជុំ | ឧត្តរ៉ា | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១៥- | លោក | ឈ្លាង | ប៊ុយ | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១៦- | លោក | យស់ | ធុល | សមាជិកក្រុមការងារចុះស្រុកកំពង់លាវ ខេត្តព្រៃវែង | ១០.០០០៛ |
| ១១៧- | លោក | ឡុង | ចន្ថា | សមាជិកក្រុមការងារចុះស្រុកកំពង់លាវ ខេត្តព្រៃវែង | ១០.០០០៛ |
| ១១៨- | លោក | ឡាច | តីរ៉ាត់ | សមាជិកក្រុមការងារចុះស្រុកបាភ្នំ ខេត្តព្រៃវែង | ១០.០០០៛ |
| ១១៩- | លោក | ឈាង | សុវណ្ណារ៉ា | មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង | ១០.០០០៛ |





សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រារព្ធចំពិធីបុណ្យកាន់បិណ្ឌវេនទី ១ និងប្រគេនទេយ្យទានព្រះសង្ឃចំនួន ៨៤ វត្ត ៤



សម្តេចតេជោ **ហ៊ុន សែន** អញ្ជើញចូលរួមពិធីតាំងពិព័រណ៍អាស៊ាន-ចិន ........... ៥



**សម្តេចតេជោ** និងការគាំពារ និងអភិវឌ្ឍន៍កុមារតូច ការជំរុញកំណែទម្រង់វិស័យអប់រំ ការប្រយុទ្ធប្រឆាំងអំពីពុករលួយ ........................ ៧



សម្តេចចក្រី **ហេង សំរិន** បំពេញទស្សនកិច្ច នៅសាធារណរដ្ឋប្រជាធិ-បតេយ្យប្រជាមានិតឡាវ ១១



ឯកឧត្តម **សុខ អាន** ប្រជុំត្រួតពិនិត្យការងាររបស់ក្រុមការងារថ្នាក់ជាតិចុះជួយខេត្តតាកែវ រយៈពេល ១ ឆ្នាំ ១២



ឯកឧត្តម **អ៊ឹម ឈុនលឹម** ប្រជុំជីវភាពនយោបាយ នៅខេត្តមណ្ឌលគិរី ១៣

**និពន្ធនាយក :**
**លោក តាក ស៊ុនអ៊ី**

**គណៈកម្មការនិពន្ធ**
១. លោក ខៀវ ណារី
២. លោក អ៊ុម សុន្ទរៈ
៣. លោក វង្ស សារុធ
៤. លោក ទាវ សារៈមុនី
៥. លោក សុខ សុធន

**លេខានិពន្ធ**
១. លោក ជុំ សម្បត្តិ
២. លោក ម៉ក់ ឈិន

**អ្នកបកប្រែភាសា**
១. លោកស្រី ម៉ែន នារីសោភ័គ

**អ្នកថតរូប**
១. លោក សុផាត វីរៈមុនី

**វិចិត្រករ**
១. លោក ធា សារុធ

អាស័យដ្ឋាន :
លេខ ២០៣
មហាវិថី ព្រះនរោត្តម
ភ្នំពេញ-កម្ពុជា
ទូរស័ព្ទលេខ :
០២៣ ២១៩ ០៦៥

**Address :**
**No 203 Preah Norodom Bld.**
**Phnom Penh Cambodia**
**Tel : 023 219 065**

## ក្របមុខ

សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ជួបសម្តែងការគួរសម ឯកឧត្តម **ជុំម៉ាលី សៃយ៉ាសន** ប្រធានរដ្ឋ និងជាអគ្គលេខាធិការ មជ្ឈិមបក្សប្រជាជនបដិវត្តន៍ឡាវ

# មាតិកា
# Contents

វិចារណកថា : ជោគជ័យឆ្នាំទី ១ របស់រាជរដ្ឋាភិបាល នីតិកាលទី៥ នៃរដ្ឋសភា.........................
Editorial : The First-Year Gains of the Fifth Legislative Term Royal Government............... ១

- សកម្មភាពសមាជិកព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស ................................ ១៤
- លទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច................................................................................ ១៧
- សមិទ្ធិថ្មីនៅទឹកដីទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រ ................................................................ ១៩
- គោលដៅអាទិភាពរបស់ក្រសួងបរិស្ថាន និងលទ្ធផលការងារជិតមួយឆ្នាំនេះ.......................... ២១
- លទ្ធផលនៃការប្រឡងមធ្យមសិក្សាទុតិយភូមិឆ្នាំនេះ បង្ហាញពីជំហានទៅមុខមួយដ៏សំខាន់នៃកំណែទម្រង់វិស័យអប់រំ.......................................................................................... ២៤
- វប្បធម៌ : ប្រាសាទគោកងារ នៅខេត្តបុរីរម្យ............................................................ ២៦
- វិទ្យាសាស្ត្រសុខភាព : ក្រអៅឈូកជួយកម្ចាត់ជាតិពុលនិងការឡើងកម្តៅក្នុងខ្លួន........................ ទុរេន Viagra ធម្មជាតិ........................................................................ ២៧
- ទឹកដីមាតុភូមិ : ឃុំបន្ទាយឆ្មារ : ទឹកដីចាស់ ផ្លាស់មុខមាត់ថ្មី.............................................. ២៨
- កំណាព្យ : ទេសភាពទៀបអស្តង្គត........................ សំណើច ............................................ ៣១

# ទស្សនាវដ្តី ប្រជាជន

THE PRACHEACHUN MAGAZINE



ឆ្នាំទី១៤ លេខ ១៦០ ខែកញ្ញា ឆ្នាំ ២០១៤



**គំរូប្លង់ស្ពានអាកាស និងផ្លូវក្រោមដីតិចណូ**

( សម្ពោធបើកការដ្ឋានសាងសង់ថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០១៤)




**ស្ថានីយចម្រោះទឹកសំណល់ប្រព័ន្ធលូបង្ហូរទឹក និងស្ពារស្ទឹងសៀមរាប ខេត្តសៀមរាប**

( សម្ពោធថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០១៤)

**ចែកជូនដោយឥតគិតថ្លៃ**